ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៣២៥**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 30-Mar-2017, 14:10
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡៃ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ចូសេហ្វ អេនឌ្រូ បិយលី | អង់គ្លេស |
| លោក សេង លាង | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក សុះ ពន់យ៉ាមីន (2-TCCP-244) | ខ្មែរ |
| លោក សេង ឃុយ (2-TCW-832) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក សុះ ពន់យ៉ាមីន** (2-TCCP-244)

សួរបន្តដោយលោក ឌេល លីសាក់ ផ្តើមពី ....................................................ទំព័រ ២

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................................................ទំព័រ ១២

សួរដោយកញ្ញា អង់តា ហ៊្គីសសេ ផ្តើមពី....................................................ទំព័រ ២៧

សួរដោយលោក គង់ សំអុន ផ្តើមពី ....................................................ទំព័រ ៤២

**ការសួរសំណួរទៅសាក្សី៖ លោក សេខ ឃុយ** (2-TCW-832)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................................................ទំព័រ ៥៣

សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្តើមពី ....................................................ទំព័រ ៥៥

សួរដោយលោក សេង លាង ផ្តើមពី ....................................................ទំព័រ ៧៥

សួរដោយលោក ហុង គីមសួន ផ្តើមពី ....................................................ទំព័រ ៧៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សុះ ពន់យ៉ាមីន បញ្ចប់ ហើយនិងផ្តើមធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-832។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះគឺ លោក សុះ ពន់យ៉ាមីន។ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ហើយសាក្សីបន្ទាប់ដែលត្រូវមកផ្តល់សក្ខីកម្ម បន្ទាប់ពីបញ្ចប់សក្ខីកម្មលោក សុះ ពន់យ៉ាមីន គឺសាក្សីដែលមានរហស្សនាម 2-TCW-832 ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ ហើយសាក្សីរូបនេះបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ

នេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាពឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខ ឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា ថាលោក នួន ជា នៅថ្ងៃនេះ មានអាការៈឈឺចង្កេះ វិលមុខ ពេលអង្គុយរយៈពេលខ្លី និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៣:៤៤]

ផ្អែកលើមូលដ្ឋាននេះ និងបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការ ពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់សវនាការថ្ងៃនេះ។

ហើយជាបន្តទៅនេះ ផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ហើយជម្រាបថា មានពេលរយៈពេលអតិបរមា១៥នាទី ក្នុងការបន្តការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ ម្សិលមិញ នៅពេលដែលយើងបានបញ្ចប់ <យើងបាន>និយាយគ្នាអំពីអំឡុងពេលដែលលោកត្រូវបានបង្ខំឲ្យចាកចេញពីស្វាយឃ្លាំង និងទៅរស់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅស្រុកដំបែ និងនិយាយអំពី ថាតើប្រជាជនចាម នៅភូមិស្វាយកាំបិតត្រូវបានគេដាក់ឲ្យរស់នៅចម្រុះគ្នាជាមួយប្រជាជនខ្មែរ ហើយអ្នកខ្លះ គឺថាត្រូវទៅដេកនៅក្នុងជង្រុកស្រូវ <និង>នៅពីខាងក្រោមផ្ទះរបស់គ្រួសារខ្មែរ។ លោកដើមបណ្ដឹងរដ្ឋប្បវេណី តើតំបន់ដែលប្រជាជនចាមត្រូវគេ<បង្ខំឲ្យ>ផ្លាស់ទីលំនៅឲ្យរស់នៅក្នុងស្រុកដំបែហ្នឹង គឺតើតំបន់ហ្នឹង ជាតំបន់មួយដែលសម្បូរជំងឺគ្រុនចាញ់មែនទេ?

[០៩:០៥:៤១]

**លោក ស៊ុះ ពន់យ៉ាមីន៖**

**ឆ៖** បាទ កន្លែងនុ៎ងជាតំបន់ដែលពោរពេញទៅដោយជំងឺគ្រុនចាញ់។

**ស៖** ហើយថាតើប្រជាជនចាមដែលត្រូវដេកនៅខាងក្រោមផ្ទះរបស់ប្រជាជនខ្មែរ តើពួកគាត់ត្រូវបានទាហានខ្មែរក្រហមដែលផ្លាស់ទីលំនៅឲ្យទៅនៅស្រុកដំបែនោះ ផ្ដល់មុងសម្រាប់ដេកទេ?

**ឆ៖** អត់មានផ្ដល់អីទេ។ អ្វីជារបស់របរដែលយើងយកជាប់ខ្លួនប៉ុនណា គឺប៉ុណ្ណឹង គេមិនចែកចាយឲ្យទៀតទេ។

**ស៖** តើមានប្រជាជនចាមណាម្នាក់នៅក្នុងក្រុមរបស់លោកហ្នឹង ស្លាប់ដោយសារតែជំងឺគ្រុនចាញ់ <ឬការ>អត់ឃ្លានដែរឬទេ ក្រោយពីលោកត្រូវបានគេបញ្ជូនទៅ<ភូមិ>ស្វាយកាំបិតនោះ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី កុំអាល់ទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ខ្ញុំជំទាស់ទៅនឹងការតាំងសំណួរបែបនេះ<។ ខ្ញុំចង់ជំទាស់ទៅនឹង>សំណួរដំបូង<ដែលសួរ>ថាតើស្រុកដំបែ គឺជាតំបន់ដែលមានជំងឺគ្រុនចាញ់ខ្ពស់ ឬក៏អត់ <ខ្ញុំគិតថា>សាក្សីមិនមានគុណវុឌ្ឍិ ដើម្បីលើកឡើងអំពីចំណុចនេះទេ<។> ហើយគាត់ក៏គ្មានចំណេះដឹងអីខាងផ្នែកវេជ្ជសាស្ត្រ <ដើម្បី>អាចបញ្ជាក់<>ថា<តើប្រជាជនស្លាប់ដោយសារជំងឺ>គ្រុនចាញ់ <ឬខ្វះអាហារ> ឬក៏<មូលហេតុផ្សេងៗទៀត>នោះទេ។ បើ<សិនគាត់ធ្លាប់ធ្វើការនៅ>មន្ទីរពេទ្យ ប្រហែលជាអាច<ឆ្លើយបាន ប៉ុន្តែគាត់មិនអាចបញ្ជាក់បានទេ ក្នុងនាមជាប្រជាពលរដ្ឋធម្មតានោះ>។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំយល់ឃើញថា សាក្សី<បានយល់ដឹងពីអ្វីដែលបានកើតឡើងចំពោះគ្រួសារដែលបានបញ្ជូនមក>ជាមួយនឹងគាត់<។ យើងអាចសួរបញ្ជាក់ពីអ្វីដែល>គាត់<>ដឹង ឬក៏<អ្វីដែលគាត់>មិនដឹង<>។ ហើយ<មេធាវីការពារក្ដីមានសិទ្ធិពេញលេញដើម្បី>សួរបញ្ជាក់អំពីចំណុចនេះ<។ គាត់បានផ្ដល់ចម្លើយមួយចំនួនពាក់ព័ន្ធនឹងបញ្ហានេះនៅក្នុងបទសម្ភាសន៍ និងឯកសារដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់។ ដូច្នេះវាជាបញ្ហាមួយ ដែលខ្ញុំជឿថាយើងមានសិទ្ធិដើម្បី>តាំងសំណួរ<បែបនេះ>បាន។

[០៩:០៨:០០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី។ ដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសំណួរ ដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិចុងក្រោយអម្បាញ់មិញនេះ ប្រសិនបើលោកចងចាំសំណួរ។ ទំនងមិនចាំទេ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ តាំងសំណួរសាជាថ្មី។

**លោក ឌេល លីសាក់៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើមានចាមណាម្នាក់នៅក្នុងក្រុមរបស់លោកនេះ ដែលគេបញ្ជូនទៅភូមិស្វាយកាំបិតហ្នឹង ស្លាប់ដោយសារតែជំងឺគ្រុនចាញ់ ឬក៏ស្លាប់ដោយសារកង្វះចំណីអាហារនោះដែរទេ?

**លោក សុះ ពន់យ៉ាមីន៖**

**ឆ៖** ចាមដែលចំណោមចាមដែលនៅ ទៅគេជម្លៀសទៅនៅជាមួយខ្ញុំហ្នឹង មានចំនួន២០គ្រួសារ។ ហើយខ្ញុំសូមជម្រាបថា នៅសល់តែប្រាំពីរគ្រួសារទេ ដែលសល់ពីការស្លាប់គ្រុនចាញ់ ឬក៏ការស្រេកឃ្លាន។

[០៩:០៩:៣៧]

**ស៖** សូមលោកជម្រាបជូនតុលាការផងថា លោកដឹងដោយរបៀបណាដែរ ដែលថាចាមដែលមកជាមួយនឹងលោកហ្នឹង ស្លាប់ដោយរបៀបណានោះ ហើយលោកៗដឹងដោយរបៀបណាដែរ?

**ឆ៖** ខ្ញុំដឹងការពិត ដោយសារខ្ញុំរស់នៅកន្លែងនុំងជាមួយគ្រួសារដែលស្លាប់ហ្នឹងហើយ ហើយខ្ញុំ

ក៏បានធ្វើសកម្មភាព ដូចថាមើលការថែទាំ ការឈឺថ្កាត់ ហើយពេលគាត់ស្លាប់ ខ្ញុំបាននាំគាត់ទៅកប់នៅកន្លែងហ្នឹង ហើយកន្លែងដែលខ្ញុំកប់ ខ្ញុំចំណាំទាល់សព្វថ្ងៃហ្នឹង។

**ស៖** បាទ សូមអរគុណ។ ប្រធានបទមួយទៀតខ្ញុំសូមសួរលោក ពីម្សិលមិញ លោកបានឆ្លើយថា នៅក្នុងឆ្នាំ១៩៧៥ ដោយចាប់ពីពេលហ្នឹងមក ប្រជាជនចាមនៅស្វាយឃ្លាំងមិនត្រូវបានអនុញ្ញាតឲ្យគោរពប្រតិបត្តិ<សាសនា> ឬក៏និយាយ<ភាសា>ចាមនោះទេ។ ខ្ញុំចង់អាន<សម្រង់មួយ អំពីប្រធានបទដូចគ្នាក្នុង>កំណត់ហេតុ<ស្តាប់>ចម្លើយរបស់បងប្រុសរបស់លោក និយាយអំពីការចាមបះបោរ គឺឯកសារ E3/7675, ERN ជាភាសាខ្មែរ <00221853>, បារាំង<> 00293924 ដល់ 25, អង់គ្លេស 00221859។ ខ្ញុំសូមដកស្រង់៖ “នៅក្នុងឆ្នាំ១៩៧៥ ការ<គោរព>ប្រតិបត្តិសាសនាអ៊ីស្លាមត្រូវ<ហាមឃាត់យ៉ាងតឹងរ៉ឹង>។ ទ្វារនៃព្រះវិហារត្រូវបិទទាំងស្រុង។ គម្ពីរ<គូរ៉ាន>ត្រូវបាន<ប្រមូលយក>ដុតចោលទាំងអស់។ <តាឡុង ដែលជាប្រធានឃុំស្វាយឃ្លាំង បានឃើញហេតុការណ៍ទាំងអស់នេះដោយផ្ទាល់។> តាយោគ ដែលជាសមាជិករបស់គណៈ<>រដ្ឋបាលស្រុកហ្នឹង បានហៅ<គ្រប់គ្នា>ឲ្យទៅចូលរួមប្រជុំ និងប្រកាសថា ស្រីៗ<>ត្រូវតែកាត់សក់របស់ខ្លួនឲ្យខ្លី ហើយការបួងសួងទាំងអស់គឺថាត្រូវហាមឃាត់ទាំងស្រុងតែម្តង។” បញ្ចប់ការដកស្រង់។ លោកដើមបណ្តឹងរដ្ឋប្បវេណី <តើ> លោកចាំអំពីកិច្ចប្រជុំដែលបងប្រុសរបស់លោក<បានរៀបរាប់នេះទេ> គឺកិច្ចប្រជុំដែលត្រូវបានកោះហៅដោយកម្មាភិបាលដែលជាសមាជិកគណៈ<>ស្រុក ដែលប្រកាសថា ការបួងសួងត្រូវហាមឃាត់ទាំងស្រុង <តើ>លោកដឹងទេ?

**ឆ៖** ខ្ញុំឆ្លើយថា ពាក្យទាំងប៉ុន្មាន គឺត្រឹមត្រូវ។

[០៩:១២:៤៨]

**ស៖** លោកចាំទេថា លោកនៅក្នុងកិច្ចប្រជុំនេះដែរឬទេ គឺកិច្ចប្រជុំដែលសមាជិកគណៈ<>ស្រុកប្រកាសថា ហាមដាច់ខាតមិនឲ្យអ្នកភូមិសំឃុំាងនេះ លោកបានចូលរួមក្នុងកិច្ចប្រជុំនេះទេ?

**ឆ៖** ពេលនោះ ខ្ញុំមិនបានចូលរួមទេ ដោយសារគេចាត់តាំងខ្ញុំឲ្យទៅធ្វើការផ្សេង។

**ស៖** ប្រធានបទមួយទៀតដែលលោកបានឆ្លើយកាលពីម្សិលមិញ លោកបានឆ្លើយថា មានកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគកណ្តាលចូលទៅដល់តំបន់របស់លោក<នៅឆ្នាំ១៩៧៨> ហើយចាប់កម្មាភិបាលភូមិភាគបូព៌ា។ ខ្ញុំចង់អានសម្រង់មួយចេញអំពីកិច្ចសម្ភាសន៍របស់សហចៅក្រមស៊ើបអង្កេតជាមួយនឹងលោកផ្ទាល់ ទៅលើឯកសារនេះ គឺឯកសារ E3/5210, ERN ជាភាសាខ្មែរ 00218572,

អង់គ្លេស 00242073, បារាំង 00334652។ នេះគឺអ្វីដែលលោកបានឆ្លើយ សូមដកស្រង់៖ “ខ្ញុំបានឃើញសពដែលត្រូវបានគេសម្លាប់ចោលនៅក្នុងព្រៃ។ បន្តទៅទៀត ក្រោយពីការឈ្លានពានពីសំណាក់កងទ័ពវៀតណាមនៅក្នុងឆ្នាំ១៩៧៨ និង<ក្រោយ>ការមកដល់នៃកម្មាភិបាលភូមិភាគកណ្ដាល ដើម្បីមកជំនួសកម្មាភិបាលភូមិភាគបូព៌ា ប្រជាជនត្រូវបានគេចាប់ខ្លួនដឹកជញ្ជូនតាមឡានធំៗ ហើយយកទៅសម្លាប់ចោលនៅក្នុងព្រៃ។ ខ្ញុំឃើញគេយកកម្មាភិបាលភូមិភាគបូព៌ាដឹកចូលទៅក្នុងព្រៃ សម្លាប់ចោលនៅទីនោះ។” បញ្ចប់ការដកស្រង់។ អ្វីដែលខ្ញុំចង់សួរទៅលោកឱ្យលោកបញ្ជាក់នេះ លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកពិតជាបានឃើញគេដឹកកម្មាភិបាលចូលទៅក្នុងព្រៃ ហើយនៅពេលនោះដែរនោះ តើលោកពិតជាបានឃើញសាកសពនៅក្នុងព្រៃមែនទេ? <តើលោកអាចឆ្លើយបំភ្លឺជូនអង្គជំនុំជម្រះបានទេ?>

[០៩:១៥:១៧]

**ឆ៖** ខ្ញុំសូមឆ្លើយថា ខ្ញុំបានឃើញពិត។ ហើយពួកទាហានគេមកចាប់កម្មាភិបាលហ្នឹងនៅភូមិរបស់ខ្ញុំផ្ទាល់។ ហេតុនេះហើយបានខ្ញុំចង់បញ្ជាក់ថា សម្រាប់ខ្ញុំគឺសម្រាប់ឃើញពិត ហើយខ្មោចដែលខ្ញុំទៅជួបប្រទះ ខ្ញុំស្គាល់ទាំងឈ្មោះទៀត ឈ្មោះ ហ៊ុត។ កាលហ្នឹងខ្ញុំដើរឃ្វាលក្របី ស្រាប់តែខ្ញុំឃ្លាន ខ្ញុំទៅរកទឹកផឹក អ៊ីចឹងមាននៅក្បែរគុម្ព គេហៅថារំចេក ដើមរំចេកហ្នឹង។ អ៊ីចឹងឈ្មោះ យាយហ៊ុត ខ្ញុំស្គាល់ទាំងឈ្មោះទៀត។ យាយហ្នឹងជាអ្នកចុងភៅដាំបាយ។ អានេះជារឿងពិត។

**ស៖** ហើយតើលោកអាចជម្រាបជូនតុលាការបានទេ លោកបានឃើញសាកសពហ្នឹង <ប្រហែល>ប៉ុន្មាននាក់ដែរ?

**ឆ៖** ខ្ញុំសូមនិយាយថា សាកសពខ្ញុំឃើញតែម្នាក់ តែរណ្ដៅខ្ញុំឃើញពីររណ្ដៅដ៏ធំៗ។ អ៊ីចឹងហើយក្រោយមក ខ្ញុំចូលទៅបោចវល្លិ៍ គេឱ្យខ្ញុំទៅបោចវល្លិនៅក្នុងព្រៃហ្នឹង ខ្ញុំឃើញរណ្ដៅ។ មុនដំបូងខ្ញុំអត់ឃើញទេ ស្រាប់តែធុំស្អុយមក ខ្ញុំចូលរុកៗទៅ ឃើញរណ្ដៅពីរទន្ទឹមគ្នា។ អ៊ីចឹងហេតុផលអាឃើញសាកសពនៅលើកគោកហ្នឹង ខ្ញុំឃើញតែម្នាក់ហ្នឹង ព្រោះខ្ញុំមើលឃើញរួច ខ្ញុំខ្លាច ខ្ញុំដាកខ្លួនចេញមក ខ្ញុំខ្លាច។ អ៊ីចឹងបានថា បានន័យថាខ្ញុំឃើញខ្មោចដែរ សាកសពនៅលើគោកតែម្នាក់ យាយហ៊ុត ហ្នឹងតែម្ដង។

[០៩:១៧:០៩]

**ស៖** នេះប្រហែលជាសំណួរចុងក្រោយរបស់ខ្ញុំហើយលោក<។> នៅត្រង់<ផ្នែកដូចគ្នានៃ>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

កំណត់ហេតុស្តាប់ចម្លើយរបស់លោកជាមួយសហចៅក្រមស៊ើបអង្កេត លោកបន្តឆ្លើយដូចតទៅ សូមដកស្រង់៖ “ពួកមកពីភូមិភាគកណ្តាលគឺជាមនុស្សឃោរឃៅ ហើយចាត់វិធានការតឹងតែងណាស់។ គេបានចាប់ផ្តើមសម្លាប់ប្រជាជនភូមិភាគបូព៌ាដោយគ្មានរើសមុខ រួមមានទាំងពួកជនជាតិចាម ហើយនិងចិន ដោយចោទប្រកាន់ថា ជាមនុស្សក្បាលយួនខ្លួនខ្មែរ។” បញ្ចប់ការដកស្រង់។ <សំណួរ>ទី១ ហេតុអ្វីជាលោកឆ្លើយថា <>កម្មាភិបាលភូមិភាគកណ្តាលនេះ គឺជាមនុស្សឃោរឃៅ <ដែលបានចាត់វិធានការតឹងតែងណាស់មកលើលោក>?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ សំណួរនេះគឺថាត្រូវបានអង្គជំនុំជម្រះហាមឃាត់ក្នុងការដែលអានកំណត់ហេតុមុន <ដោយមិនបាន>សួរសំណួរបើក<សិន> ហើយ<បន្ទាប់មកត្រឡប់ទៅចម្លើយរបស់សាក្សី ដើម្បី>រំឭកការចងចាំ<បែបនេះ>។ អង្គជំនុំជម្រះគឺថាបានលុបបំបាត់នូវ<>ការអនុវត្តបែបនេះ <ហើយការតាំងសំណួរបែបនេះគួរតែត្រូវបានហាមឃាត់>។ អ៊ីចឹងខ្ញុំសូមជំទាស់បញ្ហានេះ <លោកប្រធាន>។

**លោក ឌេល លីសាក់៖**

ខ្ញុំមិនចង់ជំទាស់ទេ យើងមិន<បាន>លុបបំបាត់ចោលនូវ<ការអនុវត្តបែបនេះ>ទេ។ <កាល>ពីម្សិលមិញ<សាក្សីត្រូវបានសួរអំពីប្រធានបទនៃការមកដល់នេះ។> ខ្ញុំ<នឹង>សួរ<សំណួរមួយចំនួនបន្ថែមទៀត>តែប៉ុណ្ណោះ ហើយខ្ញុំយល់ឃើញថាខ្ញុំមានសិទ្ធិសួរសាក្សីអំពីកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ទៅលើប្រធានបទដែលខ្ញុំកំពុងតែសួរ និងអ្វីដែលគាត់ទើបតែបានឆ្លើយកាលពីម្សិលមិញ។

[០៩:១៩:១៣]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២០:២៤]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធចោលនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី វ៉ិចទ័រ កូប៉េ

ដោយសារមូលហេតុនៃសំណួរនេះ គឺមិនមែនស្ថិតនៅក្នុងប្រភេទសំណួរដែលអង្គជំនុំជម្រះបានហាមឃាត់ទេ។ បានន័យថា សហព្រះរាជអាជ្ញាបានដកស្រង់នូវចម្លើយដែលគាត់បានឆ្លើយពីកន្លងមក ដើម្បីនិងកំណត់ហេតុដែលគាត់បានឆ្លើយកន្លងមកនេះ ដើម្បីសួរបញ្ជាក់នូវអ្វីដែលគាត់បានផ្ដល់ចម្លើយរួចហើយប៉ុណ្ណោះ។ មិនមែនអានសំណួរហើយ បានសួរក្រោយនោះទេ។

សូមអញ្ជើញសាក្សី សូមឆ្លើយតប បើសិនជាចងចាំ! ទំនងមិនចាំទេ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ តាំងសំណួរនោះសាឡើងវិញ។

**លោក ឌេល លីសាក់៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួររបស់ខ្ញុំគឺអ៊ីចេះ លោកដើមបណ្ដឹងរដ្ឋប្បវេណី ហេតុអ្វីក៏លោកនិយាយថា កម្មាភិបាលពីភូមិភាគកណ្ដាលគឺជាមនុស្សឃោរឃៅ ហើយប្រើប្រាស់វិធានការតឹងតែង?

**លោក សុះ ពន់យ៉ាមីន៖**

**ឆ៖** ខ្ញុំសូមឆ្លើយថា អ្វីដែលគេធ្វើកន្លងមក ហើយមិនមែនសម្រាប់ខ្ញុំឮគេថា ឬក៏ខ្ញុំមើលឃើញទេ សម្រាប់ខ្ញុំរស់នៅក្នុងសង្គមគេ អ៊ំ ក្នុងឃុំគេហ្នឹង។ ហើយខាងភូមិភាគកណ្ដាលមក បានន័យថា ការតឹងតែង រឹតបន្តឹង ហើយការកាប់សម្លាប់ខ្លាំង ដោយសារខ្ញុំមើលឃើញនឹងភ្នែកខ្លួនឯង ហើយខ្ញុំរស់នៅក្នុង នៅពេលនោះ ដោយការការគ្រប់គ្រងរបស់គេ។

[០៩:២២:១៣]

**ស៖** ហើយសំណួរចុងក្រោយរបស់ខ្ញុំ លោកក៏បានឆ្លើយប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា កម្មាភិបាលភូមិភាគកណ្ដាលចោទប្រកាន់<>អ្នកភូមិ<>ថាជាមនុស្សក្បាលយួនខ្លួនខ្មែរ ហើយ<ពួកគេ>សម្លាប់ជនជាតិចាម និងជនជាតិចិន<>។ <តើ>ធ្វើម៉េចបានជាលោកដឹងថា កម្មាភិបាលភូមិភាគកណ្ដាលហ្នឹង <ជាអ្នក>សម្លាប់ជនជាតិចាម<>?

**ឆ៖** ខ្ញុំដឹង ដោយសារខ្ញុំមើលឃើញ ដូចខ្ញុំបញ្ជាក់អំមិញហ្នឹង។ និយាយខ្លីថា ខ្ញុំរស់ក្រោមការត្រួតត្រារបស់គេ អ៊ីចឹងខ្ញុំមើលឃើញនឹងភ្នែកថា អ្វីដែលគេកំពុងតែធ្វើអ្វី ដំណាក់កាលដែលគេមកគ្រប់គ្រងរយៈពេលដ៏ខ្លីហ្នឹង។ អ៊ីចឹង ខ្ញុំមើលឃើញការពិត។

**ប្រធានអង្គជំនុំ៖**

បាទ អស់ពេលហើយ សហព្រះរាជអាជ្ញាអន្តរជាតិ។ បាទ បន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដែលដំបូងនេះ ផ្តល់ទៅមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ហើយបញ្ជាក់ថា នៅវគ្គសវនាការមួយវគ្គដំបូងនេះ គឺផ្តល់ពេលវេលារហូតដល់ម៉ោងដប់ និងម្ភៃនាទី។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមចាប់ផ្តើមសួរបន្តត្រឡប់ទៅអ្វីដែលសួរពីម្សិលមិញ <ពីព្រោះ>ខ្ញុំនៅតែមិនទាន់បានផ្តល់ERNនៅឡើយ ជូនលោកខាងសហព្រះរាជអាជ្ញា។ <ការ>ជំទាស់<ដំបូងមួយក្នុងចំណោមការជំទាស់ជាច្រើនពីខាងសហព្រះរាជាអាជ្ញា គឺទាក់ទងនឹងអ្វីដែលខ្ញុំនិយាយ>ថា កម្មាភិបាលខ្មែរក្រហម២៨នាក់ ត្រូវបានគេសម្លាប់។ ឥឡូវនេះ ខ្ញុំមានចម្លើយនេះជូនលោកហើយ គឺខ្ញុំ<និយាយកាលពីម្សិលមិញ គឺ>ដកស្រង់ចេញពីសៀវភៅរបស់លោក ប៉ែន ឃៀវនិន គឺទំព័រជាអង់គ្លេស<២៦៤>, ERN ជាភាសាអង់គ្លេស <0068636>, ខ្មែរ 00637770, បារាំង 00639033។ “នៅយប់មួយ ជនជាតិចាម បានសម្លាប់កម្មាភិបាលខ្មែរក្រហម<>ចំនួន២៨នាក់ <ដោយប្រើកាំបិទនិងដំបង>។” <ឯកសារនេះបាននិយាយអ៊ីចឹង។> ហើយពីម្សិលមិញ ខ្ញុំក៏ត្រូវបានស្តីបន្ទោសដោយការប្រើប្រាស់របាយការណ៍របស់យូមេនរ៉ៃត៍វ៉ច្ឆ<។ សំណួររបស់ខ្ញុំដែលមានការជំទាស់ គឺទាក់ទងនឹង>កងទ័ពតំបន់២១។ ខ្ញុំសូមរៀប<ពាក្យ>ឡើងវិញ គឺថាកងទ័ព<ដែលពាក់>ឯកសណ្ឋានកងទ័ពផ្សេងៗគ្នា<។> ខ្ញុំ<ពិតជាបាន>យោងទៅលើរបាយការណ៍របស់អង្គការយូមេនរ៉ៃត៍វ៉ច្ឆ<មែន។ ប៉ុន្តែ>របាយ-ការណ៍នេះផ្ទាល់ <បានសរសេរដោយ>យោងទៅលើជើងទំព័រ ដែលជាប្រភព<ព័ត៌មាននៃចំណុចជាក់លាក់>នេះ។ ហើយប្រភពនៃឯកសារនេះ គឺ<មាន>ប្រភពចេញមកពី<សៀវភៅរបស់> ឧស្មាន នេះផងដែរដែល<មានចំណងជើងថា> “ការបះបោររបស់ជនជាតិចាម”។ ទំព័រអង់គ្លេសគឺលេខ៨៤ ឯក-សារនេះគឺ E3/2653។ សៀវភៅ<ទាំងមូល>នេះមាន<នៅលើអ៊ីនធឺណែត។> ERN ជាភាសាអង់គ្លេសនោះគឺ 00219145 ដែលសរសេរថា៖ “នៅម៉ោងប្រាំបួន ខ្ញុំបានឃើញកងទ័ព<បន្ថែមរាប់រយ>នាក់ទើបមកដល់ ហើយស្លៀកពាក់ឯកសណ្ឋានផ្សេងៗគ្នា<ដែលខុសពីឯកសណ្ឋានរបស់>កងទ័ព<>ស្រុក<>។ ពួកគេមានស្ពាយសាក់កាដូ និងមាន<អាវុធគ្រប់ប្រភេទ>។ គេបានប្រើប្រាស់កាំភ្លើងធំតូច<ជាច្រើន> ដើម្បីមកបាញ់<ប្រឆាំងនឹងការបះបោររបស់>ប្រជាជនទាំងនេះ។ <កាណូតរបស់ខ្មែរក្រហមបានបើកមកជិតច្រាំងទន្លេ ហើយបាញ់ជាបន្តបន្ទាប់។”>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:២៦:៣២]

<សុំទោស> ខ្ញុំមិន<ទាន់>បានផ្តល់ ERN ជាភាសាខ្មែរ និងបារាំងឲ្យលោកនៅឡើយដែរ គឺខ្មែរ ERN 00221854, បារាំង 00293925។ "កងទ័ពហ្នឹង គឺស្លៀកពាក់ឯកសណ្ឋានផ្សេងៗគ្នា <ដែលខុសពីឯកសណ្ឋានរបស់>កងទ័ព<>ស្រុក" <នេះគឺមាននៅក្នុងសៀវភៅរបស់ ឧស្មាន>។ ហើយពីម្សិលមិញ យើងក៏និយាយអំពីកងវរសេនាតូច៥៥ដែរ ដែលមេបញ្ជាការ<ម្នាក់> គឺ<លោក> នាយករដ្ឋមន្ត្រី ហ៊ុន សែន។ ខ្ញុំបានផ្ញើឯកសារនេះ<ជូនលោកប្រធាន>តាមអ៊ីម៉ែល<កាលពីព្រឹកមិញ> គឺឯកសារ E3/5261 ជា<កំណត់ហេតុស្តាប់ចម្លើយរបស់យុទ្ធជននៃកងវរសេនាតូចលេខ៥៥។ គាត់> និយាយអំពីការ<បង្ក្រាបលើការបះបោររបស់ជនជាតិចាម នៅត្រង់ទំព័រជាភាសាអង់គ្លេស 0027-- ខ្ញុំបានឮថាមិនមានការបកប្រែជាភាសាខ្មែរ>។ ខ្ញុំនឹងចាប់ផ្តើមម្តងទៀត ឯកសារ E3/5261, ERN ជាភាសាអង់គ្លេស 00274336 ហើយ<មកដល់ឥឡូវ>នេះ ខ្ញុំមាន<តែ> ERN ជាភាសាបារាំង 00285329 ដែលសរសេរថា៖ "<កងវរសេនាតូចលេខ>៥៥ បាន<រៀបចំការ>បង្ក្រាបការបះបោរ <របស់ជនជាតិចាមនៅឃុំទ្រា ឃុំស្វាយឃ្លាំង>--

**ប្រធានអង្គជំនុំ៖**

លោកៗ អាចផ្តល់ ERN ជាភាសាខ្មែរ ដូចមិនទាន់ផ្តល់ឲ្យទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងផ្តល់ជូននៅពេលក្រោយនេះ បន្តិចលោកប្រធាន។ <ប្រហែល>មួយនាទីទេ<នឹង>រកឃើញហើយ<។ ឯកសារនេះបាននិយាយ>ថា "<ការបះបោររបស់>ប្រជាជនចាមត្រូវបាន<បង្ក្រាបដោយកង>វរសេនាតូច៥៥ហ្នឹង បង្ក្រាបនៅឃុំទ្រា នៅឃុំស្វាយឃ្លាំង ហើយនិងនៅកោះផល។ កន្លែងទាំងបីនេះ គឺថាត្រូវបានបង្ក្រាបនៅពេលតែមួយ។" ទំព័រខាងក្រោមមួយទៀត ខ្ញុំ<>មានERN ជាភាសាខ្មែរ<និងភាសាអង់គ្លេសសម្រាប់ឯកសារនេះ គឺ>អង់គ្លេស 00274338, បារាំង 00285332 ហើយខ្មែរ 00250945។ សាក្សីនោះ <ត្រូវ>បាន<គេ>សួរអំពី ហ៊ុន សែន<។ គាត់បាននិយាយថា ខ្ញុំសូម> ដកស្រង់៖ "បន្ទាប់ពីគាត់របួសភ្នែក គាត់ឡើងទទួលបន្ទុកក្តោបក្តាប់នៅតំបន់២១ ក្នុងនាមជាសេនាធិការរបស់<កង>វរសេនា<ធំ-ង។ យុន សុភី គឺជាប្រធាននៃសេនាធិការកងវរសេនាតូច-ឃ>ដែលទទួលបញ្ជាពី<សេនាធិការនៃកង>វរសេនាធំនេះតែម្តង។" <ដូច្នេះសំណួរនេះ ខ្ញុំសួរកាលពីម្សិលមិញ រួចហើយ។> ឥឡូវនេះ ខ្ញុំ<នឹង>មិន<>សួរទៅសាក្សី<ទាក់ទងនឹងរបាយការណ៍យូមេនរ៉េត៍វ៉ិទ្ធទេ បើសិន

នេះជាអ្វីដែលលោកប្រធានប្រាប់ឲ្យយើងធ្វើនោះ>។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

[០៩:៣០:៣៣]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកមេធាវីដែលផ្ដល់ ERN<។ យើងប្រហែលជាមិនមានបញ្ហាទេ បើសិន ERN នេះត្រូវ>បានផ្ដល់<ជូនតាំង>ពីម្សិលមិញ។ ខ្ញុំគ្រាន់ចង់បញ្ជាក់<ដើម្បីឲ្យកំណត់ត្រាមានភាព>ច្បាស់<លាស់>នៅលើឯកសារមួយចំនួន<ដែលលោកមេធាវីទើបតែបង្ហាញ។> ទាក់ទងទៅនឹងឯកសារយោងរបស់ ប៉ែន យៀរនិន និយាយពីកម្មាភិបាលខ្មែរក្រហម<២៨>នាក់ដែលត្រូវបានគេសម្លាប់ហ្នឹង គឺគេនិយាយអំពីទីតាំងផ្សេងៗ និងពេលវេលាផ្សេងៗ<ខុសពីព្រឹត្តការណ៍ទាំងប៉ុន្មានដែលយើងកំពុងតែនិយាយ>។ កថាខណ្ឌខាងលើ <ដែល>និយាយពីស្វាយឃ្លាំង<ជាឧទាហរណ៍ ឯកសារនេះបាននិយាយ>ថា អ្នកភូមិ<ដែលកាន់ផ្កាក់បាន>សម្លាប់កម្មាភិបាល<បក្សកុម្មុយនីស្ត>ម្នាក់ និងកងទ័ពខ្មែរក្រហមពីរនាក់។ ដូច្នេះ<កំណត់ត្រាគួរតែបញ្ជាក់ឲ្យច្បាស់ថា ការសម្លាប់២៨នាក់ដែលបានរាយការណ៍មុននេះ គឺ>ខុសពីអ្វីដែល<ពិភាក្សាដេញដោលនៅក្នុងដំណើរការនីតិវិធី>នេះ<>។

ទី២ ខ្ញុំត្រេកអរណាស់ដែលថា មេធាវីការពារក្ដីបានលើកឡើងនូវកិច្ចសម្ភាសន៍របស់សហចៅក្រមស៊ើបអង្កេតជាមួយកម្មាភិបាល<ម្នាក់>ដែលធ្វើការនៅ<កង>វរសេនាតូច៥៥។ <ផ្ទុយពីអ្វីដែលគាត់បានប្រាប់កាលពីម្សិលមិញ គឺថាតុលាការនេះមិនបាន>បិទភ្នែក ធ្វើមិនដឹងមិនឮរឿងនោះទេ<ហើយបុគ្គលជាក់លាក់ម្នាក់ត្រូវបានសម្ភាសទាក់ទងនឹងរឿងនេះ>។ <លោកមេធាវី គឺត្រឹមត្រូវហើយ។> កម្មាភិបាលរូបនេះ<ដែលធ្វើការនៅក្នុងមន្ទីរនេះ>បានបញ្ជាក់<>ថា<កង>វរសេនាតូចលេខ៥៥<ត្រូវ>បានបញ្ជូន<ទៅឲ្យចូលរួមក្នុងការបង្ក្រាបនេះ>មែន ប៉ុន្តែ<អ្វីដែល>មេធាវីការពារក្ដីមិន<ទាន់>បានបញ្ជាក់<នោះគឺ> កម្មាភិបាលនោះមិនបានឆ្លើយបញ្ជាក់<ពី>មេបញ្ជាការ<កងវរសេនាតូចនៅពេលនោះថា>ឈ្មោះ សុខ សាធ នេះមិនមែនឈ្មោះ ហ៊ុន សែន នេះទេ <គឺ>ឈ្មោះ សុខ សាធ ទេ។ ហើយ<>គាត់ឆ្លើយថា<នៅពេលនោះ> ហ៊ុន សែន គឺគាត់ទទួលខុសត្រូវក្នុង<ផ្នែកឈ្លបយកការណ៍ដែលមាន>យុទ្ធជន៣០នាក់តែប៉ុណ្ណោះ <ហើយក្រោយមក គាត់មានតួនាទីផ្សេងទៀត>។ ដូច្នេះ យើង

មិនជំទាស់ជាមួយមេធាវីការពារក្តី<ក្នុង>ការសួរ<សាក្សីទាំងឡាយទាក់ទង>នឹងបញ្ហាទាំងអស់នេះទេ <ដែលមេធាវីការពារក្តីបានប្រើប្រាស់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ហើយគាត់បានរៀបរាប់ពីភស្តុតាងនេះបានយ៉ាងត្រឹមត្រូវ>។ <ឥឡូវនេះ> ខ្ញុំមិនចង់ចំណាយពេលច្រើនពេកទេ លោកប្រធាន តែខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យបានច្បាស់ចំពោះសម្រាប់ប្រតិចារឹក។

[០៩:៣២:៤៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំ<គិត>ថា បើសិនណាជាយើងអានប្រតិចារឹកកាលពីម្សិលមិញ ប្រហែលជាល្អជាង <ពីព្រោះកាលពី>ម្សិលមិញ<សហព្រះរាជអាជ្ញាហាក់ដូចជា>មិនបាន<ដឹងអំ>ពី<កង>វរសេនាតូច៥៥ <និងឯកសណ្ឋានកងទ័ព>នោះទេ។ <ខ្ញុំមិនគិតថា ការដកស្រង់នេះគឺត្រឹមត្រូវទេ ហើយចំពោះតួលេខ២៨នោះក៏ដូចគ្នាដែរ។> ហើយនៅក្នុងកថាខណ្ឌខាងក្រោមមកទៀតនេះ គឺនិយាយអំពីកោះផល ដែលថាកម្មាភិបាលខ្មែរក្រហម២៨នាក់ ត្រូវបានសម្លាប់ដោយកាំបិត <ហើយនិងដំបង ដូច្នេះខ្ញុំមិនច្បាស់ថាហេតុអ្វីបានជាថាវាមិនជាប់ពាក់ព័ន្ធអ្វីសោះជាមួយនឹងការបះបោរ។> នេះ<ជា>ជំពូក<មួយដែល>និយាយអំពីការបះបោរ តែមិនថ្មីទេ ខ្ញុំបន្តទៅមុខទៀត <លោកប្រធាន>។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនតូចសួរទៅកាន់លោក។ ដំបូងខ្ញុំសូមសួរលោក <ពីរយៈពេលមុន> "ខ្មែរក្រហមបានចូលមកតំបន់របស់<លោក>"។ តើ<លោក>មាន<គ្រួសារ>ចាម<ដែល>រស់នៅៗកំពង់ឆ្នាំង ពោធិ៍សាត់ តាកែវ ឬក៏កំពតដែរទេ?

**លោក សុះ ពន់យ៉ាមីន៖**

**ឆ៖** សំណួរនេះ ខ្ញុំអត់យល់ ខ្ញុំមិនអាចឆ្លើយបានទេ។ ឥឡូវសូមបញ្ជាក់សំណួរម្តងទៀត។

**ស៖** ខ្ញុំរៀបចំសំណួរឡើងវិញ។ តើលោក<ដឹង>ថា<តើ>នៅដើមទសវត្សរ៍១៩៧០ មានចាម<ជាច្រើន>រស់នៅកំពង់ឆ្នាំង ពោធិ៍សាត់ តាកែវ និងកំពតដែរឬទេ<>?

**ឆ៖** ចាម ខ្ញុំដឹងថា នៅគ្រប់ខេត្ត ហើយខេត្តដែលលោកមេធាវីរាប់ទាំងអស់នោះ ខ្ញុំជឿជាក់ថាចាមរស់នៅមិនមែនត្រឹមរបបនោះទេ រស់នៅជាយូរលង់មកហើយ។

[០៩:៣៥:២៣]

**សះ** តើត្រឹមត្រូវដែរឬទេលោក ដែលថាក្រោយពីរដ្ឋប្រហារឆ្នាំ១៩៧០ ជនជាតិចាមជាច្រើនបានក្លាយទៅជាជនបដិវត្តន៍ ដើម្បីចូលរួមជាមួយចលនាបដិវត្តន៍ប្រឆាំងនឹងរបប លន់ នល់?

**ផះ** ខ្ញុំសុំឆ្លើយថា ធម្មតាយើងជាប្រជាជនរស់នៅក្រោមដំបូលប្រទេសមួយ អ៊ីចឹងប្រទេសត្រូវការ ជាតិត្រូវការ ដាច់ខាតត្រូវតែទៅបម្រើជាតិ។ អ៊ីចឹងយើងមិននឹកស្មានថា របបនោះវាទៅជារបបប្រល័យពូជសាសន៍ វាទៅជារបបបំផ្លាញជាតិទេ។ អ៊ីចឹងដាច់ខាត សូម្បីតែជំនាន់ណាក៏ដោយក៏ជនជាតិចាមខ្ញុំចូលរួមដើម្បីក្នុងនាមកសាងប្រទេស ការពារប្រទេសដែរ។ របបសព្វថ្ងៃនេះ របប លន់ នល់ របបសម្តេច នរោត្តម សីហនុ ដាច់ខាត ព្រោះខ្ញុំ ជនជាតិចាមខ្ញុំ គេទុកជាជាតិខ្មែរតែមួយ។ អ៊ីចឹងខ្ញុំត្រេកអរណាស់ បានគេទទួលស្គាល់ ហើយគេស្រឡាញ់។ អ៊ីចឹងរឿងអីដែលប្រជាជនចាមខ្ញុំជួយការពារជាតិ ដោយសារគ្រប់ជំនាន់ ដាច់ខាតត្រូវតែរួមចំណែកការពារជាតិ ហើយនិងកសាងជាតិ។

**សះ** តើត្រឹមត្រូវដែរទេថា មនុស្សម្នាក់ឈ្មោះ សុះ ម៉ាន មានតួនាទីមួយសំខាន់នៅក្នុងការបញ្ចុះបញ្ចូលជនជាតិចាមឲ្យចូលរួមជាមួយ<>ចលនាបះបោរនេះ?

**ផះ** ខ្ញុំមិនស្គាល់ សុះ ម៉ាន ដូចអត់មានស្គាល់ទេខ្ញុំ។

**សះ** ប្រហែលជាលោកអាចស្គាល់កូនរបស់គាត់<។ តើលោកស្គាល់មនុស្សម្នាក់>ឈ្មោះ<ថា> ម៉ាត់ លី <ដែរ>ឬអត់?

**ផះ** ខ្ញុំគ្រាន់តែឮឈ្មោះ ខ្ញុំមិនដែលស្គាល់ ហើយគាត់ក៏មិនដែលស្គាល់ខ្ញុំដែរ។

**សះ** ចុះលោកធ្លាប់ឮ<>រណសិរ្សចាមនៅភូមិភាគបូព៌ាទេ?

**ផះ** ខ្ញុំមិនដែលឮទេ។

[០៩:៣៨:២៨]

**សះ** តើត្រឹមត្រូវដែរឬទេថា <>មាន<ប្រាំ> ឬក៏ប្រាំ<មួយ>ភូមិចំណុះឲ្យឃុំស្វាយឃ្លាំងត្រឹមត្រូវទេ?

**ផះ** សូមបញ្ជាក់លោកមេធាវី សួរឲ្យវាបានច្បាស់ ហើយអានឲ្យវាបានភូមិអីៗ តែស្រែឃ្លាំងៗខ្ញុំស្តាប់អត់បាន ខ្ញុំឆ្លើយទៅយ៉ាងម៉េច។

**សះ** សំណួរខ្ញុំសួរថា តើស្វាយឃ្លាំងហ្នឹងមានភូមិដាច់ៗៗពីគ្នាហ្នឹង ចំណុះឲ្យស្វាយឃ្លាំងតែម្តងប្រាំទៅប្រាំមួយភូមិមែនទេ?

**ផះ** បាទ ត្រឹមត្រូវ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើលោកដឹង<ទេ>ថា<តើ>មេដែលត្រូវបាន<តែងតាំងដោយ> "ខ្មែរក្រហម<ក្រោយ> ឆ្នាំ៧១ ឬក៏<ក្រោយឆ្នាំ>៧៣" <>សុទ្ធតែជាជនជាតិចាម<មែនដែរឬ>ទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ។ ហើយតាមខ្ញុំដឹង វាមិនមែនដូច្នោះទេ។

**ស៖** ឥឡូវនេះខ្ញុំកម្រិតសួរតែចំពោះភូមិលោកផ្ទាល់តែម្ដង គឺភូមិលេខ៥។ ខ្ញុំជឿជាក់ថាអ៊ីចឹង។ ពីម្សិលមិញលោកនិយាយពីមនុស្សម្នាក់ឈ្មោះ កៅ។ ខ្ញុំមិនដឹងថាខ្ញុំយល់ច្បាស់ ឬក៏អត់ទេ ប៉ុន្តែ កៅ នេះ ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាប្រធាន។ លោកដឹងទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** គាត់ជាជនជាតិចាមដែរឬក៏អត់ទេ?

**ឆ៖** គាត់ជាចាម។

[០៩:៤០:៥៤]

**ស៖** តើគាត់មានបានចូលរួមពាក់ព័ន្ធក្នុងការដាក់វិធានការ<>ហាមឃាត់ការគោរពប្រតិបត្តិសាសនារបស់លោកទេ?

**ឆ៖** នេះជាគោលការណ៍។ ខ្ញុំចង់បញ្ជាក់ថា ជាស្ថាប័នរបស់ខ្មែរក្រហម។ អ៊ីចឹងគោលការណ៍អ្វីធ្លាក់ពីលើមក អ៊ីចឹងយើងមិនអាចប្រកែកបាន។ យើងយល់ពីសភាពការណ៍ យើងយល់ពីមនោសញ្ចេតនា អ្វីទាំងអស់។ បើសិនជាគ្នាមិនធ្វើ ហើយតាមខ្ញុំបញ្ជាក់ឲ្យច្បាស់ ឈ្មោះ កៅ ឬក៏ប្រធានភូមិដទៃទៀត អត់មានធ្វើសកម្មភាពឃាតករ ឬក៏សម្លាប់អីទេ។ អ៊ីចឹងគ្រាន់តែសកម្មភាពការដឹកនាំនៅក្នុងភូមិហ្នឹងតែប៉ុណ្ណឹង។

**ស៖** នៅក្នុងឆ្នាំ១៩៧៣, ៧៤ លោកស្គាល់ កៅ នេះច្បាស់ទេ? លោកធ្លាប់និយាយជាមួយគាត់ទេ?

**ឆ៖** ខ្ញុំស្គាល់ច្បាស់ ហើយក៏ខ្ញុំធ្លាប់និយាយជាមួយគាត់។

**ស៖** តើលោកធ្លាប់ដែលសួរគាត់ថា ហេតុអ្វីបានជា<គាត់>អនុវត្តគោលការណ៍<ហាមឃាត់> មិនឲ្យគោរពប្រតិបត្តិសាសនា<ចាមដែលជាសាសនាខ្លួនឯង>អ៊ីចឹង?<ឬបើតាមសែស្រឡាយទាំងនោះតើគាត់ខ្លួនឯងផ្ទាល់ជាជនជាតិចាមទេ?>

**ឆ៖** ខ្ញុំមិនដែលទៅនិយាយសួរគាត់លើបញ្ហាហ្នឹងទេ ព្រោះខ្ញុំយល់ថាគាត់ហ្នឹងសម្រាប់គេប្រើតូចតាច។ អ៊ីចឹងគោលការណ៍ខ្ញុំចង់ជម្រាបថា គោលការណ៍ធំៗដើម្បីហាមឃាត់ពីបញ្ហាសិទ្ធិ សេរីភាព

សាសនា ឬក៏អ្វីផ្សេងទៀតហ្នឹង មិនមែនគោលការណ៍ត្រឹមប្រធានភូមិមកផ្សព្វផ្សាយទេ គោលការណ៍មានថ្នាក់ស្រុក ថ្នាក់អី គេចុះមកប្រជុំ។ អ៊ីចឹងប្រធានភូមិ ប្រធានអីអត់មានលទ្ធភាពទៅផ្សព្វផ្សាយទេ។ ថាអ៊ីចឹង មានថ្នាក់លើៗគេចុះមកប្រជុំ។

[០៩:៤៣:៣៨]

**ស៖** ឥឡូវកម្រិតសួរតែត្រឹមភូមិលោកតែប៉ុណ្ណោះបានហើយ។ តើមានខ្មែរក្រហមជាជនជាតិចាមដែលជួយធ្វើការ កៅ ដែរទេ ជួយដល់តួនាទីរបស់ កៅ នេះដែរទេ?

**ឆ៖** អត់មានទេ។

**ស៖** តើ កៅ ជាកម្មាភិបាល<ខ្មែរក្រហម>តែម្នាក់គត់នៅក្នុងភូមិរបស់លោក<នៅ>ចន្លោះពីឆ្នាំ៧៣ ទៅដល់៧៥ អ៊ីចឹងមែនទេ?

**ឆ៖** វាមានបន្ទាប់ៗគាត់ដែរ។

**ស៖** ឥឡូវនេះខ្ញុំសួរទៅលោក ពីមនុស្សម្នាក់ឈ្មោះ ម៉ាត លី ដែលខ្ញុំទើបសួរមុននេះ តើលោកធ្លាប់ឮអំពីតួនាទីរបស់ ម៉ាត់ លី នៅក្នុងរដ្ឋសភានៅក្នុងឆ្នាំ១៩៧៦ដែរទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ ព្រោះខ្ញុំមិនអាចដឹងថា ភារកិច្ច តួនាទីរដ្ឋសភា ឬក៏មន្ត្រីធំៗអីគេម៉េចម៉ា ខ្ញុំមិនដឹងផង។ ខ្ញុំដឹងថា គ្រាន់តែឮឈ្មោះគាត់ តែខ្ញុំមិនដឹងថាគាត់ធ្វើអី ខ្ញុំអត់ដឹងទេ ព្រោះកាលហ្នឹងខ្ញុំជាប្រជាជនសាមញ្ញមួយរូប។

**ស៖** ឥឡូវនេះគឺអ៊ីចេះ លោកដើមបណ្តឹងរដ្ឋប្បវេណី <ខ្ញុំគិតថា នៅពេលនោះ> ស្វាយឃ្លាំងគឺ<>ជាផ្នែកមួយនៃស្រុក។ លោកដឹងថា ស្វាយឃ្លាំងជាចំណុះឲ្យស្រុក<មួយ>ណាដែរ<>?

**ឆ៖** ចំណុះឲ្យស្រុកក្រូចឆ្មារ។

**ស៖** ហើយតើលោកដឹង<ថា> ស្រុកក្រូចឆ្មារនេះ ចំណុះឲ្យអង្គភាព <ឬ>ចំណុះឲ្យថ្នាក់ណា<ដែលខ្ពស់ជាងស្រុកក្រូចឆ្មារទៀត>?

[០៩:៤៦:២១]

**ឆ៖** ខ្ញុំអត់ដឹង។

**ស៖** តើលោកធ្លាប់ដែលឮសួរ<កន្លែងមួយ>ឈ្មោះ<>ពាមជីលាំងទេ?

**ឆ៖** ភូមិពាមជីលាំង ខ្ញុំមិនឮសួរទេ ខ្ញុំស្គាល់ ហើយខ្ញុំធ្លាប់នៅកន្លែងនុ៎ងទៀត។

**ស៖** តើលោកហៅវាថាជាភូមិ? ហើយតើពាមជីលាំងនេះ គឺមានឃុំពីរ<ទៀត>នៅក្នុងស្រុក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្រូចឆ្មារ លោកដឹងដែរទេ?

**ឆ៖** តាមខ្ញុំដឹង ពាមជីលាំងមិនមែននៅស្រុកក្រូចឆ្មារទេ នៅស្រុកត្បូងឃ្មុំទេ។ ឃុំកំពង់ទ្រាស ទេ ទើបនៅស្រុកក្រូចឆ្មារ។ អ៊ីចឹងចែកម្នាក់ មួយខាងព្រែក ព្រែកពាមជីលាំង។

**ស៖** បាទ មិនថ្វីទេ។ លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកដឹងថា ស្រុកដែលលោករស់នៅនោះ គឺជាស្រុកមួយចំណុះឲ្យតំបន់មួយធំ គេហៅថាតំបន់២១ លោកដឹងទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេ ព្រោះកាល គេហៅតំបន់ស៊ីហ្នឹង របបខ្មែរក្រហម គេហៅតំបន់ហ្នឹង។ អ៊ីចឹងខ្ញុំមិនអាចយល់បានថា នៅក្នុងរបបខ្មែរក្រហម គេហៅថាតំបន់២១, ២២, ២០គត់អី គេចែកខណ្ឌ ខាងណាខាងណី ខ្ញុំអត់ដឹងទេ ខ្ញុំអត់ដឹង ព្រោះខ្ញុំមិនអាចមានលទ្ធភាពទៅគិតគូរដល់ថ្នាក់ប៉ុណ្ណឹងទេ ព្រោះខ្ញុំជាប្រជាជនសាមញ្ញម្នាក់។

**ស៖** ឥឡូវខ្ញុំសូមសួរតាមរបៀបផ្សេងវិញ។ លោកមានដឹងថា មានថ្នាក់ណាខ្ពស់ជាងស្រុកទេ <គឺថាថ្នាក់ខ្ពស់>ដែលថ្នាក់ស្រុកត្រូវតែ<ស្ដាប់និង>គោរពតាមការបញ្ជាណាមួយនោះ លោកដឹងទេ?

[០៩:៤៩:១៤]

**ឆ៖** ខ្ញុំសូមនិយាយថា មន្ត្រីស្ថាប័នខ្មែរក្រហម ខ្ញុំមិនអាចយល់បាន ព្រោះគេមានថ្នាក់តំបន់ផង ថ្នាក់ស្រុកផង ថ្នាក់ខេត្តផង ថ្នាក់ភាគផង មិនមែនដូចសព្វថ្ងៃហ្នឹងថា បើថាស្រុកច្បាស់ស្រុក ខេត្ត ច្បាស់ខេត្ត ខ្ញុំៗយល់បាន។ អានេះវាៗ ខ្ញុំយល់អត់បាន កាលនុ៎ងខ្ញុំវានៅក្មេង នៅវ័យក្មេងផង វាមិន អាចចាប់អារម្មណ៍លើបញ្ហាហ្នឹងទេ។ អ៊ីចឹងខ្ញុំបានន័យថា ខ្ញុំអត់ដឹងទេ។

**ស៖** មានពេលមួយនៅខែកក្កដា ១៩៧៥ ពីរឬក៏បីខែ <ក្រោយ>ពេលរំដោះភ្នំពេញ និងកំពង់ចាម<> មនុស្ស<ទី២ ក្នុងតំបន់២១>ឈ្មោះ អ៊ុក ប៊ុនឈឿន។ បើខ្ញុំនិយាយពីឈ្មោះ អ៊ុក ប៊ុនឈឿន តើលោកស្គាល់ទេ <ឬ>នឹកឃើញទេ?

**ឆ៖** អត់ទេ ព្រោះគេថ្នាក់ធំៗ ខ្ញុំមិនអាចស្គាល់ទេ ដូចខ្ញុំជម្រាបអំមិញ។ អ៊ីចឹងកម្រិតធំៗ ខ្ញុំ បើ លោកមេធាវីសួរខ្ញុំ ក៏គ្មានប្រយោជន៍អីដែរ ព្រោះខ្ញុំកាលហ្នឹងអត់មានលទ្ធភាពទៅស្គាល់គេថ្នាក់ភូមិភាគ ថ្នាក់តំបន់អី ខ្ញុំអត់ស្គាល់ទេ។ អ៊ីចឹងសូម្បីតែមួយភូមិខ្ញុំ ខ្ញុំស្គាល់មិនទាំងអស់ផង។

**ស៖** <ការដែលលោក>និយាយ<ថាមិនបាន>ស្គាល់មនុស្ស<>ហ្នឹងវាជារឿងមួយហើយ ប៉ុន្តែលោកប្រហែលជាអាចស្គាល់កងទ័ពមកពីផ្នែកផ្សេងៗគ្នា។ តើលោកមានដឹងថា មានការញែកដាច់ ពីគ្នារវាងកងទ័ពស្រុក និងកងទ័ពតំបន់ ឬក៏កងទ័ពថ្នាក់លើទេ? <>

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៥១:៤៧]

**ឆ៖** ខ្ញុំសូមនិយាយថា ខ្ញុំសួរទៅលោកថា ខ្ញុំមិនមែនកងទ័ព តើកងទ័ព និងប្រជាជន ច្បាប់វាខុសគ្នាយ៉ាងម៉េច គោលការណ៍វាខុសគ្នាយ៉ាងម៉េច។ អ៊ីចឹងឲ្យខ្ញុំទៅដឹងពីកងទ័ព ខ្ញុំសម្រាប់ប្រជាជនសាមញ្ញមួយរូបហ្នឹង តើខ្ញុំអត់មានលទ្ធភាពដឹងដែរ កងទ័ពស្រុកផង ទ័ពស្អី កងពល កងស្អី ខ្ញុំទៅដឹងអី--

**ប្រធានអង្គជំនុំ៖**

លោកៗ ដើមបណ្តឹងរដ្ឋប្បវេណី លោកមាន ព្រោះលោកផ្តល់សក្ខីកម្ម លោកអាចឆ្លើយ ការដែលលោកឆ្លើយថាមិនដឹង ក៏ជាចម្លើយដែរ។ ខ្លីៗ កន្លែងណាដែលលោកមិនដឹង គឺលោកឆ្លើយថាមិនដឹងទៅ ខ្លី។ យើងយល់ហើយនូវគោលបំណងនៃការសួរ ហើយនិងរបៀបដែលលោកឆ្លើយ ព្រោះលោកបានឆ្លើយ លោកមិនដឹងទេ។ លោកមិនដឹងតាំងពីចំណុះ តាំងពីថ្នាក់លើអីណាផង ប៉ុន្តែមេធាវី គេព្យាយាមសួរក្នុងទិសដៅដែលគេចង់បាន។ ប៉ុន្តែគឺគ្រាន់តែបញ្ជាក់ នីតិវិធីនៅចំពោះមុខតុលាការ ការដែលឆ្លើយមិនដឹង ក៏ជាចម្លើយដែរ ព្រោះគុណភាពរបស់លោកជាគោលដៅដែលត្រូវឆ្លើយ មិនមែនគោលដៅសួរគេទេ។ លោកអាចសួរទៅជាប់ចោទបាននៅចុងក្រោយតាមរយៈប្រធាន គឺរូបយើងជាប្រធានអង្គជំនុំជម្រះក្នុងការបញ្ជូនចម្លើយនោះ ទៅគោលដៅដែលលោកឆ្លើយ -- លោកដែលត្រូវឆ្លើយគឺជនជាប់ចោទប៉ុណ្ណោះ។ បាទ ដើម្បីឲ្យច្បាស់លាស់លើនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ ចៀសវាងការជជែកថាផ្សេងៗ។ អង្គជំនុំជម្រះ និងភាគីដទៃទៀតនឹងផ្ចិតផ្ចង់ស្តាប់បញ្ហានេះ ថាគួរតែដោះស្រាយបញ្ហានុ៎ងយ៉ាងដូចម្តេច។ យើងសាកល្បង ព្រោះចម្លើយដែលយើងបានកត់ត្រានេះ គឺលោកបានឆ្លើយថាមិនច្រើនហើយ ប៉ុន្តែយើងចម្លែកដែរ នៅពេលដែលលោកឆ្លើយថាមិនដឹងហើយ គេព្យាយាមនៅសួរផ្សេងៗទៀត។ យើងដឹងអំពីគោលដៅនៃបំណងនៃការសួរ ប៉ុន្តែនេះជាសិទ្ធិរបស់គេ រហូតដល់មួយយើងនឹងថាចាត់ការយ៉ាងដូចម្តេចលើបញ្ហានេះ បាទ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <លោកដើម្បីបណ្តឹងរដ្ឋប្បវេណី ខ្ញុំនឹងនិយាយត្រង់ៗជាមួយលោកបន្តិច។> ខ្ញុំភ្ញាក់ផ្អើលណាស់ ដែលលោកមិនដឹងបែបនេះ។ កាលពីម្សិលមិញ លោកបាននិយាយយ៉ាងច្រើនថា លោកបានចូលរួមនៅក្នុងការបះបោរ ហើយមានការវាយប្រយុទ្ធគ្នា មានការបាញ់កាំភ្លើងធំជាដើម។ ដូច្នេះខ្ញុំគិតថា លោកបានឃើញពួកទាហាន<។> អ៊ីចឹងហើយបានជាខ្ញុំសួរលោកជាលក្ខណៈទូទៅពាក់ព័ន្ធទៅនឹងការបះបោរនោះ។ <នៅពេលដែលការបះបោរកើតឡើងខ្លាំង> តើលោកមានឃើញកងទ័ព<ដែល>មាន

អាវុធផ្សេងៗ មានឯកសណ្ឋានផ្សេងៗគ្នាចម្រុះ ហើយមាន<>អាកប្បកិរិយាហ្នឹងខុស<ៗ>ពីគ្នាទេ?

[០៩:៥៥:០០]

**លោក សុះ ពន់យ៉ាមីន៖**

**ឆ៖** ខ្ញុំអត់បានឃើញទេ។ ធម្មតាបាញ់គ្នា យើងទៅបង្ហាញមុខមើលគេហ្នឹង គេបាត់យើងហើយ។ អីចឹងបានអត់បានឃើញទេ។ គេចតែគ្រាប់កាំភ្លើងទេ អត់មានទៅគិតអារឿងឃើញមនុស្សយ៉ាងម៉េច សម្បុរយ៉ាងម៉េចទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ដើម្បីសាកល្បងភាពជឿជាក់បាននៃសាក្សីនេះ ខ្ញុំសូមអាននូវសម្រង់ឯកសារនៅក្នុងសៀវភៅរបស់ អ៊ីសា ឧស្មាន <ដែលខ្ញុំទើបតែលើកឡើងមុននេះ> ជាភាសាអង់គ្លេសគឺ 00221859, ខ្មែរ 00221854, បារាំងគឺ 00293925 គឺនៅជាភាសាអង់គ្លេស 84។

**ប្រធានអង្គជំនុំ៖**

ឯកសារ E ប៉ុន្មាន លោកប្រាប់តែលេខ ERN ឯកសារអត្តសញ្ញាណឯកសារជាក់លាក់ប៉ុន្មានទៅ?

[០៩:៥៦:២២]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអភ័យទោសលោកប្រធាន ឯកសារនេះគឺជាសៀវភៅរបស់លោក អ៊ីសា ឧស្មាន ដែលមានចំណងជើងថា "ការបះបោររបស់ជនជាតិចាម" គឺ E3/7675។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមអាននូវសម្រង់ ហើយខ្ញុំនឹងសូមការឆ្លើយតបរបស់លោក។ "នៅវេលាម៉ោងប្រាំបួន ខ្ញុំឃើញកម្លាំងបន្ថែម<រាប់រយ>នាក់ទើបតែមកដល់ ដែលពាក់ឯក-សណ្ឋានផ្សេងៗគ្នាខុសពីឯកសណ្ឋាណរបស់កងទ័ពស្រុក។ ពួកគេមានស្ពាយសាក់កាដូ ហើយមានអាវុធគ្រប់ប្រភេទ។ ពួកគេបាញ់អាវុធធុនធ្ងន់ធុនស្រាលសំដៅទៅលើពួកអ្នកដែលបះបោរ។" ហើយ<>កាណូតរបស់ទាហានខ្មែរក្រហមជិះមក<ជិតច្រាំងទន្លេ ហើយបន្តបាញ់ជាបន្តបន្ទាប់>ផងដែរ។ តើលោក<មានប្រតិកម្មយ៉ាងម៉េចដែរ ចំពោះ>ចម្លើយ<របស់អ្នកដែលបាននៅកន្លែងកើតហេតុ ដូចលោកដែរ?>

[០៩:៥៧:៣៨]

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា ចម្លើយនេះមិនដឹង អ៊ីសា ឧស្មាន យកចម្លើយពីណា។ សូមបញ្ជាក់ថា អ៊ីចឹងបានខ្ញុំមិនចង់និយាយច្រើនទេ។ ខ្ញុំថា ខ្ញុំអត់ដឹងៗ ប៉ុន្តែលោកនៅតែដដឹកសួរខ្ញុំថែមទៀត ព្រោះដឹងពីមូលហេតុ ម៉ោងប្រាំបួនយប់ហ្នឹងៗ ខ្ញុំទៅមើលឃើញសម្បុរ គេពាក់យ៉ាងម៉េចៗឯណា ហើយមិនដឹងប៉ុន្មានអីប៉ុន្មាន ម៉ោងប្រាំបួនយប់ហ្នឹង។ អ៊ីចឹងបះបោរនៅពេលម៉ោងប្រាំបួនយប់។ អ៊ីចឹងកាលណាយើងគួរវិភាគដែរថា ជំនាន់ខ្មែរក្រហមអត់មានអគ្គិសនីដុតតាមផ្លូវអីទេ។ អ៊ីចឹងងងឹតសូន្យ យើងទៅមើលសម្បុរអាវយោធាពាក់យ៉ាងម៉េចៗ ខ្ញុំអត់ដឹងទេ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី កាលពីម្សិលមិញ លោកបានរៀបរាប់<យ៉ាងច្រើន>អំពីតួនាទីរបស់លោកនៅក្នុងការបះបោរ អ៊ីចឹង<បានជា>ខ្ញុំគិតថាលោកប្រហែលជាអាចដឹងអំពីរឿងនេះ។ ខ្ញុំសូមសួរលោកជាលក្ខណៈទូទៅ តាមបទពិសោធន៍របស់លោកដែលចូលរួមក្នុងការបះបោរនោះ តើលោកដឹងទេថា ហេតុអ្វីបានជាមានទាហានខ្មែរក្រហមរាប់រយនាក់ ហើយមានតាំងពីកាណូត <> មានកាំភ្លើងធំ<>ច្រើនបែបនេះ <ដើម្បី>មកបង្ក្រាប<ការបះបោរនេះ>ប៉ុណ្ណឹង ក៏មានទ័ពច្រើនម្លេះ?

**ឆ៖** ខ្ញុំសូមនិយាយថា ខ្ញុំពិបាកចម្លើយ។ មូលហេតុកន្លែងនោះថា លោកដឹងថាប្រជាជនចាមហ្នឹងបះបោរ អ៊ីចឹងគេមកយកកាំភ្លើងយកអី គេមានទាហានមានអី គេមកទប់ទល់។ អាហ្នឹងវាប៉ុណ្ណឹង។

[១០:០០:០៤]

**ស៖** <ប៉ុន្តែពិតប្រាកដហើយ វា>មិនមែនដោយសារតែ<មានកាំភ្លើងអា.កាមួយដើម និងកាំភ្លើងកាប៊ីនតែមួយដើមប៉ុណ្ណោះទេ គឺថាប្រាកដជាមានអាវុធផ្សេងទៀតនៅ>ខាងជនជាតិចាមដែលបះបោរហ្នឹង <តើត្រឹមត្រូវដែរឬទេ>?

**ឆ៖** អានេះជាគោលការណ៍របស់គេ ហៅថាកន្លែងហ្នឹង កន្លែងប្រយុទ្ធគ្នា។ អ៊ីចឹងប្រុង គេមិនមែនសម្រាប់ថា ចាមហ្នឹងមានអាវុធតិចតួច គេអត់នេះទេ អ៊ីចឹងគោលការណ៍គេមកច្បាំងគេ គឺគេមកៗហើយ មានទ័ពមានអី ពាក្យថា ច្បាំងមួយមាត់ មានកំប្លែរបស់គេមកហើយ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី មានរបាយការណ៍ដែលបានបង្ហាញថាជនជាតិចាមប្រហែលជា៥០០នាក់ត្រូវបានសម្លាប់ដោយកងទ័ពខ្មែរក្រហម។ តើលោកមានធ្លាប់ស្តាប់ឮទេថា ក្រោយពី<ការបង្ក្រាប>ការបះបោរមកនោះ <មានមនុស្សស្លាប់ និងរបួសជាច្រើនដែរឬទេ>?

**ឆ៖** ខ្ញុំយល់ថា អាចសមស្របដែរ ក៏ប៉ុន្តែខ្ញុំអត់សន្និដ្ឋានថា ៥០០នាក់ទេ ព្រោះខ្ញុំអត់ដឹង។ ប៉ុន្តែ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចំនួនដូច តាមចំនួនហ្នឹង បើវាលើសក៏លើសតិច ហើយបើខ្វះ ខ្វះតិចដែរ។ តាមៗ វាសម្រាប់ -- គេចាប់ទៅរឿយៗទៅ បាត់ទៅទាល់ដល់ឥឡូវ។ ខ្ញុំមិនសន្និដ្ឋានថា គេសម្លាប់ស្អីទេ ព្រោះខ្ញុំអត់ឃើញនឹងភ្នែកផងហ្នឹង ឃើញតែគេចាប់ទៅទេ។

**ស៖** កាលពីម្សិលមិញ លោកបាននិយាយអំពីការប្រើប្រាស់កាំភ្លើងធំ<និងអាវុធធុនធ្ងន់> ដោយ<កងពលផ្សេងៗ>។ <តើលោកនៅចាំលម្អិតជាងនេះទៀតទេ? តើ>លោកអាចបញ្ជាក់បានទេថាគេបាញ់កាំភ្លើងធំហ្នឹងពេលណា<?> ហើយឈប់បាញ់នៅពេលណា? ហើយរយៈពេលបាញ់ហ្នឹងប្រហែលប៉ុន្មានម៉ោង<?> ហើយមានការបាញ់តបតពីខាងចាមនៅលើកោះ<>វិញទេ?

[១០:០២:៣២]

**ឆ៖** ខ្ញុំសូមឆ្លើយថា គេបាញ់ហ្នឹង ខ្ញុំមិនដឹងកាំភ្លើងហ្នឹង វាប៉ុន្មានអីប៉ុន្មាន ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំមិនអាចមើលឃើញកាំភ្លើង ឬក៏ស្អីទេ។ អ៊ីចឹងរយៈពេលគេបាញ់ហ្នឹង ចាប់ផ្តើមពីប្រយុទ្ធគ្នា ទាល់ឈប់ប្រយុទ្ធ គេឈប់ (ឮមិនច្បាស់)។ គេឈប់ ពេលឈប់ហ្នឹងតែម្តង។

**ស៖** តើលោកដឹងថា ហេតុអីបានជាខ្មែរក្រហមត្រូវប្រើពេលអស់ដល់ទៅបីថ្ងៃឯណោះ ព្រោះថាកងទ័ពខ្មែរក្រហមហ្នឹងមានសុទ្ធតែកាំភ្លើងធំ<ដើម្បី>បាញ់<កម្ទេចការបះបោរ?> ម៉េចក៏ប្រើពេលដល់ទៅបីថ្ងៃ?

**ឆ៖** ខ្ញុំអត់ដឹងថាបីថ្ងៃ ឬក៏នេះទេ តាមខ្ញុំដឹង តែមួយថ្ងៃមួយយប់ប៉ុណ្ណោះទេ។ លោកបានព័ត៌មានពីខាងណាមកថា បីថ្ងៃហ្នឹង ក៏ខ្ញុំសូមបដិសេធដែរ ព្រោះខ្ញុំនៅកន្លែងហ្នឹងផ្ទាល់ អត់មានបីថ្ងៃទេ មួយថ្ងៃមួយយប់ទេ។

**ស៖** ខ្ញុំសូមអាននូវសម្រង់តូចមួយចេញពីសៀវភៅមួយរបស់អ្នកសិក្សាស្រាវជ្រាវ<ម្នាក់ គឺ> ជាសៀវភៅរបស់លោក ប៉ែន ឃៀរនិន លោកប្រធាន។ គឺ E3/1593 គឺទំព័រ២៦៤ ភាសាអង់គ្លេស <00678636>, ភាសាបារាំង 00639033, ខ្មែរ 00637770។ លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំអានសម្រង់នេះជូនលោក ហើយ<ខ្ញុំនឹងសួរអំពីប្រតិកម្ម>របស់លោក៖ "យប់មួយ ចាមបានសម្លាប់ខ្មែរក្រហម២៨នាក់<ដោយកាំបិទ និងដំបង។ នៅក្នុងការបង្ក្រាបនៅពេលក្រោយមក គឺថាចំនួន>ពួកចាម<ដែល>ស្លាប់<និងរបួសមានចំនួន>ច្រើនជាង<ខាងពួកខ្មែរក្រហម>។ ស្អែកឡើង <ពេលព្រឹកព្រលឹម> កងទ័ពខ្មែរក្រហមបានចាប់ជនជាតិចាមចង ហើយនាំយកទៅ<ឆ្ងាយឱ្យស្លាប់នៅកណ្តាលទន្លេ។ ប្រហែលជារាប់រយនាក់បានស្លាប់។ គេដឹកប្រជាជនចាមចេញ ពីរ ឬបីកាណូតជារៀងរាល់ថ្ងៃ។

សូម្បីអ្នកដែលឈឺក៏ត្រូវគេចាប់ដាក់ចូលក្នុងកាណូត> ហើយ<ផ្តួលទម្លាក់>ទឹក<ដែរ>។” តើ<ភាព> សាហាវឃោរឃៅដែលប្រព្រឹត្តឡើងដោយកងទ័ពភូមិភាគបូព៌ានេះ <តើ>លោកធ្លាប់<>ឮទេ?

**លោក ឌេល លីសាក់៖**

លោកប្រធាន <ខ្ញុំសូមជំទាស់>!

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំសូមជំទាស់លោកប្រធាន។ មេធាវី<កំពុងតែ>អានន្ទូវសម្រង់មួយរបស់សាក្សីមួយរូប<ដែលមិនបង្ហាញពីទីកន្លែងដែលត្រូវបាន>រៀបរាប់<នោះ>ទេ។ គាត់មិន<បាន>អាន<ចម្លើយចេញពី>ឃ្លា <ខាងលើទេ គឺថាចេញពីកថាខណ្ឌខាងលើ>ដែលគេនិយាយអំពីការបះបោរនៅស្វាយឃ្លាំង<ដែល> មានព័ត៌មានផ្សេង<ខុសពីអ្វីដែលមេធាវីបានអាន>។ អ៊ីចឹង <ខ្ញុំគិតថា វាមិនសមស្របដែលលោកមេធាវី>អាន<សម្រង់ដែលមិនជាប់ពាក់ព័ន្ធនឹងឃុំស្វាយឃ្លាំង>ហើយ<បែរជាធ្វើមិនដឹងមិនឮព័ត៌មានផ្សេងទៀតដែលនៅក្នុងទំព័រដូចគ្នាដែលនិយាយអំពី>ហេតុការណ៍<ដែលលោក>ដើមបណ្តឹងរដ្ឋប្បវេណី <បានចូលរួមដែរ គឺថាត្រង់នោះមានព័ត៌មានខុសគ្នាតែម្តង។>។

[១០:០៦:៣៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនដឹង<ច្បាស់>ថា ហេតុអីបានជាព្រះរាជអាជ្ញាគាត់ជំទាស់ត្រង់ចំណុចនេះទេ <បើទោះជាខ្ញុំដឹងថាវានឹងកើតឡើង លោកប្រធាន>។ <>យើង<កំពុងតែ>និយាយអំពីភាពសាហាវឃោរឃៅ<ដែលបង្កឡើងដោយ>កងទ័ពភូមិភាគបូព៌ា<ដែលអាចរួមបញ្ចូលទាំងនាយករដ្ឋមន្ត្រីនៃប្រទេសនេះហើយនិងសមាជិកព្រឹទ្ធសភាផងដែរ។ ដូច្នេះ>ខ្ញុំគិតថា សំណួរ<ដែលខ្ញុំសួរនេះគឺ>ជាសំណួរសមស្របហើយ ក៏ប៉ុន្តែខ្ញុំអាចសួរសំណួរ<បែបអព្យាក្រឹត្យជាងនេះ> ប្រសិនបើលោកប្រធានចង់ឲ្យខ្ញុំធ្វើបែបនេះនោះ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំមិនជំទាស់<ចំពោះលោកមេធាវីដែល>សួរសំណួរពាក់ព័ន្ធនឹងប្រធានបទ<នេះ

ទេ>។ <ប៉ុន្តែ>គាត់<គួរតែ>ដកស្រង់សម្រង់<ទាំងឡាយដែល>ពាក់ព័ន្ធនឹងប្រធានបទដែល<សាក្សីរូបនេះកំពុងតែផ្តល់សក្ខីកម្ម>។

**លោក វ៉ិចទ័រ កូប៉េ៖**

<ជាថ្មីម្តងទៀត> លោកប្រធាន <ឯកសារទាំងនេះ>គឺលោក ប៉ែន យៀវនិន គាត់បានរៀបរាប់អំពីការបះបោររបស់ចាម<មិនត្រឹមតែ>នៅស្វាយឃ្លាំង <ប៉ុន្តែក៏មាន>នៅ<ភូមិ>ទ្រា ហើយនិងនៅកោះផល។ <នេះគឺជាផ្នែកទាំងអស់នៃការបង្ក្រាបដូចគ្នាដែលមេបញ្ជាការរូបនេះបាននិយាយ។> ដូច្នេះខ្ញុំគិតថា ការបង្ក្រាបនៅទីតាំងអស់ហ្នឹង គឺវាមានទំនាក់ទំនងជាមួយនឹងគ្នា។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញសាក្សីឆ្លើយតប!

បដិសេធនឹងការឆ្លើយតបរបស់សហព្រះរាជអាជ្ញាហើយខាងអន្តជាតិ ហើយសាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា អម្បាញ់មិញនេះ ប្រសិនបើលោកក្តាប់បាននៅសំណួរនេះ។ បើលោកក្តាប់មិនបានទេ លោកអាចសុំឱ្យមេធាវីតាំងសំណួរនោះសាជាថ្មី។

[១០:០៨:២២]

**លោក សុះ ពន់យ៉ាមីន៖**

**ឆ៖** ខ្ញុំមិនអាចក្តាប់បានទេ។ ឥឡូវសូមតាំងសំណួរសាជាថ្មីចុះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** មិនអីទេ លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសួរម្តងទៀត។ អម្បាញ់មិញនេះ ខ្ញុំបានអាននូវចម្លើយរបស់សាក្សីមួយរូប ដែលបានឆ្លើយពាក់ព័ន្ធទៅនឹងបញ្ហាបះបោរ។ គាត់បានរៀបរាប់ថា មនុស្សរាប់រយនាក់បានស្លាប់។ គាត់បាននិយាយដូចតទៅ៖ "គឺនៅពេលព្រលឹមខ្មែរក្រហមចងមនុស្ស ហើយ <នាំយកចេញទៅឱ្យស្លាប់>នៅកណ្តាលទន្លេ<។> ប្រហែលជាមនុស្សរាប់រយនាក់បានស្លាប់ ហើយគេដឹកតាមទូកនោះពេញៗពីរ <ឬ>បីទូកជារៀងរាល់ថ្ងៃ។ <សូម្បីអ្នកដែលឈឺនៅក្នុងផ្ទះក៏ត្រូវចាប់យកដាក់ក្នុងទូក ហើយដឹក>យកទៅ<ទម្លាក់ចោលក្នុងទឹក>។" លោកដើមបណ្តឹងរដ្ឋប្បវេណី តើអ្វីដែលសាក្សីរូបនោះ គាត់បានឆ្លើយហ្នឹង លោកដឹងថារឿងហ្នឹង គឺពិតជាអ៊ីចឹងទេ?

**ឆ៖** ឥឡូវខ្ញុំសូមនិយាយថា សាក្សីរូបនោះ គេឆ្លើយជារឿងរបស់គេផ្សេង ហើយមិនមែនពាក់ព័ន្ធនៅលើស្វាយឃ្លាំងទេ ហើយមិនអាចខ្ញុំឆ្លើយបានទេ។ អាហ្នឹងកន្លែងគេ គេសកម្មភាពគេផ្សេងតែ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កន្លែងខ្ញុំសកម្មភាពខ្ញុំផ្សេង។ អ៊ីចឹងខ្ញុំអត់ដឹង។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកភ័យខ្លាចក្នុងការឆ្លើយមែនទេ?

[១០:១០:០០]

**ឆ៖** ខ្ញុំអត់ភ័យទេ។ រឿងអីខ្ញុំត្រូវភ័យ ព្រោះខ្ញុំនិយាយតែការពិត។ ខ្ញុំអត់ត្រូវការភ័យអីទេ បើខ្ញុំភ័យ ខ្ញុំមិនចូលខ្លួនមកដល់កន្លែងហ្នឹងទេ ខ្ញុំនៅឆ្ងាយណាស់។

**ស៖** បាទមិនអីទេ។ លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្គាល់ភូមិឈ្មោះមួយឈ្មោះភូមិទ្រាទេ?

**ឆ៖** ខ្ញុំស្គាល់។

**ស៖** តើលោកដឹងទេថា នៅក្នុងភូមិទ្រាហ្នឹងក៏មានជនជាតិចាមងើបបះបោរដែរ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** តើការបះបោរនៅទ្រាហ្នឹងគឺដូច មានពេលកើតឡើងក្នុងពេលដូចគ្នាទៅនឹងការបះបោររបស់ចាមនៅស្វាយឃ្លាំង និងនៅកោះផលដែរមែនទេ។

**ឆ៖** អត់ដូចៗទេ។

**ស៖** អ៊ីចឹងគឺនៅពេលក្រោយមែនទេ គឺបះបោរហ្នឹងគឺនៅខែវិច្ឆិកា ឆ្នាំ៧៥ មែនទេ?

**ឆ៖** បះបោរនៅទ្រា តាមខ្ញុំដឹងព្រោះនៅក្បែរគ្នាដែរ ខ្ញុំដឹងពិតថាគេមុន ហើយបះបោរគ្នាហ្នឹងមិនទាន់កើតជាទ្រង់ទ្រាយបះបោរទេ គ្រាន់តែមានសកម្មភាពបន្តិច គេបង្ក្រាប គេចាប់ទៅអស់ទៅអ៊ីចឹងស្ងប់ទៅវិញ។

[១០:១១:៥១]

**ស៖** ឥឡូវនេះខ្ញុំសូមអានសម្រង់មួយផ្សេងទៀត ដែលចេញមកពីសៀវភៅរបស់អ្នកស្រាវជ្រាវដដែល គឺខ្ញុំសូមដកស្រង់<ចេញពីអ្នកស្រាវជ្រាវជនជាតិបារាំងម្នាក់ឈ្មោះ>លោក ប៉ុងសូដ៍ ម្តងគឺឯកសារ<នេះមាន ERN> ដដែល<ដូច>ដែលខ្ញុំបានដកស្រង់អម្បាញ់មិញ លោកប្រធាន។ លោក ប៉ុងសូដ៍ ដែលជាជនជាតិបារាំងគាត់និយាយថា៖ “នៅខែវិច្ឆិកា ឆ្នាំ៧៥ ចាមនៅក្នុងភូមិ<ទាំងបីរបស់>ស្រុកក្រូចឆ្មារហ្នឹងក៏បះបោរដែរ។ បន្ទាប់មកខ្មែរក្រហមបានកម្ទេចអ្នកដែលបានបះបោរ<ក្នុងភូមិដោយកាំភ្លើងបេ-៤០> ហើយ<វាយកម្ទេចក្បាលអ្នកដែលនៅរស់ជាមួយនឹងចបតាសេះ។ គេបាន>បោះសាកសពចោល<។ ពួកខ្មែរក្រហមថែមទាំងបានដោតក្បាលអ្នកបះបោរទាំងនោះនឹងលំពែង> ហើយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<ដាក់បង្ហាញ>នៅតាម<ច្រាំង>ដងទន្លេមេគង្គ។” តើលោកធ្លាប់ស្ដាប់ឮរឿងហ្នឹងទេ ដែលកើតឡើងនៅក្នុងភូមិទ្រានៅក្នុងឆ្នាំ៧៥នោះ?

**ឆ៖** អត់ទេ។ អត់បាន ព្រោះភូមិគេផ្សេង ខ្ញុំអត់ដឹង។

**ស៖** <ខ្ញុំឆ្ងល់ចំណុចមួយ លោកដើមបណ្ដឹងរដ្ឋប្បវេណី។> លោកបានឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា<ដោយនិយាយ>ថា កងទ័ពភូមិភាគកណ្ដាលហ្នឹងគឺកាចសាហាវជាងកងទ័ពភូមិភាគបូព៌ា។ <ខ្ញុំគិតថាការនិយាយបែបនេះហាក់ដូចជាចម្លែកបន្តិច តើត្រឹមត្រូវទេ?> ដូច្នេះ តើលោកអាចពន្យល់យ៉ាងម៉េច <នៅពេលដែលលោក>ថាកងទ័ពខាងភូមិភាគកណ្ដាល<>កាចសាហាវជាងកងទ័ពភូមិភាគបូព៌ាហ្នឹង?

**ឆ៖** ខ្ញុំបកស្រាយរួចហើយ ខ្ញុំមិនអាចបកស្រាយពីរបីដងទេ អ៊ីចឹងខ្ញុំសូមប៉ុណ្ណឹង។ ព្រោះទើបសួរខ្ញុំអំមិញទេអាហ្នឹង។

**ស៖** លោកស្គាល់បុរសម្នាក់ឈ្មោះ សោ ភឹម ទេ?

**ឆ៖** អត់ស្គាល់។

**ស៖** លោកដឹងថាអ្នកណាជាប្រធានភូមិភាគបូព៌ាទេ? គឺភូមិដែល១ -- ភូមិ១លោកហ្នឹងចំណុះនៅភូមិភាគបូព៌ាហ្នឹង អ៊ីចឹងខ្ញុំចង់ដឹងថាលោកស្គាល់ប្រធានភូមិភាគហ្នឹងទេ?

**ឆ៖** អត់ទេ អត់ស្គាល់។

**ស៖** មានភស្តុតាងដែលបញ្ជាក់ថា គឺប្រធានភូមិភាគបូព៌ាហ្នឹងជាអ្នកកម្ទេចការបះបោរជនជាតិចាម។ លោកក្រោយមកនោះ លោកមានធ្លាប់ឮទេថា អ្នកដែលទទួលខុសត្រូវក្នុងការកម្ទេចជនជាតិចាមហ្នឹង គឺប្រធានភូមិភាគបូព៌ានេះឯង?

**ឆ៖** ខ្ញុំអត់ឮទេ បើលោកឯងឮ លោកឯង អាហ្នឹងជារឿងរបស់លោកឯងទេ។ តែខ្ញុំសម្រាប់ខ្ញុំអត់ឮទេ ខ្ញុំអត់ដឹងទេ មិនដឹងខាងណាខាងណីទេ។

[១០:១៥:៤២]

**ស៖** ខ្ញុំជិតចប់ហើយ ខ្ញុំនៅសល់សំណួរមួយចំនួនតូចទៀតដើម្បីសួរលោក។ កាលពីម្សិលមិញលោកបានឆ្លើយពាក់ព័ន្ធទៅនឹងបញ្ហាជនជាតិចាម ដែលត្រូវបានគេចាត់ទុកថាប្រជាជនថ្មី។ ខ្ញុំដូចជាវង្វេងបន្តិចពាក់ព័ន្ធនឹងចំណុចនេះ។ ខ្ញុំដឹងថាអ្នកដែលត្រូវបានរំដោះមុន<ថ្ងៃទី១៧ ខែមេសា> ឆ្នាំ៧៥ហ្នឹង គេហៅថាប្រជាជនចាស់ ឬប្រជាជនមូលដ្ឋាន។ អ៊ីចឹងលោក ហើយនិងអ្នកផ្សេងទៀត<ដែលមក

ពី>ភូមិ<របស់លោក>ហ្នឹង តាមពិតទៅជា<>ជាប្រជាជនមូលដ្ឋានទេ<មែនទេ>?

**ឆ៖** ឥឡូវខ្ញុំសុំបកស្រាយឲ្យលោកស្ដាប់ឲ្យបានច្បាស់ថា គេហៅថាប្រជាជន មុនឆ្នាំ១៩៧៥ ហ្នឹង នៅក្នុងតំបន់រំដោះហ្នឹង គេហៅថាប្រជាជនមូលដ្ឋាន។ តែក្រោយឆ្នាំ១៩៧៥ គេហៅថាប្រជាជនថ្មី ដោយមូលហេតុគេជម្លៀសចេញពីភូមិខ្ញុំ ទៅរស់នៅភូមិគេផ្សេងទៀត។ ហ្នឹងសូមឲ្យលោកជ្រាប។

**ស៖** ចុះអ្នកណាជាអ្នកប្រាប់លោក <ហើយនិង>អ្នក<ផ្សេងទៀតដែលមកពី>ភូមិ<របស់លោក ថាតើលោកត្រូវបានគេចាត់ទុកជាប្រជាជនមូលដ្ឋាន -- សូមទោស គឺជា>ប្រជាជនថ្មី<>?

**ឆ៖** គេអត់ប្រាប់ទេ គេហៅ គេអត់ប្រាប់ទេ គេហៅតែម្ដង។ មេគេ ឬក៏ប្រជាជនគេហ្នឹង គេហៅអ៊ីចឹងតែម្ដង។

[១០:១៧:៣៧]

**ស៖** ប្រហែលជាសំណួរចុងក្រោយ លោកដើមបណ្ដឹងរដ្ឋប្បវេណី។ តើលោកដឹងទេក្នុងឆ្នាំ៧៣ ក្នុងទីតាំងដែលលោករស់នៅហ្នឹង នៅកន្លែងដែលលោករស់នៅហ្នឹង គេមានបង្កើតជាសហករណ៍ហើយ ឬនៅ?

**ឆ៖** ឥឡូវសូមសួរម្ដងទៀត ព្រោះខ្ញុំស្ដាប់អត់បានអំមិញ។

**ស៖** អម្បាញ់មិញនេះ ខ្ញុំសួរលោកថានៅក្នុងភូមិរបស់លោកនៅក្នុងឆ្នាំ១៩៧៣ តើគេមាន បង្កើតសហករណ៍ហើយឬនៅ?

**ឆ៖** ឆ្នាំ៧៣ គេមិនទាន់បង្កើតទេ ព្រោះទើបតែរំដោះ។ អ៊ីចឹងគេហៅថា "ក្រុមសាមគ្គី" គេ បង្កើតក្រុមសាមគ្គី។

**ស៖** តើលោកចាំទេថា នៅពេលណាដែលគេបង្កើតកន្លែងហូបចុករួម<>?

**ឆ៖** ខ្ញុំអត់ចាំបានទេ ព្រោះកាលហ្នឹងវាភ្លេចភ្លាំងអស់ហើយ វាយូរលង់មកហើយ ៤០ឆ្នាំមក ហើយ ខ្ញុំមិនអាចចាំបាន។

[១០:១៩:០៩]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេល

នេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២០ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់លាស់សម្រាប់ប្រតិចារឹក<ពាក់ព័ន្ធនឹងសម្រង់ដែលលោក>មេធាវីការពារក្តីបានដកស្រង់ចេញពីសៀវភៅរបស់លោក ប៉ែន យៀរនិន ដែលថាកម្មាភិបាលខ្មែរក្រហម២៨នាក់ ត្រូវបានសម្លាប់ចោល។ <កិច្ចសម្ភាសន៍ដែលដកស្រង់>ដោយ ប៉ែន យៀរនិន <នៅក្នុងឯកសារ>នេះ <គឺតាមពិតជាកិច្ចសម្ភាសន៍មួយ ដែលត្រូវបានទទួលយកដោយ> តុលាការ<នេះ។> គឺឯកសារ E3/7531 – E3/7531 ជាកិច្ចសម្ភាសន៍ដែលធ្វើឡើង<ដោយ នេត ថាយ៉ូវ>នៅក្នុងខែកញ្ញា <ឆ្នាំ១៩៨៤>។ <សូមដកស្រង់ពីរបីចំណុចខ្លីៗ៖> "ការពិតទៅឧបទ្ទវហេតុ<>ដែលបានរៀបរាប់<នេះ> មិនមែនកើតឡើងនៅស្វាយឃ្លាំងនោះទេ គឺនៅកោះផល។ ទី២ <សាក្សីដែលត្រូវបានគេ>សម្ភាស<នោះ> មិន<ធ្លាប់រស់នៅ>កោះផល<ឬរស់នៅជិតៗហ្នឹងទេ> ហើយគាត់ក៏មិនដែលរស់នៅក្នុងស្រុកនេះដែរ<។> គាត់ជាអ្នកដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ បញ្ជូនទៅកាន់ស្រុកត្បូងឃ្មុំ<។ ចំណុច>ចុងក្រោយ <កិច្ចសម្ភាសន៍នេះនិយាយដោយផ្អែកលើការ>ទទួលបានព័ត៌មានពីគេមកទេ ដែលថាខ្មែរក្រហម២៨នាក់ ត្រូវបានគេសម្លាប់នេះ។ មិនបាននិយាយ<អ្វីទាំង

អស់ទាក់ទងនឹង>ការចាក់នឹងដាវ ឬ<ចំណុចដែលស្រដៀងៗនេះ>ទេ។ ដូច្នេះប្រតិចារឹក<គួរតែបង្ហាញថា កិច្ចសម្ភាសន៍ជាក់លាក់នេះគ្រាន់តែជាផ្នែក*(ឮមិនច្បាស់)*។> មេធាវីការពារក្តីអាចបន្តប្រើប្រាស់សៀវភៅនេះបាន ក៏ប៉ុន្តែចំណុចនេះ គឺមានកិច្ចសម្ភាសន៍ជាច្រើនទៀត<ជាមួយ>សាក្សីទាំងនោះ<ដែល>នៅឯកោះផល<។> ហើយ<ចំពោះខ្ញុំ> មេធាវីការពារក្តីគួរតែសួរសាក្សីដែលមានវត្តមាននៅទីនោះ ជាជាង<ការប្រើប្រាស់ព័ត៌មានចេញពី>អ្នកដែលមិនមានវត្តមាននៅកោះផលនោះ។

[១០:៣៥:៥៦]

**លោក វ៉ិចទ័រ កូប៉េះ៖**

<ពិតជាពាក្យដែលប្រកបដោយគតិបណ្ឌិត លោកសហព្រះរាជអាជ្ញា> នេះគឺអ្វីដែលយើង<គួរតែធ្វើឱ្យបានញឹកញាប់ ដោយ>ប្រើប្រាស់ភស្តុតាង<ចេញ>ពីមនុស្សដែលបានឃើញ<ហេតុ-ការណ៍ជាក់ស្តែង>ដោយផ្ទាល់ <ហើយនេះជាអ្វីដែលយើងមិនធ្វើនៅក្នុងតុលាការនេះ>។

**ប្រធានអង្គជំនុំ៖**

បាទ ហើយជាបន្ត អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមានសំណួរ។ សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រមទាំងអស់គ្នា។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក សុះ ពន់យ៉ាមីន ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ <ក្នុងឋានៈជាមេធាវីរបស់គាត់> យើងខ្ញុំ<នឹង>ចោទសំណួរ<មួយចំនួនដើម្បីសុំការបំភ្លឺអំពីអ្វីដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ>។ ខ្ញុំចាប់អារម្មណ៍ជាសំខាន់ទៅនឹងការបះបោរនៅស្វាយឃ្លាំង ដែលលោកបានចូលរួមដែរ ហើយខ្ញុំនឹងចោទសំណួរមួយចំនួន ដើម្បីសុំការបំភ្លឺពីលោក។ កាលពីម្សិលមិញ សហព្រះរាជអាជ្ញា បានដកស្រង់រឿងរ៉ាវមួយផ្នែកនៃបងប្រុសរបស់លោក ទាក់ទងទៅនឹងការបះបោរនេះ។ អ៊ីចឹង ខ្ញុំចង់សួរលោកបញ្ជាក់ពីលោកថាតើកាលនោះលោកបានចូលរួមបះបោរជាមួយបងប្រុសរបស់លោកដែរឬទេ នៅឆ្នាំ៧៥ហ្នឹង?

[១០:៣៧:៣៣]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក សុះ ពន់យ៉ាមីន៖**

**ឆ៖** កាលនោះនៅជាមួយគ្នា ក៏ប៉ុន្តែពេលវេលាមិនអាចនៅជាមួយគ្នារហូតបានទេ ប៉ុន្តែវានៅក្នុងភូមិជាមួយគ្នា។

**ស៖** ខ្ញុំត្រឡប់មកនិយាយពីរយៈពេលមុនពេលបះបោរហ្នឹងបន្តិច ហើយនិងសុំការបំភ្លឺពីលោក សួរថាតើលោកចាំថា តើនៅពេលដែលមានការចាប់ខ្លួនដែលមកពីការបះបោរហ្នឹង សួរថានៅពេលនុ៎ងនៅពេលបះបោរ ហើយពេលមានការចាប់ខ្លួននុ៎ង តើគេមាននិយាយអំពីខ្មែរសទេ នៅពេលហ្នឹង?

**ឆ៖** អត់មាននិយាយទេ។

**ស៖** ខ្ញុំនិយាយអំពីខ្មែរសនេះ ពីព្រោះថានៅក្នុងឯកសារដែលរៀបរាប់អំពីរឿងរ៉ាវរបស់បងប្រុសរបស់លោកនោះ គឺឯកសារ E3/2653, ERN ជាភាសាអង់គ្លេសគឺ 00219145, ERN ជាភាសាខ្មែរគឺ00904322 ដែលជាអកុសលមិនទាន់មានឯកសារនេះជាភាសាបារាំងទេ អ៊ីចឹងខ្ញុំសូមអានសម្រង់នេះជាភាសាអង់គ្លេស។ បងប្រុសរបស់លោកនិយាយដូចតទៅនេះ៖ “<មានពាក្យចចាមអារាម>ថាខ្មែរក្រហម<កំពុងតែ>ចាប់<ខ្លួន>អ្នកណាម្នាក់ដែលជាប់ពាក់ព័ន្ធជាមួយនឹងចលនាខ្មែរស។” សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងសំណួរខ្ញុំសួរថា តើក្រោយពី<ស្តាប់សម្រង់>នេះហើយ ធ្វើឲ្យលោកនឹកឃើញដល់អ្វីដែរឬទេ ឬក៏លោកចាំថា <ដូច>អ្វីដែល<បងប្រុសរបស់លោកបាននិយាយ តើមានការ>រៀបរាប់<ពី>ចលនាខ្មែរសនៅពេលនោះ<ដែរឬទេ>?

[១០:៤០:០១]

**ឆ៖** ខ្ញុំសូម -- បញ្ហាចលនាខ្មែរស វាសម្រាប់ វាថា វានិយាយ វាចោទប្រកាន់។ ឧទាហរណ៍ ខ្ញុំសូមលើកបញ្ជាក់យ៉ាងវែងបន្តិចថា សូមអត់ទោស ដូចខ្ញុំមានប្រសាសន៍ម្សិលថា មនុស្សម្នាក់វាចង់សម្លាប់ចោលហ្នឹង វាចោទប្រកាន់ថា អ្នកណាឯងស័ក្តិ៥ ឬក៏ស័ក្តិ៣។ អ៊ីចឹងវាមិនដែលយកមនុស្សថាអ្នកនេះស្លូតត្រង់ទេ ប៉ុន្តែវាចាប់យកទៅសម្លាប់ចោល វាមិនដែលថាអ៊ីចឹងទេ។ អ៊ីចឹងអត់មានសោះចលនាខ្មែរស ចលនាអីហ្នឹង អត់មានទេ។ អ៊ីចឹងសម្រាប់បងខ្ញុំ បងប្រុសខ្ញុំសម្គាសអ៊ីចឹង បានខ្ញុំថា ខ្ញុំរស់នៅភូមិជាមួយគ្នាមែន ប៉ុន្តែពេលវេលាមិនអាចនៅជាមួយគ្នារហូតបានទេ។ អ៊ីចឹងត្រង់កន្លែងដែលឮគេថាយ៉ាងម៉េចនោះ សម្រាប់វា តែសម្រាប់ខ្ញុំ ខ្ញុំអត់មានឮអីទេ។ កាលណាគេសួរចម្លើយខ្ញុំ គេសួរពីហេតុផល យើងបះបោរ មូលហេតុអីៗ អាហ្នឹងគេសួរប៉ុណ្ណឹង។ អាហ្នឹងសូមបញ្ជាក់។ ខ្ញុំមិនចង់បកវែងទេ ប៉ុន្តែបើមិនបក អ៊ីចឹងគេស្តាប់អត់បាន។

**ស៖** មិនមានបញ្ហាអ្វីទេ បើសិនជាខ្ញុំមិនយល់ចំណុចណាមួយ ខ្ញុំនឹងសុំចោទសំណួរបន្ថែមទៅលោក ហើយសូមអរគុណ<ចំពោះការបារម្ភរបស់លោក>។ ទាក់ទងទៅនឹងកម្មាភិបាលដែលទទួលខុសត្រូវ<ក្នុងមន្ទីរនៅពេលនោះ គឺជាកម្មាភិបាលខ្មែរក្រហមពាក់ព័ន្ធនឹង>ការបះបោរ<នៅពេល>នោះ<តើលោកចាំឈ្មោះអ្នកណាខ្លះបានទេ? មិនថាតែនិយាយអំពីកម្រិតត្រឹមមេ>ភូមិ<របស់>លោក<នៅមូលដ្ឋាន ឬ>ក៏ដូចភូមិអ្នកផ្សេង<ទៀតដែលនៅក្នុងភូមិភាគហ្នឹង។ សរុបមក គឺនិយាយជាពិសេសនៅតំបន់>ស្វាយឃ្លាំង<>?

[១០:៤២:១២]

**ឆ៖** ចម្លើយ ខ្ញុំទើបចម្លើយអំមិញ។ ប្រធានខ្ញុំ រឿងអីខ្ញុំមិនស្គាល់ ខ្ញុំប្រាប់រួចហើយតើ! រួចគាត់នៅសួរដដែលៗ។ ឧទាហរណ៍ ខ្ញុំប្រាប់ថាឈ្មោះ កៅ ប្រធានភូមិហ្នឹង ខ្ញុំប្រាប់តាំងពីម្សិលមកហើយ។

**ស៖** ខ្ញុំមិននិយាយត្រឹមតែពីឈ្មោះប្រធានភូមិទេ ខ្ញុំនិយាយទៅដល់ប្រធានភូមិផ្សេងៗទៀតផងដែរ ដើម្បីរំឭកការចងចាំរបស់លោក ខ្ញុំសូមដកស្រង់កិច្ចសម្ភាសន៍របស់លោកដែលផ្ដល់ជូនឲ្យ អ៊ីសា ឧស្មាន ឯកសារ E3/9136, ERN ជាភាសាបារាំងគឺ <01128375>, ERN ជាភាសាខ្មែរគឺ 0004 6390, ERN ជាភាសាអង់គ្លេសគឺ <01133239>។ លោក ឧស្មាន ចោទសំណួរលោកទាក់ទងទៅនឹងការរើបម្រះ ការបះបោរ ហើយនិងការគ្រោងការចាប់ខ្លួនមនុស្ស ហើយគាត់សួរលោកដូចទៅនេះ៖ "ថាលោកជួបអ្នកណាដែរ ប្រទះនឹងអ្នកណាដែរ? លោកឆ្លើយ៖ ជួប<ឈ្មោះ> ចែត ហើយនិង ប៉េង ហេង ហើយដើម្បីឲ្យច្បាស់ជាងនេះតែម្ដង គឺជួបពួកខ្មែរក្រហម។ ពួកគេមានគ្នាបីនាក់ បូកបញ្ចូលទាំង<> ប្រធានភូមិឈ្មោះ ម៉ាត់ ហើយ ម៉ាត់ នោះជាបងប្អូនជីដូនមួយរបស់ខ្ញុំ។ គាត់មិនមែនជាមនុស្សរបស់ខ្មែរក្រហមទេ ប៉ុន្តែធ្វើការនៅក្រោមការបញ្ជារបស់គេ គេឲ្យគាត់ជូនទៅ។" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងសម្រង់នេះធ្វើឲ្យលោកនឹកឃើញទេ លោក<នៅចាំ> ចែត ហើយនិង ប៉េង ហេង នេះលោកនឹកឃើញគាត់ទេ ចាំគាត់ទេ?

**ឆ៖** ត្រឹមត្រូវ។

[១០:៤៤:៤០]

**ស៖** អ៊ីចឹងលោកនិយាយថាលោកចាំ។ បើអ៊ីចឹងខ្ញុំសួរលោកថា តើលោកដឹងថា ចែត ហើយនិង ប៉េង ហេង នេះគាត់មានឋានៈជាអ្វីដែរនៅពេលនោះ?

**ឆ៖** ខ្ញុំអត់ស្គាល់ឋានៈតួនាទីគេទេ ប៉ុន្តែក្នុងនាមមន្ត្រីរបស់ខ្មែរក្រហម។

**ស៖** ឥឡូវ ខ្ញុំសូមយោងទៅនឹងរឿងរ៉ាវរបស់បងប្រុសរបស់លោក គឺឯកសារ E3/2653, ERN ជាភាសាបារាំងគឺ 00219145 <សូមទោស> ជាភាសាអង់គ្លេស<ទេ>, អត់មាន ERN ជាភាសាបារាំងទេ, ERN ជាភាសាខ្មែរគឺ 00904323។ បងប្រុសរបស់លោកនិយាយជាភាសានេះ សម្រង់ជាភាសាអង់គ្លេស៖ "<កម្មាភិបាលខ្មែរក្រហមបួននាក់ដែលមានឈ្មោះ ប៉េង ហេង> ចែត, ចុល ហើយ ស្លេះ ម៉ាត់ ជាជនជាតិចាមដែលត្រូវបានចាត់តាំងជាមេភូមិ៦ ដើម្បីបំពេញបេសកកម្ម <នេះ>។ ប៉ុន្តែគេបានចាប់តែបុរសបីនាក់នេះគឺឈ្មោះ សេន ឡឹម, សុះ ហ៊ីម ហើយនិង តាតេះ។ ពួកគេប្រឈរមុខជាមួយនឹងអ្នកភូមិ<មួយក្រុម>ដែល<ត្រៀម>ប្រយុទ្ធ<តស៊ូ>។" បញ្ចប់ការដកស្រង់។

**អ្នកបកប្រែ៖**

លោកប្រធាន អ្នកបកប្រែស្តាប់អត់ឮ គាត់អត់បើកក្បាលមីក្រូលោកប្រធាន។

**ស្លួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមទោស ក្រៅពី ប៉េង ហេង ហើយនិង ចែត ដែលលោកនិយាយថា លោកចាំនោះ តើឈ្មោះ ចុល នេះលោកចាំគាត់ទេ លោកនឹកឃើញគាត់ទេ? ហើយដឹងថាគាត់នឹងមានមុខងារអីដែរនៅពេលនោះ តួនាទីអីដែរ?

**លោក សុះ ពន់យ៉ាមីន៖**

**ឆ៖** ឈ្មោះ ចុល ខ្ញុំអាចចាំបាន តែខ្ញុំមិនដឹងពីតួនាទីរបស់គេទេ។ អ៊ីចឹងបុគ្គលិកគេចុះធ្វើការងារនៅក្នុងភូមិហ្នឹង អ៊ីចឹងបានន័យថា ខ្ញុំអត់ដឹងពីតួនាទីគេយ៉ាងណាៗទេ ខ្ញុំអត់ដឹង។

**ស៖** តាមសម្រង់ដែលខ្ញុំទើបនឹងអានអម្បាញ់មិញនេះ គឺរឿងរ៉ាវរបស់បងប្រុសរបស់លោកនោះ <ដែលគាត់ទំនងជាបាននិយាយ>ថា ស្លេះ ម៉ាត់ នេះដែលជាបងប្អូនជីដូនមួយរបស់លោកហ្នឹង គឺគាត់បានចូលរួមក្នុងការចាប់មនុស្សទាំងបីនាក់គឺ<>ឈ្មោះ សេន ឡឹម, សុះ ហ៊ីម ហើយនិង តាតេះ។ លោកចាំពីចំណុចនេះទេ?

[១០:៤៨:០៥]

**ឆ៖** ចំណុចនេះខ្ញុំអត់ៗចាំអី ខ្ញុំអត់ដឹងតែម្តង ព្រោះអាហ្នឹងជាតួនាទី ដែលពាក្យសម្តីរបស់បងប្រុសខ្ញុំ វាដឹងយ៉ាងម៉េចអីម៉េច អាហ្នឹងជារឿងរបស់វា ខ្ញុំមិនអាចដឹងរឿងគេ១០០ភាគរយ ខ្ញុំមិនដឹងទេ។

**ស៖** អ៊ីចឹងខ្ញុំត្រូវយល់យ៉ាងម៉េចដែរ<ចំពោះអ្វី>ដែលលោក<បាន>ឆ្លើយ<កាលពីដំបូងចំពោះសំណួររបស់ខ្ញុំ លោកបាននិយាយ>ថា<> ដោយសារពេលខ្លះ<>លោក<មិន>នៅជាមួយបងប្រុស

របស់លោក<ទេ វាអាចទៅរួចដែលថាបងប្រុសរបស់លោក>បានឃើញ<ហេតុការណ៍មួយចំនួនដែល>លោកមិនបានឃើញ។ <តើ>ខ្ញុំត្រូវយល់អ៊ីចឹង<ត្រឹមត្រូវ> ឬយ៉ាងណា?

**ឆ៖** អានេះ ខ្ញុំ -- អានេះជាសិទ្ធិរបស់លោកស្រី ខ្ញុំមិនអាចសន្និដ្ឋានថា ឲ្យលោកស្រីយល់អ៊ីចេះយល់អ៊ីចុះបានទេ។ អាហ្នឹងស្រេចលើជម្រើសលោកស្រី ទាំងពីរហ្នឹងនៅលើលោកស្រីជម្រើសចុះ។

**ប្រធានអង្គជំនុំ៖**

លោក។ដើមបណ្ដឹងរដ្ឋប្បវេណី លោកព្យាយាមឆ្លើយតបនូវអ្វីដែលសមស្រប មិន។ឆ្លើយ គប្បីឆ្លើយដូច្នេះទេ។ វាមានចម្លើយពេលខ្លះ គឺវាមានលម្អៀងគ្នា ឬក៏វាខុសគ្នា រវាងចម្លើយមួយៗ។ អ៊ីចឹងហើយបានជាធ្វើការប្រៀបធៀបមើល នៅក្នុងចម្លើយដែលបានឆ្លើយកន្លងមកនេះ។ ព័ត៌មានដែលបានកន្លងមកនេះ តើព័ត៌មានណាវាប្រាកដជាង។ ប្រសិនបើព័ត៌មានដែលលោកមិនដឹង គឺលោកឆ្លើយថាមិនដឹង ដូចយើងបានប្រាប់ហើយ នុំងក៏ជាចម្លើយដែរ។ លោកមិនអាចធ្វើអ្វីទៅតាមចង់ ឬមិនចង់បានទេ វាមានកាតព្វកិច្ចមួយត្រូវឆ្លើយតបទៅនឹងសំណួរដែរ ព្រោះនៅទីនេះយើងប្រើពាក្យថា "ស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី"។ សូមលោករៀបអារម្មណ៍ ដើម្បីឆ្លើយតប។

[១០:៥០:៣០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក សុះ ពន់យ៉ាមីន ខ្ញុំសួរលោកបន្តទៀត។ លោកបានឆ្លើយថា លោកមានគ្នាតិចទេពីដំបូងដែលបានយកស្គរ <>ហើយដឹកនាំ<ការ>បះបោរ។ អ៊ីចឹងខ្ញុំចង់សួរលោក<តើលោកចាំទេ> ថាតើ<ចុងក្រោយ>អ្នកភូមិទាំងអស់ហ្នឹងបានមកចូលរួមជាមួយលោកដែរឬទេ?

**លោក សុះ ពន់យ៉ាមីន៖**

**ឆ៖** ក្រោយពីយើងទូងស្គរទៅ គេមកចូលរួមទាំងអស់គ្នា។

**ស៖** នៅក្នុង<ផ្នែកមួយនៃ>កិច្ចសម្ភាសន៍ឲ្យលោក <អ៊ីសា> ឧស្មាន លោកបានឆ្លើយថា ភូមិរបស់លោកហ្នឹងរើបម្រះ ហើយក៏ភូមិទី៦ហ្នឹងដែរ<។ តើលោកចាំថាបាននិយាយបែបនោះទេ? សម្រាប់កំណត់ត្រាប្រតិចារឹក> គឺជាឯកសារ E3/9136, ERN ជាភាសាបារាំងគឺ 01128378, ERN ជាភាសាខ្មែរ 00046394, ERN ជាភាសាអង់គ្លេសគឺ 01133242។ តើលោកចាំដែរឬទេ ថាមិនមែនត្រឹមតែភូមិទី៥របស់លោកទេ គឺថាមានទាំងភូមិ៦ផងដែរ ដែលចូលរួមក្នុងការក្រោកឡើងរើបម្រះបះបោរហ្នឹង?

**ឆ៖** ភូមិទី៦ ហើយភូមិទី៥ កាលនោះគេបង្កើតមានភូមិទី៦។ ប៉ុន្តែក្រោយរំដោះឆ្នាំ១៩៧៩មក គេដាក់ថាភូមិទី៥មួយទេ ភូមិទី៦ និងភូមិទី៥ជាមួយគ្នាតែម្តង គេដាក់។ អ៊ីចឹងជំនាន់ខ្មែរក្រហមនេះ គេដាក់ភូមិទី៦ផង ភូមិទី៥ផង ភូមិចាមហ្នឹង ភូមិចាម។ អ៊ីចឹងសព្វថ្ងៃនេះ គេប្រើដាក់ថាតែភូមិទី៥ទេ។

**ស៖** សំណួរខ្ញុំអម្បាញ់នេះ ខ្ញុំចង់ដឹងថា តើនៅសម័យនោះពិតជាមានភូមិទាំងពីរហ្នឹង ដែលចូលរួមក្នុងការបះបោរ <ពីព្រោះភូមិទាំងពីរនេះនៅខុសពីគ្នា ដូច្នេះខ្ញុំចង់សួរថា តើ>លោកបានពិគ្រោះគ្នាជាមួយនឹងអ្នកភូមិទី៦<>ដែរ<ឬទេ>?

**ឆ៖** បាទ ពិតមែន។

**ស៖** ខ្ញុំក៏ចង់ដឹងផងដែរ ថាតើមានការពិគ្រោះគ្នាជាមួយភូមិដទៃទៀតនៅឃុំស្វាយឃ្លាំងដែរឬទេ ក្រៅពីភូមិទី៦ និងទី៥នេះ?

[១០:៥៣:៥៦]

**ឆ៖** អត់មានទេ។

**ស៖** ខ្ញុំចោទសំណួរនេះទៅលោកនោះ ពីព្រោះថានៅក្នុងសៀវភៅរបស់លោក អ៊ីសា ឧស្មាន ហ្នឹងដែលមានចំណងជើងជាភាសាអង់គ្លេសថា "អ្នកដែលរស់រានមានជីវិតនៅក្នុងភូមិនោះ" គឺឯកសារ E3/2653 មានរឿងរ៉ាវរបស់មនុស្សម្នាក់ដែលឈ្មោះ ឡិប រ៉ាន់ម៉ាត់ ERN ជាភាសាអង់គ្លេសគឺ 00219148, ERN ជាភាសាខ្មែរគឺ 00904326។ គាត់លើកឡើងដូចតទៅនេះ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ "ខ្ញុំ<បានបញ្ចុះបញ្ចូលពីការបះបោរនេះដល់>អ្នកភូមិទាំងអស់<នៅស្រុកក្រូចឆ្មារ> មិនមែនតែស្វាយឃ្លាំងមួយ<ទេ។> យើងបានរៀបចំកិច្ចប្រជុំជាសម្ងាត់ <ហើយការរៀបចំប្រជុំនីមួយៗធ្វើឡើងដោយហ្មត់ចត់ណាស់>។ យើងកំណត់កាលបរិច្ឆេទដើម្បីធ្វើការបះបោរ នៅពេលយើងធ្វើបុណ្យ<រយ៉ា>។" សូមបញ្ចប់ការដកស្រង់។ សំណួរខ្ញុំ ខ្ញុំចង់ដឹងថា តើ<លោកដឹងថា>មានកិច្ចប្រជុំមួយនៅក្នុងស្រុកក្រូចឆ្មារ ដែលភូមិលោកនោះ នៅក្នុងស្រុកក្រូចឆ្មារនេះដែរ<។ ហើយបើ>ទោះបីលោកមិនបានចូលរួមក្នុងកិច្ចប្រជុំ<ទាំងនោះ>ក៏ដោយ <តើលោកដឹងទេថាមាន>កិច្ចប្រជុំ<ធ្វើនៅ>ភូមិផ្សេងៗទៀត<ទេ ក្រៅពី>នៅស្វាយឃ្លាំងហ្នឹង លោកមានដឹងរឿងហ្នឹងទេ?

**ឆ៖** ខ្ញុំសួរលោកថា គេប្រជុំហ្នឹង ថ្នាក់ណាគេមកប្រជុំ ឬក៏ប្រជុំរឿងអី? អ៊ីចឹងខ្ញុំអត់យល់ អ៊ីចឹងខ្ញុំពិបាកឆ្លើយ។

**ស៖** អត់បញ្ហាអ្វីទេ តើលោក<អាច>បញ្ជាក់បានទេថា ភូមិទី៥ ហើយនិងភូមិទី៦<នៅក្នុង>

ឃុំស្វាយឃ្លាំងហ្នឹង ស្ថិតនៅក្នុងស្រុកក្រូចឆ្មារ? <>

[១០:៥៦:៥៦]

**ឆ៖** ស្រុកក្រូចឆ្មារ។

**ស៖** តើភូមិទី៥ និងទី៦ នៃឃុំស្វាយឃ្លាំងនេះ ស្ថិតនៅក្នុងស្រុកក្រូចឆ្មារដែរឬទេ?

**ឆ៖** ខ្ញុំថា ក្រូចឆ្មារហើយអំមិញ។

**ស៖** បាទ អម្បាញ់មិញ ខ្ញុំបានអានសម្រង់មួយនៃរឿងរ៉ាវរបស់ ឡិប វ៉ាន់ម៉ាត់ ដែលគាត់ហ្នឹងបានបញ្ជាក់ថា គាត់ហ្នឹងបានញុះញង់<ប្រជាជន>ឲ្យ<ធ្វើការបះបោរ គឺថាគ្រប់ភូមិទាំងអស់>នៅក្នុងស្រុកក្រូចឆ្មារ <មិនមែនតែនៅឃុំស្វាយឃ្លាំងទេ។> ហើយគាត់បានពន្យល់ថា មានកិច្ចប្រជុំសម្ងាត់មួយ។ អ៊ីចឹងសំណួរខ្ញុំចង់សួរ<ឲ្យច្បាស់>ថាតើ ទោះបីជាលោកផ្ទាល់នោះ មិនបានចូលរួមកិច្ចប្រជុំហ្នឹងក៏ដោយ <តើ>លោក<ធ្លាប់ឮពី>កិច្ចប្រជុំសម្ងាត់<ទាំងនោះ ធ្វើឡើងនៅក្នុង>ភូមិ<ផ្សេងៗគ្នា> នៅក្នុងស្រុកក្រូចឆ្មារ<ដែរឬទេ?>

**ឆ៖** ខ្ញុំអត់បានដឹងទេៗ។

**ស៖** ដោយលោកមិនដឹងថាមានកិច្ចប្រជុំសម្ងាត់ហ្នឹង តើក្រោយមកនោះ លោកមានបាន<ឮ> ថាមានការបះបោរនៅក្នុងភូមិផ្សេងៗទៀត ក្រៅពីភូមិទី៥ និងទី៦ របស់លោកនេះ<ដែរឬទេ>?

**ឆ៖** ខ្ញុំដឹងតើ! ដឹងថាមានបះបោរ វាបះបោរហ្នឹង វាមុនស្វាយឃ្លាំង។

**ស៖** ការបះបោរផ្សេងដែលលោកនិយាយអំមិញនេះ គឺលោកសំដៅទៅលើការបះបោរនៅកោះផល ឬក៏យ៉ាងណា?

[១០:៥៩:៣២]

**ឆ៖** បះបោរ មានតែកោះផល ហើយនិងស្វាយឃ្លាំង ទ្រា ប៉ុណ្ណឹង ហើយភូមិពីរហ្នឹង គេបះបោរមុន។ កោះផល មុនប្រហែលកន្លះខែ ហើយស្វាយឃ្លាំងហ្នឹង ក្រោយគេ។ អ៊ីចឹងភូមិចាមទូទាំងប្រទេស មានតែបីភូមិហ្នឹងដែលបះបោរហ្នឹង។

**ស៖** តើលោកមានចាំ<កាលបរិច្ឆេទនៃ>ការបះបោរនៅ<ភូមិ>ទ្រា<>ដែរឬទេ?

**ឆ៖** ខ្ញុំអត់ចាំបានទេ មិនមែនទ្រាសទេ។ អ៊ីចឹងបានសូមអភ័យទោស អានឈ្មោះឲ្យវាច្បាស់ផង ព្រោះទ្រាសហ្នឹងភូមិគេ មានភូមិទ្រាសដែរ ប៉ុន្តែភូមិទ្រាសហ្នឹងគេអត់បះបោរទេ។ ភូមិទ្រាទេ បះបោរហ្នឹង។

**ស៖** ប្រហែលជាដោយសារខ្ញុំអានមិនសូវច្បាស់ សូមអភ័យទោស។ បើខ្ញុំយល់មិនច្រឡំទេគឺថា មានការបះបោរនៅក្នុងរដូវប្ញូស ហើយនិងនៅថ្ងៃស្រាយប្ញូស។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បះបោរនៅពេលក្រោយប្ញូសទេ។ ព្រោះបុណ្យហ្នឹងបុណ្យស្រាយប្ញូសហ្នឹងហើយ រួចបះបោរហ្នឹង ពេលប្ញូសហ្នឹង។ អ៊ីចឹងស្រាយប្ញូសរួចបានបះបោរ។

**ស៖** ទាក់ទងនឹងភូមិទ្រានេះ លោកមិនដឹងថា ការបះបោរហ្នឹង លោកមិនដឹងថា កើតឡើងនៅថ្ងៃណា ខែណា ពេលណាទេ។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១១:០១:៤០]

**ស៖** ឥឡូវខ្ញុំត្រឡប់មកនិយាយពីការបះបោរនៅក្នុងភូមិទី៥ របស់លោក ហើយខ្ញុំចង់ដឹងថា តើលោកមានចាំថា មានកម្មាភិបាលខ្មែរក្រហមប៉ុន្មាននាក់ដែលត្រូវបានសម្លាប់នៅថ្ងៃនោះ?

**ឆ៖** ខ្ញុំអត់ដឹងទេក្នុងនោះ។

**ស៖** ដើម្បីរំឭកការចងចាំរបស់លោក គឺឯកសារ អានេះជារឿងរ៉ាវរបស់បងប្រុសលោកដដែល គឺឯកសារ E3/2653 ERN ជាភាសាអង់គ្លេសគឺ 00219146 ERN ជាភាសាខ្មែរគឺ 00904323។ បើតាមរឿងរ៉ាវរបស់បងប្រុសរបស់លោក ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖“កងទ័ពខ្មែរក្រហមប្រាំមួយនាក់ត្រូវបានគេចាក់ស្លាប់។” តើលោកចាំដែរឬទេ ខ្ញុំអានជូនអំមិញនេះធ្វើឱ្យលោកនឹកឃើញទេ?

**ឆ៖** ខ្ញុំមិនចាំអី ខ្ញុំមិនឃើញ ខ្ញុំមិនដឹង ព្រោះខ្ញុំប្រាប់ហើយថា វាមិនអាចដឹងទាំងអស់ទេ កាលពេលនោះហ្នឹង ប្រុងដោយខ្លួនៗ។ អ៊ីចឹងខ្ញុំមិនអាចឃើញអ្វីដែលខ្ញុំ -- បើខ្ញុំឃើញខ្ញុំនិយាយ បើខ្ញុំមិនឃើញ ខ្ញុំមិននិយាយ ខ្ញុំមិនដឹង។ អ៊ីចឹងសម្រាប់អ្នកផ្សេងទៀត គេឃើញផ្សេងទៅ អាហ្នឹងជារឿងសម្រាប់ខ្ញុំអត់ទទួលស្គាល់លើបញ្ហាគេឃើញ រួចថា ខ្ញុំឃើញដែរ។ ខ្ញុំដឹងដែរ ខ្ញុំអត់ដឹងទេ។

[១១:០៣:៤៨]

**ប្រធានអង្គជំនុំ៖**

អ៊ីចេះទេ ដើមបណ្តឹងរដ្ឋប្បវេណី វាអាចរឿងអង្គហេតុមួយ វាអាចគាត់ដឹង ហើយលោកដឹង។ ហើយមួយទៀតហ្នឹង គឺអាចគាត់ដឹង ហើយលោកអត់ដឹងទេ។ ហើយអ្នកសួរ គឺមិនដឹងថា លោកដឹង ឬក៏អត់ទេ អ៊ីចឹងហើយបានជាសួរ។ ហើយប្រសិនបើជាចម្លើយតប ដូចយើងបានប្រាប់ច្រើនដងហើយថា បើលោកមិនដឹង គឺឆ្លើយថាមិនដឹង ក៏ជាចម្លើយដែរ វាខ្លី។ ព្រោះលោកមិនដឹង ឆ្លើយថា ដឹងវាកើតទេ

ណា។ ចៀសវាងយើងជជែក វាជជែកអ៊ីចឹងវាអត់ -- នីតិវិធីរបស់តុលាការ វាចំពោះមុខនីតិវិធីតុលាការ វាមិនត្រឹមត្រូវទេ។ បញ្ហាទី២ យើងបញ្ជាក់ហើយថា នៅក្នុងភាសាខ្មែរគេប្រើពាក្យមួយប្រហែលជាធ្ងន់ពេក ប៉ុន្តែគ្រាន់តែឲ្យយល់ថា នីតិវិធីឈ្មោចសួរ ឬក៏សួរដេញដោល គេប្រើពាក្យ "ដេញដោលនៅចំពោះមុខតុលាការ"។ មិនមែនសួរធម្មតាទេ គេប្រើពាក្យ "សួរដេញដោល"។ អ៊ីចឹងវាៗដើម្បីស្វែងរកការពិតអ៊ីចឹងកម្រិតនៃការសួរឆ្លើយនេះ វាមានកម្រិតខ្ពស់ជាងការសួរធម្មតា។ អាហ្នឹងគប្បីយល់បញ្ហានេះ។

សូមអញ្ជើញបន្តទៀតបាទ!

**សួរដោយកញ្ញា អង់តា ហ្គិសសេះ**

**ស៖** ឥឡូវខ្ញុំសូមអានឯកសារមួយនៃកិច្ចសម្ភាសន៍របស់លោក ជាមួយនឹង អ៊ីសា ឧស្មាន គឺឯកសារ E3/9136, ERN ជាភាសាបារាំងគឺ <01128379>, ERN ជាភាសាខ្មែរ <00046396>, ជាភាសាអង់គ្លេសគឺ 01133243 នេះជាសំណួរដែលចោទសួរដោយ អ៊ីសា ឧស្មាន<៖> "តើអ្នកបះបោរនោះមានអាវុធដែរឬទេ? ចម្លើយរបស់លោកដូចតទៅនេះ៖ យើងមានកាំភ្លើងពីរដើម មួយកាំភ្លើងកាប៉ាប៊ីន ដែលយើងដណ្តើមយកបាន<ពីកម្មាភិបាលខ្មែរក្រហមម្នាក់>ដែលយើង<កាប់វានឹងកាំបិត> ហើយយកកាំភ្លើងវា។ ហើយកាំភ្លើងមួយទៀត កាំភ្លើងទាហានដែរ ដែលវានៅទីនុំងដែរ។ យើងបានវាយយកកាំភ្លើងកាប៉ាប៊ីន ដោយចាក់មួយកាំបិតទៅលើទាហាននុំង។" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងសំណួររបស់ខ្ញុំ ចង់ដឹងថា តើ<ការចាក់នឹង>កាំបិតហ្នឹង<តើលោកចង់និយាយអំពីអ្វី?> ហើយ<នរ>ណា<ដែលត្រូវបានគេចាក់សម្លាប់>?

[១១:០៦:៣៨]

**លោក សុះ ពន់យ៉ាមីន៖**

**ឆ៖** អ្នកបះបោរមានអាវុធ អាវុធអ្នកបះបោរគឺកាំបិតហ្នឹងហើយ។ ហើយគេបានដូចថាកាំភ្លើងមួយដើមហ្នឹង ដោយសារដណ្តើមបានពីអ្នកដែលកាន់កាំភ្លើង គឺខាងខ្មែរក្រហម និយាយឲ្យខ្លី។

**ស៖** សំណួររបស់ខ្ញុំច្បាស់ជាងហ្នឹង លោកនិយាយថាមានការកាប់ យកកាំបិតកាប់ហ្នឹង។ អ៊ីចឹងខ្ញុំសួរលោកថា គេកាប់អ្នកណា?

**ឆ៖** គេកាប់ហ្នឹងគេបះបោរហ្នឹង គេកាប់ខ្មែរក្រហមហ្នឹងហើយ គេបះបោរហ្នឹងប្រឆាំងជាមួយខ្មែរក្រហម។ អ៊ីចឹងគេត្រូវកាប់ គេចាក់ ខ្ញុំអត់ដឹងទេ ព្រោះមិនមែនជាខ្ញុំជាអ្នកចាក់ ខ្ញុំជាអ្នកកាប់គេ។

**ស៖** អ៊ីចឹងខ្ញុំត្រូវយល់តាមរយៈចម្លើយរបស់លោកនេះ គឺថាត្រូវយល់ថា លោកមិនមានវត្តមាន

នៅទីនោះទេ <នៅពេល>គេ<>កាប់<គ្នានោះ តើ>អ៊ីចឹងមែនទេ?

**ឆ៖** ត្រឹមត្រូវៗ។

**ស៖** នៅក្នុងចម្លើយរបស់លោក ខ្ញុំមិន<ចាំថា វាគឺជាអ្វីដែល>លោកឆ្លើយទៅសហព្រះរាជអាជ្ញា ឬ<ក៏អត់>ទេ លោកបានឆ្លើយថា លោកមិនអាចដឹងថាទាហានដែលមកបង្ក្រាបការបះបោរហ្នឹងមកពីណានោះទេ។ លោកមិនដឹងថាជាយោធាស្រុក ឬក៏យោធាឃុំ ឬក៏យោធាមកពីណាផ្សេងនោះទេ។ តើខ្ញុំៗ បើខ្ញុំយល់យ៉ាងដូច្នេះនេះ តើយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ នៅពេលលោកឆ្លើយកន្លងមកនេះ?

[១១:០៩:១៧]

**ឆ៖** ខ្ញុំពិបាកឆ្លើយ បើខ្ញុំឆ្លើយទៅខ្លាចវាខុសនឹងនីតិវិធី។ ហៅថាអាហ្នឹង ខ្ញុំថាត្រឹមត្រូវ ក៏ខ្ញុំមិនដឹងថាឆ្លើយយ៉ាងម៉េចដែរ តែសម្រាប់ខ្ញុំៗអត់ដឹងហ្នឹង ឲ្យខ្ញុំទៅថាម៉េច។ អ៊ីចឹងបានខ្ញុំឆ្លើយថា អត់ដឹង អ៊ីចឹងអស់លោកនៅតែជជែកសួរខ្ញុំទៀត។ អ៊ីចឹងខ្ញុំអត់ដឹងឆ្លើយយ៉ាងម៉េចទេ ខ្ញុំអត់ អាហ្នឹងសំខាន់លើ--

**ប្រធានអង្គជំនុំ៖**

កន្លែងណាលោកអត់ដឹង ឆ្លើយថាអត់ដឹងទៅណា។ បើកន្លែងថាសំណួរមិនច្បាស់លាស់ លោកបានសួរហើយ បើសំណួរមិនច្បាស់លាស់លោកស្ដាប់មិនយល់ ឬក៏ស្ដាប់ន័យវាមិនបានច្បាស់លាស់ទេ សុំឲ្យគេតាំងសំណួរសាជាថ្មីម្ដងទៀត។ បាទ ហើយសំណួរណាដែលលោកដឹង លោកឆ្លើយតប ដូចជាមិនមែនជាលំបាកប៉ុន្មានទេ។

អ៊ីចេះៗ បញ្ហាមានការសួរ សួរបញ្ជាក់ឡើងវិញ អ្វីដែលលោកឆ្លើយមកគេបូកសរុបនូវចម្លើយហ្នឹងដើម្បីបញ្ជាក់ឡើងវិញ ថាបញ្ហាហ្នឹងវាជាត្រឹមត្រូវដែរឬទេ ព្រោះលោកឆ្លើយរួចហើយ។ អ៊ីចឹងគេបូកសរុបនូវចម្លើយរបស់លោក សួរបញ្ជាក់លោកឡើងវិញ ថាតើវាត្រឹមត្រូវដែរទេ ចម្លើយរបស់លោកអ៊ីចឹង ឃើញទេ! ឬក៏ការយល់ បានន័យថា គាត់ស្ដាប់ការបកប្រែភាសាយើងទៅ ហើយសរុបមកវិញគាត់យល់ថាចម្លើយរបស់លោកដែលឆ្លើយមុនៗ ដែលលោកឆ្លើយថាអ៊ីចឹង ដែលគាត់យល់ថា ចម្លើយលោកដែលលោកឆ្លើយអ៊ីចឹង ត្រឹមត្រូវដែរឬអត់? លោកថាត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវទៅ វាជារឿងមួយចប់ហើយ ជាការឆ្លើយតបនឹងសំណួរហើយ។ យើងបានប្រើពាក្យអំមិញហើយ ច្បាស់លាស់ហើយនៅក្នុងនីតិវិធី គេប្រើពាក្យថា "សួរដេញដោលនៅចំពោះមុខតុលាការ" ប្រហែលជាអាចប្រឈមមកពីលោកមិនធ្លាប់ជួបប្រទះស្ថានភាពនេះ។ អ៊ីចឹង ជាលើកដំបូងដែលលោកអាចពិបាកទ្រាំបន្តិច ប៉ុន្តែរឿងនីតិវិធីរបស់តុលាការគឺដូច្នេះ។ តុលាការណាដូចតុលាការណាដែរ មិនខុសគ្នាទេពាក្យថាតុលាការហ្នឹង។

[១១:១១:២៨]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ដើម្បីរំឭកដល់ការចងចាំរបស់លោក រឿងរ៉ាវរបស់បងរបស់លោក គឺឯកសារ E3/2653 ERN ជាភាសាអង់គ្លេសគឺ 00219145, ERN ជាភាសាខ្មែរគឺ 00904323។ សុំដកស្រង់ជាភាសាអង់គ្លេស៖ "ពីកន្លែងដែលខ្ញុំឈរ ខ្ញុំឃើញខ្មែរក្រហមគឺថាជាកម្មាភិបាលស្រុក និងជាកងទ័ពស្រុកក្រូចឆ្មារ។" បញ្ចប់ការដកស្រង់។ បើតាមរឿងរ៉ាវរបស់បងប្រុសរបស់លោកហ្នឹង គាត់<ទំនងជាដឹងថាជា> យោធាស្រុក។ តើការខ្ញុំអានសម្រង់ជូនអម្បាញ់មិញនេះធ្វើឲ្យលោកនឹកឃើញដែរឬទេ ឬក៏លោកនៅតែប្រកាន់ចម្លើយថា លោកមិនដឹងថាយោធាហ្នឹងមកពីណាទេ?

**លោក សុះ ពន់យ៉ាមីន៖**

**ឆ៖** ខ្ញុំអត់ដឹង ដោយសារខ្ញុំអត់ស្គាល់យោធា។ បើខ្ញុំស្គាល់ថាយោធាហ្នឹងមកពីណាៗ ខ្ញុំប្រាប់ថាខ្ញុំដឹងហើយ។ ឥឡូវ ខ្ញុំអត់ដឹងទេ។ ហើយពាក្យសម្ដី ដូចថា គោលការណ៍ដែលយកមកមិនមែនជាខ្ញុំទេ បងខ្ញុំទេ។ អ៊ីចឹងបងខ្ញុំគេស្គាល់យោធា គេស្គាល់អី ហ្នឹងខ្ញុំអត់ដឹងទេ ឯសម្រាប់រូបខ្ញុំ ខ្ញុំអត់ដឹងមែន។

**ស៖** ទាក់ទងនឹងអ្នក មេខ្លោងនៃការបះបោរនៅក្នុង<ភូមិរបស់លោក គឺ>ភូមិទី៥នៃឃុំស្វាយឃ្លាំងហ្នឹង។ តើលោកអាចជម្រាបឈ្មោះមេខ្លោងទាំងអស់ហ្នឹងជូនតុលាការបានដែរឬទេ<? តើនរណាខ្លះជា>មេខ្លោង<នៃការបះបោរ>នៅភូមិទី៥ហ្នឹង?

**ឆ៖** មេខ្លោង ពាក្យថា "មេខ្លោង" វាពាក្យពិបាកស្ដាប់ណាស់។ ខ្ញុំមិនជំទាស់ទេ ប៉ុន្តែសួរថាខ្ញុំធ្វើហ្នឹងដើម្បីស្អី ហើយកម្ពុជាម៉ោងហ្នឹងវាត្រូវ ពេលហ្នឹង សង្គមហ្នឹងវាយ៉ាងម៉េចអីយ៉ាងម៉េច អាហ្នឹងហើយអ្នកលំបាកវេទនានៅពេលនោះ។ អ៊ីចឹងវាត្រូវទាំងអស់មួយកម្ពុជាហ្នឹង ទាំងអស់ មិនត្រូវតែភូមិ៥ចាមខ្ញុំទេ។ អ៊ីចឹងពាក្យថា "មេខ្លោង" ហ្នឹងវាពិបាកស្ដាប់បន្តិច។

**ស៖** បើលោកមិនយល់ពាក្យហ្នឹង ខ្ញុំសុំប្រើពាក្យផ្សេងវិញ។ តើអ្នកណាជាអ្នកដឹកនាំការបះបោរនៅក្នុងភូមិទី៥របស់លោកហ្នឹង? លោកអាចជម្រាបជូនឈ្មោះគាត់ហ្នឹង ពួកគាត់ទាំងអស់ជូនតុលាការបានទេ?

**ឆ៖** ខ្ញុំបានជម្រាបតាំងពីម្សិលមកហើយ បញ្ហាហ្នឹង អ៊ីចឹងខ្ញុំមិនអាចនិយាយពីរបីដងបានទេ។ អ៊ីចឹងវា ខ្ញុំជម្រាបរួចហើយ។

[១១:១៥:១៦]

**ស៖** ខ្ញុំសូមចោទសំណួរបែបផ្សេងវិញ។ ក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយនឹងលោក អ៊ីសា ឧស្មាន គឺឯកសារ E3/9136, ERN ជាភាសាបារាំងគឺ <01128378>, ERN ជាភាសាខ្មែរគឺ 00046394, ជាភាសាអង់គ្លេស 01133242 សំណួរលោក ឧស្មាន សួរលោកដូចតទៅនេះ៖ “ពេលដែលខ្មែរក្រហមមក<ឡោម>ព័ទ្ធភូមិ <តើ>លោកនៅឯណា? ចម្លើយលោកដូចតទៅនេះ៖ ខ្ញុំមិននៅ<តែមួយ>កន្លែងទេ<ពីព្រោះ>ខ្ញុំត្រូវដឹកនាំចលនា<បះបោរ>ហ្នឹង <ដូច្នេះ>ខ្ញុំមិន<អាច>នៅមួយកន្លែងទេ<។> ខ្ញុំ<បានចាត់ចែងឲ្យ>អ្នក<ខ្លះនៅ>កន្លែង<នេះ> ហើយអ្នក<ខ្លះ>ទៀត<នៅ>កន្លែង<នោះ។ ខ្ញុំត្រូវរត់ចុះឡើង> ហើយ<ទៅពិនិត្យមើល>ខ្សែត្រៀម ព្រោះយើងខ្លាចថា គេរត់ចោលជួរ។ អ៊ីចឹងខ្ញុំដើរជាមួយ ឡិប វ៉ាន់ម៉ាត់ ជួនកាលខ្ញុំសូមឲ្យគាត់ទៅភូមិទី៥ ហើយឯចំណែកខ្ញុំ ខ្ញុំនៅភូមិទី៦ ឬក៏យើងឆ្លាស់គ្នាទៅវិញទៅមក។” សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ តើនៅក្នុងចម្លើយរបស់លោក<ដែល>លោកឆ្លើយទៅលោក អ៊ីសា ឧស្មាន វាជាការត្រឹមត្រូវដែរឬទេ ដែលថាលោកហ្នឹង លោកបង្ហាញណែនាំខ្លួនឲ្យគេស្គាល់ថា លោកជាអ្នកដឹកនាំចលនា<បះបោរ>ហ្នឹង <នៅក្នុង>ភូមិទី៥ <និងភូមិ>ទី៦<>?

**ឆ៖** ពិតហើយ។

**ស៖** ឥឡូវខ្ញុំសូមអានសម្រង់មួយទៀត នៃចម្លើយរបស់បងប្រុសរបស់លោក ដែលឆ្លើយនៅចំពោះមុខចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5205។ ERN ជាភាសាបារាំងគឺ 00293921, ERN ជាភាសាអង់គ្លេសគឺ 00275163, ERN ជាភាសាខ្មែរគឺ 00221849 ទៅដល់ <50>។ សំណួរដែលអ្នកស៊ើបអង្កេតសួរទៅបងប្រុសរបស់លោក ដូចតទៅនេះ៖ “តើអ្នកណាជាអ្នកដឹកនាំការបះបោរ? ចម្លើយរបស់គាត់៖ អ្នកដែលគេចោទប្រកាន់ថា ជាអ្នកដឹកនាំនោះ <គឺជាក្មេងប្រុស>មានអាយុ<១៥>ឆ្នាំ គាត់ឈ្មោះ<> ឡិប វ៉ាន់ម៉ាត់ <ដែលបានស្លាប់បាត់ហើយកាលពីប៉ុន្មានឆ្នាំមុន>។ <ប៉ុន្តែ>ពេលៗដែលគេសួរខ្ញុំនៅក្នុងសាលានោះ ខ្ញុំឆ្លើយប្រាប់គេថា <អ្នកដឹកនាំនោះ>គឺឈ្មោះ ជី ក្រឹម ហើយគាត់ហ្នឹង<ជាអ្នក>ប្រកាសតាមមីក្រូព្រះវិហារហ្នឹងឲ្យប្រជាជនទាំងអស់ក្រោកបះបោរ។” សំណួររបស់ខ្ញុំ បើតាមមើលបងប្រុសរបស់លោកនុ៎ង មិនបានរៀបរាប់លោកក្នុងចំណោមអ្នកដឹកនាំការបះបោរនោះទេ។ តើ<លោកធ្លាប់ឮ>ឈ្មោះ ជី ក្រឹម នេះ<>ទេ<? តើលោកអាចជម្រាបជូនតុលាការបានទេ តើ>ឈ្មោះ ជី ក្រឹម <នេះជានរណា?>?

[១១:១៩:១៧]

**ឆ៖** ខ្ញុំស្គាល់។

**ស៖** តើនៅក្នុងភូមិទី៥ និងភូមិទី៦ហ្នឹង គាត់មានតួនាទីអីច្បាស់លាស់ជាក់លាក់ទេ?

**ឆ៖** ខ្ញុំមិនអាចដឹងបានពីបញ្ហាភូមិទី៦ទេ ព្រោះខ្ញុំនៅភូមិទី៥។ អ៊ីចឹង ជី គ្រឹម ហ្នឹងនៅភូមិទី៦ បងខ្ញុំនៅភូមិទី៦។

**ស៖** តើលោកដឹងដែរឬទេ ថាតើ ជី គ្រឹម នេះគាត់បានប្រកូកប្រកាសតាមមីក្រូចេញពីព្រះវិហារដែរឬទេ?

**ឆ៖** ខ្ញុំក៏មិនបានដឹងដែរ ព្រោះគេនៅភូមិគេ។

**ស៖** <ប្រហែលជា>ខ្ញុំមិនយល់ <ឬ>ប្រហែលជាមានបញ្ហាបកប្រែឬក៏យ៉ាងណា ព្រោះថាចម្លើយមុនហ្នឹង អម្បាញ់មិញហ្នឹង លោកឆ្លើយថា លោកស្គាល់ឈ្មោះ ជី គ្រឹម ពីព្រោះថា<>គាត់នៅភូមិទី៦ ដូចបងប្រុសលោកដែរ ហើយខ្ញុំនិយាយតែឈ្មោះ ជី គ្រឹម ហ្នឹងដដែលទេ។ ខ្ញុំសួរលោកថាតើ ជី គ្រឹម ហ្នឹងពិតជាបានប្រកាសតាមមីក្រូចេញពីព្រះវិហារមែនដែរឬទេ?

**ឆ៖** ខ្ញុំថា ខ្ញុំអត់ដឹង ព្រោះ ជី គ្រឹម គាត់នៅភូមិទី៦ បងខ្ញុំក៏នៅភូមិទី៦ ខ្ញុំនៅភូមិទី៥។ អ៊ីចឹងបានខ្ញុំអត់ដឹងត្រង់កន្លែងហ្នឹង ការងារគេធ្វើនៅភូមិទី៦ ខ្ញុំនៅភូមិទី៥ ខ្ញុំធ្វើម៉េចហ្នឹងដឹង។

[១១:២១:៣០]

**ស៖** ប៉ុន្តែ<>ខ្ញុំ<គិតថាខ្ញុំបានយល់ពីសក្ខីកម្មរបស់លោកដែល>លោកបានបញ្ជាក់តាមរយៈសម្រង់ដែលខ្ញុំអានជូនលោកស្តាប់នេះ ដែលលោកផ្តល់កិច្ចសម្ភាសន៍ជាមួយលោក ឧស្មាន។ ខ្ញុំរំឭកឡើងវិញ ERN ជាភាសាបារាំងគឺ <01128378>, ERN ជាភាសាខ្មែរគឺ <0046394>, ERN ជាភាសាអង់គ្លេសគឺ <001133242>។ លោកឆ្លើយ៖ "ខ្ញុំដើរជាមួយ ឡិប វ៉ាន់ម៉ាត់ ជូនកាលខ្ញុំសុំឱ្យគាត់ទៅភូមិទី៥ ហើយចំណែកខ្ញុំ ខ្ញុំនៅក្នុងភូមិទី៦ <ឬក៏>យើងផ្លាស់គ្នាទៅវិញទៅមក។" បើតាមចម្លើយនេះ ខ្ញុំ<យល់>ឃើញថាមានកិច្ចសហការជាមួយគ្នារវាងភូមិទី៥ និងភូមិទី៦ ហើយគឺថាលោកអាចចេញពីភូមិទី៥ ទៅភូមិទី៦ ឬត្រឡប់មកវិញបាន។ អ៊ីចឹង<ផ្អែកតាមលក្ខខណ្ឌនេះ> តើលោកប្រាកដដែរឬទេ<> ដែលពេលដែលលោកនិយាយថា លោកមិនដឹងថា មានរឿងអ្វីកើតឡើងនៅភូមិទី៦ហ្នឹង?

**ឆ៖** ឥឡូវខ្ញុំសូមបកស្រាយឱ្យច្បាស់។ ពាក្យថាខ្ញុំដើរ មិនមែនខ្ញុំនៅទេ។ អ៊ីចឹងពាក្យ អាមួយ "ដើរ" អាមួយ "នៅ" ហ្នឹងវាខុសគ្នា។ អ៊ីចឹងធម្មតា ខ្ញុំដើរទៅភូមិ៦ ដើរភូមិទី៥ ខ្ញុំដើរ។ ឯណាចំណែកគោលការណ៍ គេនៅភូមិទី៦ សម្រាប់មេដឹកនាំគេហ្នឹង អាហ្នឹងជារឿងរបស់គេផ្សេង។ ខ្ញុំចង់បញ្ជាក់

អ៊ីចឹង។ ហើយវានៅសហការគ្នាមែន ក៏ប៉ុន្តែខ្ញុំដើរទៅមកៗ។

**ស៖** ខ្ញុំគិតថា ប្រហែលជាយើងមិនយល់គ្នាហើយ និយាយពីព្រឹត្តិការណ៍ដែលខ្ញុំកំពុងនិយាយហ្នឹង ខ្ញុំមិននិយាយថានៅក្នុងអតីតកាលហ្នឹង ថាលោក<ពិតជាអាចដើរ>ពីភូមិទី៥ ទៅភូមិទី៦អីនោះទេ។ ខ្ញុំចង់និយាយ<ជាក់លាក់ទៅលើ>ថ្ងៃបះបោរតែម្តង<។> ខ្ញុំបានដកស្រង់អម្បាញ់មិញ<នូវផ្នែកមួយនៃចម្លើយនោះ ហើយខ្ញុំបាននិយាយ>ជាទូទៅ<មុននេះ> គឺថានិយាយសំដៅទៅលើការងារលោកជាអ្នកដឹកនាំចលនាបះបោរហ្នឹង <ឬក៏ជាមេនាំមុខការបះបោរនៅពេលនោះ>។ ហើយលោក ពេលអំមិញហ្នឹងឆ្លើយថា លោកត្រូវផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយក្នុងពេលបះបោរហ្នឹង។ ហើយនៅក្នុងបរិបទហ្នឹងហើយ ដែល<លោក>និយាយអំពីការផ្លាស់ទី<របស់>លោកទៅភូមិទី៦។ <ដូច្នេះរឿងនេះស្ថិតនៅក្នុងបរិបទនៃការបះបោរ។> តើ<អ្វីដែល>លោកឆ្លើយទៅលោក <អ៊ីសា> ឧស្មាន ហ្នឹង <តើ>លោកឆ្លើយច្រឡំឬក៏យ៉ាងម៉េច<? តើ> លោកអាចពន្យល់<ចំណុចនេះ>បាន<ទេ>?

[១១:២៤:៤៤]

**ឆ៖** ខ្ញុំមិនដឹងដែរ តែសម្រាប់ខ្ញុំ ឆ្លើយបានតែប៉ុណ្ណឹង។ ឯចំណែក ឧស្មាន គេបកប្រែយ៉ាងម៉េចខ្ញុំអត់ដឹងទេ។ តែសម្រាប់ខ្ញុំ ឆ្លើយបានតែប៉ុណ្ណឹង។ ព្រោះការងារខ្ញុំបានតែប៉ុណ្ណឹង ហើយខ្ញុំធ្វើតែប៉ុណ្ណឹង។

**ស៖** ដើម្បីឱ្យច្បាស់លាស់ជាងហ្នឹងទៅទៀត អ្វីដែលខ្ញុំដកស្រង់នុ៎ង មិនត្រូវគ្នាទៅនឹងអ្វីដែល ឧស្មាន បានសរសេរដោយខ្លួនឯងពេលក្រោយទេ។ ហើយ<ទីនេះ យើងនិយាយអំពី>កំណត់ហេតុនៃកិច្ចសម្ភាសន៍ជាមួយលោក<ដែលមានសំណួរចម្លើយនៅក្នុងហ្នឹង>។ ដើម្បីរំឭកដល់ការចងចាំរបស់លោក <ដោយសារខ្ញុំបានអានពីមុនរួចម្តងហើយ> ឥឡូវខ្ញុំសូមអានឡើងវិញនូវផ្នែកមួយដែលមានលេខ ERN ជាភាសាបារាំងគឺ 01128378, ERN ជាភាសាខ្មែរគឺ 00046394, ERN ជាភាសាអង់គ្លេសគឺ 01133242។ សំណួររបស់ អ៊ីសា ឧស្មាន៖ “ពេលខ្មែរក្រហមមក<ឡោម>ព័ទ្ធភូមិហ្នឹង<តើ>លោកនៅឯណា?” <>នេះ<ជាអ្វីដែល>លោកនិយាយ មិនមែន អ៊ីសា ឧស្មាន អ្នកនិយាយទេ<។ នៅក្នុងករណីណាក៏ដោយ នេះជាអ្វីដែលបានបង្ហាញនៅក្នុង>ឯកសារដែលយើងមាន<។ លោកបាននិយាយថា៖ “>ខ្ញុំមិនមែននៅតែមួយកន្លែងនោះទេ ព្រោះខ្ញុំត្រូវដឹកនាំចលនាបះបោរ ហើយខ្ញុំមិនអាចនៅមួយកន្លែងបានទេ។ ខ្ញុំត្រូវតែចេញបញ្ជាឱ្យមនុស្សទៅកន្លែងនេះ កន្លែងនោះ ទៅកន្លែងផ្សេងគ្នា។ ខ្ញុំត្រូវផ្លាស់ទី ហើយនិងទៅត្រួតពិនិត្យមើលខ្សែត្រៀម ខ្ញុំខ្លាចគេរត់ចោលជួរ។ ខ្ញុំដើរ<មើល>ជាមួយ ឡិប វ៉ាន់ម៉ាត់ ជួនកាលខ្ញុំឱ្យគាត់ទៅភូមិទី៥ទៅ ហើយខ្ញុំៗនៅភូមិទី៦ ជួនកាលយើងផ្លាស់គ្នា គាត់មកភូមិនេះ ខ្ញុំ

ទៅភូមិនោះអ៊ីចឹងទៅ។" ខ្ញុំសូមបញ្ចប់ការដកស្រង់។ តើខ្ញុំដកស្រង់នេះធ្វើឲ្យលោកនឹកឃើញទេ?

[១១:២៧:១៣]

**ឆ៖** ខ្ញុំនឹកឃើញ។ អ្វីដែលខ្ញុំនិយាយ ខ្ញុំអត់បដិសេធណា។ ប៉ុន្តែស្តាប់ខ្ញុំឲ្យបានថា ខ្ញុំទៅមក ហើយភូមិនេះជាភូមិរបស់គេ។ រួចលោកស្រីចេះតែសួរឈ្លេចខ្ញុំ ដូចពិបាកឆ្លើយដល់ហើយនេះ។ អ៊ីចឹង ក្នុងនាមខ្ញុំនៅភូមិទី៥ បងខ្ញុំនៅភូមិទី៦ រួច ជី ក្រឹម នៅភូមិទី៦។ អ៊ីចឹងក្នុងនាមប្រាស្រ័យទាក់ទងគ្នាបាន តែត្រឹមទាក់ទងគ្នា រឿងអ្វីផ្សេង អាហ្នឹងការងារភូមិទី៦ គេផ្សេង ខ្ញុំហ្នឹងផ្សេង គ្រាន់តែទាក់ទងគ្នាតែ ប៉ុណ្ណឹង។ ឥឡូវខ្ញុំបកស្រាយវាអស់ប៉ុណ្ណឹងហើយ អើ បើលោកស្រីស្តាប់មិនបាន ខ្ញុំក៏មិនដឹងធ្វើម៉េចដែរ។

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំលើប្រធានបទនេះ។ ខ្ញុំសូមរំឭកផងដែរថា នៅក្នុងបរិបទ នេះ គឺថាខ្ញុំមិននិយាយ <អំពីអ្វីដែលកើតឡើងនៅក្នុង>ភូមិទី៦ នៅពេលណាផ្សេងទេ <គឺ>ខ្ញុំនិយាយតែ ថ្ងៃបះបោរហ្នឹងទេ។ ហើយចម្លើយដែលលោកផ្តល់ឲ្យ អ៊ីសា ឧស្មាន ហ្នឹងគឺលោកទៅមករវាងភូមិទាំង ពីរហ្នឹង។ ខ្ញុំយល់ចម្លើយលោកហើយ ក៏ប៉ុន្តែខ្ញុំមិនមែននិយាយអំពីភូមិទី៦ ហ្នឹងនៅថ្ងៃណាផ្សេង ជា ទូទៅនោះទេ គឺនិយាយសំដៅតែថ្ងៃបះបោរហ្នឹងទេ។ ហើយលោកនិយាយថា នៅថ្ងៃហ្នឹងលោកទៅភូមិ ទី៦ដែរ។ អ៊ីចឹងហើយបានខ្ញុំសួរសំណួរហ្នឹងៗ។ ឥឡូវលោកយល់ខ្ញុំច្បាស់ហើយឬនៅ?

**ឆ៖** ខ្ញុំយល់ច្បាស់ហើយបាទ ឥឡូវខ្ញុំយល់ច្បាស់ហើយ។ ខ្ញុំនិយាយហ្នឹងសំដៅនៅថ្ងៃបះបោរ ហ្នឹង ខ្ញុំមិននិយាយថ្ងៃណាទេ។ ហើយនិយាយពីរឿងមេបះបោរ ជី ក្រឹម ហ្នឹង ក៏សំដៅនៅថ្ងៃបះបោរ ហ្នឹងដែរ មិនមែនអីតែម្នាក់ខ្ញុំទេ ព្រោះភូមិគេមេគេផ្សេង។ តែសម្រាប់ខ្ញុំដើរទៅមក សម្រាប់ទាក់ទងគ្នា ប្រាស្រ័យទាក់ទងគ្នា តែប៉ុណ្ណឹង។ ឥឡូវខ្ញុំអត់មានពាក្យអីត្រូវការប្លែកជាងហ្នឹងទេ ហើយខ្ញុំមិនមែនឆ្លើយ ពង្វាងរឿងដើម្បីដោះស្រាយរឿងអស់ទេ។ ខ្ញុំអត់បដិសេធទេ រឿងខ្ញុំប៉ុន្មាន ខ្ញុំសម្អាសប៉ុន្មាន ខ្ញុំទទួល ស្គាល់ទាំងអស់។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធានខ្ញុំនៅសំណួរចុងក្រោយខ្លីទេ ប៉ុន្តែមេធាវី គង់ សំអុន គាត់មានសំណួរមួយចំនួន ដើម្បីសួរទៀតដែរលោកប្រធាន។ <ដូច្នេះខ្ញុំមិនដឹងថាតើលោកប្រធានចង់ឲ្យយើងបញ្ចប់ការតាំងសំណួរ ទៅសាក្សីឥឡូវនេះតែម្តង ឬ>លោកប្រធានចង់ឲ្យខ្ញុំសួរឲ្យចប់ហើយ ឲ្យលោកមេធាវី គង់ សំអុន ចូល សួរនៅពេលសម្រាកពិសាបាយថ្ងៃត្រង់ហើយលោកប្រធាន។

[១១:៣០:០០]

**ប្រធានអង្គជំនុំ៖**

ទំនងត្រូវការពេលវេលាប៉ុន្មានទៀតទៅ? យើងគិតថា យើងផ្តល់ពេលវេលា១៥នាទីទៀត បើសិនជាអាចធ្វើចប់។ អ៊ីចឹងហើយបានជាយើងព្យាយាមក្នុងការពន្លឿនពេលវេលា ជួសជុលឡើងវិញ ដោយការសម្រាកហ្នឹង តែ១០នាទីអំមិញ។ បាទ បើយើងមិននិយាយថា១០នាទីទេ យើងថាសម្រាកពីណេះទៅណោះតែម្តង ប៉ុន្តែម៉ោងគឺតែ១០នាទីទេ ក្នុងនិយាយជួសជុលឡើងវិញ នូវពេលវេលាដែលបានប្រើប្រាស់ដើម្បីឲ្យត្រឹមត្រូវតាមអ្វីដែលអង្គជំនុំជម្រះ។ ១៥នាទីទៀត សមស្រប។

**កញ្ញា អង់តា ហ្គីសសេ៖**

នៅក្នុងលក្ខខណ្ឌនេះ អ៊ីចឹង ខ្ញុំសូមបញ្ចប់សំណួររបស់ខ្ញុំតែម្តង ហើយទុកឲ្យលោកមេធាវី គង់ សំអុន សួរបន្ត លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំចង់សួរបញ្ជាក់សំណួរមួយ ដែលខ្ញុំបានជំទាស់ពីមុន ទាក់ទងទៅនឹងភូមិ។ ជាពិសេស លោកបានឆ្លើយអំពីឈ្មោះភូមិស្វាយឃ្លាំង ហើយក្រោយមកក៏មានលើកឡើងរបស់សហព្រះរាជអាជ្ញាជាតិថា ឈ្មោះភូមិហ្នឹង ត្រូវបានកើតជាភូមិតូចៗផ្សេងទៀត ភូមិទី១, ទី២, ទី៣ អ៊ីចឹងគឺក្រោយពីឆ្នាំ១៩៧៥។ ខ្ញុំចង់ឲ្យលោកបញ្ជាក់មើល ថាតើនៅក្នុងភូមិរបស់លោកហ្នឹង គឺវាកើតឡើងដាក់ឈ្មោះថា ភូមិទី១, ទី២, ទី៣ ដល់ទី៧ហ្នឹង នៃឃុំស្វាយឃ្លាំងហ្នឹង ពីពេលណាដែរ?

**លោក សុះ ពន់យ៉ាមីន៖**

**ឆ៖** ភូមិស្វាយឃ្លាំងចាប់ផ្តើមដាក់ឈ្មោះតាំងពីពេលខ្មែរក្រហមមកហើយ មិនមែន៧៩ទេ ប៉ុន្តែស្វាយឃ្លាំង មុនឆ្នាំ១៩៧២, ៧៣ហ្នឹង គេហៅថា ស្វាយឃ្លាំងទេ អត់មានដាក់ទី១, ទី២ ទេ។ អ៊ីចឹងដាក់ពីពេលខ្មែរក្រហមមកហើយ។ អ៊ីចឹងបានន័យថា ភូមិស្វាយឃ្លាំងទី៥ ជំនាន់ខ្មែរក្រហមមានភូមិទី៦ទៀត ភូមិចាមតែមួយហ្នឹង ប៉ុន្តែមនុស្សវាច្រើនពេក វាបែងចែកថា ភូមិទី៥, ភូមិទី៦។ ឥឡូវក្រោយ

រំដោះមក គេដាក់តែ ភូមិទី៥ តែមួយ។ អាហ្នឹង សូម--។

**ស៖** អ៊ីចឹង បើតាមខ្ញុំយល់មិនច្រឡំទេ គឺការបែងចែកភូមិទី១, ទី២, ទី៣ ហ្នឹង គឺប្រហែលក្នុងឆ្នាំ៧៣។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងឯកសារ E3/9139 ទាក់ទងនឹងឈ្មោះភូមិនេះដែរ លោកបានបញ្ជាក់នៅក្នុងឯកសារនេះ វាខ្លី វានៅក្នុងទំព័រចុងក្រោយសម្រាប់ទាំងបីភាសា គឺទំព័រចុងក្រោយគេបំផុត។ លោកបានបញ្ជាក់ទៅលើប្រជាជនចាមដែលរស់នៅក្នុងភូមិ៥ ភូមិ៦ និងភូមិ៧។ តើលោកនៅចាំទេថា ភូមិទាំងបីនេះ គឺជាភូមិរបស់ចាមសុទ្ធតែម្តង ឬមួយក៏មានជនជាតិខ្មែរលាយ រស់នៅលាយគ្នានៅក្នុងភូមិនេះដែរ?

[១១:៣៤:៣៦]

**ឆ៖** ភូមិទី៥ ភូមិទី៦ ប្រជាជនចាមសុទ្ធ ពីរភូមិហ្នឹង។ ហើយភូមិទី៧ លាយចម្រុះគ្នា លាយចម្រុះ ប៉ុន្តែនៅដោយឡែកគ្នា ក៏ប៉ុន្តែក្នុងភូមិហ្នឹង គេចាត់ទុកភូមិ -- ដាក់ភូមិទី៧ វានៅចម្រុះគ្នា។ អ៊ីចឹងខ្ញុំមិនដឹងភាគរយប៉ុន្មានអីប៉ុន្មាន ខ្ញុំអត់ដឹងដែរ។ ប៉ុន្តែភូមិពីរហ្នឹង ភូមិទី៥ ភូមិទី៦ ចាមសុទ្ធ តែភូមិទី៧ វាចូលចម្រុះគ្នា។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់កន្លងមកពីចំនួនប្រជាពលរដ្ឋចាម ដែលរស់នៅក្នុងភូមិទី៥ និងទី៦ ហើយអាចថា បូកជាមួយនឹងទី៧ ខ្លះទៀត។ តាមឯកសារដដែលនេះ លោកបានបញ្ជាក់ថា មានចំនួន១.២៤២គ្រួសារ ហើយលោកបានបញ្ជាក់ថា នៅក្នុងឆ្នាំ៧០។ តើចំណុចនេះ លោកនៅប្រកាន់ថា ជាចំណុចត្រឹមត្រូវ ឬក៏មិនមែនឆ្នាំ៧០ទេ បានន័យថា ក្រោយឆ្នាំ៧០ទេ?

**ឆ៖** ខ្ញុំយល់ថា ត្រឹមត្រូវ។

**ស៖** ត្រឹមត្រូវៗទាំងពីរចំណុច ទាំងឆ្នាំ១៩៧០ និងចំនួនប្រជាពលរដ្ឋចាមដែលរស់នៅក្នុងភូមិទាំងបីនោះ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ មែន ទាំងពីរចំណុច។

**ស៖** ប៉ុន្តែចំណុចបន្ទាប់មកទៀត សំណួរបន្ទាប់មកទៀតដែល ឧស្ទាន សួរលោកថា៖ "តើលោកបានស្ថិតិមកពីណា? លោកឆ្លើយថា ខ្ញុំសូមដកស្រង់៖ ដឹងច្បាស់ ព្រោះពេលនោះ មានសហករណ៍គេហើយ មួយសហករណ៍មាន៥០គ្រួសារ អ៊ីចឹងគ្រប់សហករណ៍ទូទាត់ទៅនៅពេលនោះ ឃើញ

១២៤២គ្រួសារ។" បាទ សូមបញ្ចប់ការដកស្រង់។ លោកចាំសម្ដីនេះទេ ជាសម្ដីរបស់លោកទេ?

**ឆ៖** ពិតមែនហើយ សម្ដីនេះជាសម្ដីរបស់ខ្ញុំពិត។

[១១:៣៧:២៦]

**ស៖** អ៊ីចឹងបានន័យថា លោកដឹងហ្នឹងក្រោយពេលដែលមានសហករណ៍ហើយ ហើយបើតាមលោកមានប្រសាសន៍មុនអំមិញថា ខ្មែរក្រហមចូលកាន់កាប់នៅក្នុងតំបន់របស់លោក ក្នុងភូមិរបស់លោកហ្នឹង គឺឆ្នាំ៧៣។ បើអ៊ីចឹងមិនឆ្នាំ៧០ទេ លោកយល់ស្របអ៊ីចឹងទេ?

**ឆ៖** បាទៗ ខ្ញុំយល់ស្រប ព្រោះឆ្នាំ៧០ មិនទាន់ខ្មែរក្រហមចូលដល់ទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងចំនួនដែលលោកបាន ដែលលោកថា ក្រោយពីមានសហករណ៍ហើយនេះ តើលោកបានព័ត៌មានពីចំនួនហ្នឹងពីសហករណ៍នីមួយៗហ្នឹងដោយរបៀបណាដែរ?

**ឆ៖** ខ្ញុំបានចំនួនពីសហករណ៍នីមួយៗ វាងាយស្រួលនឹងគេប្រាប់ ប៉ុន្តែយើងសួរតាមរឿងសាមញ្ញ -- តាមសាមញ្ញនោះក៏បានដែរ ព្រោះសហករណ៍មួយៗគេដាក់៥០គ្រួសារ។ អ៊ីចឹងគ្រប់សហករណ៍ទាំងអស់ហ្នឹង យើងអាចក្ដាប់បានតាមរយៈប្រធានសហករណ៍ហ្នឹង។

**ស៖** លោកអាចបញ្ជាក់ផងបានទេ ថាលោកក្ដាប់បានពីប្រធានសហករណ៍ហ្នឹង ដោយរបៀបណា? ប្រធានសហករណ៍ត្រូវរាយការណ៍មកលោក ឬក៏មានការប្រជុំយ៉ាងម៉េចដែរ ទាក់ទងនឹងព័ត៌មានទាំងនេះ?

**ឆ៖** ខ្ញុំមិនមែនសហករណ៍ត្រូវរាយការណ៍មកខ្ញុំទេ ព្រោះខ្ញុំមិនមែនជាមន្ត្រី -- ថ្នាក់ដឹកនាំអីទេ ក៏ប៉ុន្តែខ្ញុំសួរតាមរយៈសាមញ្ញដូចថា ធម្មតាៗ ឧទាហរណ៍ថា យើងជួបគ្នាទៅ អ៊ូ! សហករណ៍អ្អែងប៉ុន្មាន អីមួយភូមិហ្នឹងប៉ុន្មាន អីប៉ុន្មាន អាហ្នឹងអ៊ីចឹងទេ។ ព្រោះខ្ញុំអត់មានត្រូវគេរាយការណ៍អ៊ីចឹង ហើយខ្ញុំត្រួតពិនិត្យផ្ទាល់ហ្នឹង គឺឃើញដូច្នោះមែន។

**ស៖** បាទ សូមអរគុណ។ លោកអាចឆ្លើយជាក់លាក់បានទេថា លោកសួរអ្នកណាគេ?

**ឆ៖** ខ្ញុំដូចជាភ្លេចភ្លាំងអស់ហើយ ឈ្មោះនោះ ព្រោះអាអ្នកខ្ញុំសួរនោះក៏វាស្លាប់ទៅ អីទៅ ដូចវាភ្លេចអស់ហើយ ខ្ញុំសុំទោស ព្រោះវាយូរហើយ។

[១១:៤០:២១]

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់ខាងដើមអំមិញថា ក្នុងមួយសហករណ៍មាន៥០

គ្រួសារ។ ចុះលោកដឹងថា ក្នុងទាំងបីភូមិហ្នឹងមាន ប៉ុន្មានសហករណ៍ទេ?

**ឆ៖** អាហ្នឹងខ្ញុំដូចថាយើងមិននេះទេ ប៉ុនកាលនុ៎ងខ្ញុំ យើងគុណមើលទៅមួយសហករណ៍ បូក មើលទៅមួយសហករណ៍វា៥០គ្រួសារ។ អ៊ីចឹងខ្ញុំបូកកាលហ្នឹង វា១២៤២គ្រួសារ អ៊ីចឹងខ្ញុំដូចថា ខ្ញុំមិន អាចមកសរុបនៅពេលនេះ ពេលវេលានេះ ខ្ញុំសរុបមិនបានទេ ប៉ុន្តែខ្ញុំដឹងច្បាស់ថាពេលហ្នឹងខ្ញុំសរុបទៅ ឃើញៗប៉ុននុ៎ង។

**ស៖** លោកអាចបញ្ជាក់បានទេថា អ្នកដែលលោកទៅសួរ អំមិញលោកអត់ លោកថាលោកអត់ ចាំឈ្មោះទេ អ៊ីចឹងលោកអាចចាំពីចំនួនមនុស្សដែលលោកសួរពីចំនួនប្រជាពលរដ្ឋនៅក្នុងភូមិគេ ឬក៏ សហករណ៍គេនីមួយៗហ្នឹងដែរទេ?

**ឆ៖** អានេះបញ្ហាដែលខ្ញុំសួរហ្នឹង ខ្ញុំអត់ចាំបានថាឈ្មោះមនុស្សអីប៉ុនណា អីចំនួនប៉ុនណា អីប៉ុន ណា ខ្ញុំចាំមិនបានទេ។ ប៉ុន្តែនិយាយឲ្យខ្លីទៅខ្ញុំសួរមកហ្នឹង ខ្ញុំតស៊ូដើម្បីខ្ញុំដឹងក្នុងភូមិខ្ញុំហ្នឹង ចំនួនប៉ុន្មាន ចាមហ្នឹងដើម្បីងាយស្រួលខ្ញុំដឹង។ ឯរឿងហេតុវាកើតយូរហើយ ខ្ញុំពិបាកនិយាយដូចថាយើងមិនដឹងទៅ សួរចំនួនប៉ុន្មាននាក់អីប៉ុន្មាននាក់ ខ្ញុំដូចថាភ្លេចភ្លាំងអស់ហើយណ៎ា។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេថា អ្នកដែលលោកសួរនោះជាអ្នកមានតួ នាទី ឬឋានៈអ្វីដែរទេ ក្នុងពេលហ្នឹង?

**ឆ៖** ខ្ញុំសួរនោះសុទ្ធតែគេមានតួនាទីគ្រប់គ្រងក្នុង ដូចថាប្រជាជនគេហ្នឹង ខ្ញុំសួរសុទ្ធតែគេមាន តួនាទី។

[១១:៤៣:០២]

**ស៖** លោកអាចបញ្ជាក់តួនាទីអ្វីទេ? ថ្នាក់ណាដែរ?

**ឆ៖** តួនាទីគេខ្ញុំបញ្ជាក់ថា ជាប្រធានសហករណ៍ ឬក៏ជាបុគ្គលិករបស់មេភូមិ ស្មៀនៗរបស់មេ ភូមិអី អាហ្នឹងតួនាទីគេប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីទំនាក់ទំនងដែលនាំឲ្យលោកអាចសួរសំណួរទាំង អស់នេះ ទៅប្រធានសហករណ៍ ឬក៏ជាអ្នកធ្វើការនៅក្នុង ឬក៏ជាមួយមេភូមិតាមដែលលោកមាន ប្រសាសន៍អម្បាញ់មិញបានទេ ថាមូលដ្ឋានអ្វីដែលអាចឲ្យលោកលើកសំណួរទាំងអស់នេះ ទៅសួរគេ បាន?

**ឆ៖** សូមអត់ទោស សូមបញ្ជាក់សំណួរម្តងទៀត ខ្ញុំស្តាប់ក្តាប់មិនបាន។

**សៈ** ខ្ញុំចង់សួរលោកឲ្យលោកបញ្ជាក់ពីតួនាទី ឬក៏ភារកិច្ចរបស់លោកដែលឲ្យលោកអាចដើរសួរប្រធានសហករណ៍ ឬក៏មេភូមិ ឬក៏លោកមានប្រសាសន៍អំមិញថាជាអ្នកធ្វើការជំនួយការមេភូមិជាដើមហ្នឹង តើមានៗកត្តាអ្វី ឬក៏ភារកិច្ចអ្វីដែលៗជាទំនាក់ទំនង ដែលអាចឲ្យលោកទៅសួរគេទាំងអស់នេះពីចំនួនប្រជាពលរដ្ឋហ្នឹងទេ?

**ឆៈ** ខ្ញុំសួរតាមរយៈ ដូចខ្ញុំបញ្ជាក់អំមិញ អ៊ីចឹងក្នុងនាមមនោសញ្ចេតនា មិត្តភក្តិនៅរាប់អានគ្នាអ៊ីចឹងធម្មតា លេខាភូមិហ្នឹងជាមិត្តភក្តិរបស់ខ្ញុំ ឬក៏ប្រធានសហករណ៍ ឬស្អី ព្រោះរស់នៅជាមួយគ្នាហ្នឹងការមនោសញ្ចេតនាចេះតែទំនាក់ទំនងគ្នាហើយ តាមរយៈហ្នឹងទេ។

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងចំនួនប្រជាពលរដ្ឋចាមដែលលោករៀបរាប់មកខាងក្រោយមកទៀតនៅក្នុងឯកសារដដែលហ្នឹង លោកថា ក្រោយឆ្នាំ៧៩នេះគឺនៅសល់តែ១៦០គ្រួសារ។ តើលោកនៅប្រកាន់ចំណុចនេះទេ? ជាសក្ខីកម្មរបស់លោកទេ?

[១១:៤៥:៥៨]

**ឆៈ** បញ្ហាក្រោយរំដោះ ចំនួនស្ថិតិប្រជាជននៅភូមិទី៥ ខ្ញុំឯកភាព ខ្ញុំយកបានថាអ្វីដែលខ្ញុំថា។ ក៏ប៉ុន្តែចំណុចដែលវា នេះវាលម្អៀងគ្នាបន្តិច ហ្នឹងខ្ញុំធ្លាប់ថា៧០ នៅសល់៧០ ហើយមនុស្សខាងក្រៅមករស់នៅនៅកន្លែងស្វាយឃ្លាំងហ្នឹងវា២៥គ្រួសារទៀត។ អ៊ីចឹង វាសល់ចេញពីខ្មែរក្រហមមក នៅសរុបទាំងអស់វា១៩៥គ្រួសារ ទាំងអ្នកចំណូលថ្មី ឯអ្នកចំណូលចាស់ អ្នកដូចថាម្ចាស់ភូមិហ្នឹងវានៅសល់១៧០គ្រួសារ។

**សៈ** បាទ សូមអរគុណ។ លោកមាននៅពេលហ្នឹងលោកជាអ្នកស្រង់ស្ថិតិទទួលខុសត្រូវក្នុងការរៀបចំស្រង់ស្ថិតិហ្នឹង ឬមួយក៏លោកដឹងចំនួននេះដោយរបៀបណា?

**ឆៈ** សូមបញ្ជាក់សំណួរថា នៅពេលណា ពេលក្រោយឆ្នាំ៧៩ ឬក៏ពេលណា?

**សៈ** បាទ គឺក្រោយឆ្នាំ៧៩។

**ឆៈ** ពេលនោះខ្ញុំមានតួនាទីជាគ្រូបង្រៀន ហើយខ្ញុំមានតួនាទីជា ដូចថាអ្នកមុខអ្នកការសម្រាប់ជំនួយការឲ្យហាកឹមគេទៀត។ អ៊ីចឹង ខ្ញុំត្រូវដូចថា អ្វីៗខ្ញុំត្រូវក្តាប់បានតាមរយៈហ្នឹង។

**សៈ** ខ្ញុំចង់សួរបញ្ជាក់អំពីប្រជាពលរដ្ឋចាមហ្នឹងគឺនៅក្នុង ដែលលោកនិយាយហ្នឹងនៅក្នុងឃុំស្វាយឃ្លាំងហ្នឹងទាំងមូល ឬមួយក៏បញ្ជាក់ទៅលើភូមិណាមួយទេ?

**ឆៈ** ឥឡូវខ្ញុំចង់បញ្ជាក់ មិនមែននៅឃុំទេ នៅភូមិទេ។ អ៊ីចឹងសរុបបីភូមិមក នៅមួយរយ ស្រុក

ភូមិទី៧ ដែលខ្ញុំជម្រាបសាមុនថាភូមិទី៧, ភូមិទី៦, ភូមិទី៥។ អ៊ីចឹងភូមិទី៧ មានរស់នៅជាមួយភូមិបងប្អូនខ្មែរចម្រុះគ្នា។ ឯចំណែកភូមិទី៥, ភូមិទី៦ សុទ្ធ – ចាមសុទ្ធ។ អ៊ីចឹងសរុបទាំងបីភូមិមក នៅសល់តែ ១៩៥គ្រួសារហ្នឹង។ ឯមួយឃុំហ្នឹងវាមានភូមិខ្ពបផ្សេងទៀតៗ អត់ពាក់ព័ន្ធទេអាហ្នឹងភូមិខ្ពប មួយឃុំ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ លោកប្រធាន ខ្ញុំឃើញម៉ោងលើសហើយ ប៉ុន្តែខ្ញុំនៅសល់មួយចំណុចទៀត តើសុំបន្តពេលថ្ងៃ ឬមួយយ៉ាងម៉េច?

[១១:៤៩:២៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥០:១៨]

**ប្រធានអង្គជំនុំ៖**

លោកត្រូវការពេលវេលាប៉ុន្មានទៀត លោក គង់ សំអុន? ព្រោះយើងប្រឹងប្រែងនេះដូចជាគ្រប់គ្រងពេលវេលាហ្នឹងដូចសមស្របហើយ។

**លោក គង់ សំអុន៖**

បើលោកប្រធាន អនុញ្ញាតឲ្យត ខ្ញុំព្យាយាមធ្វើឲ្យខ្លីបំផុត អាច២នាទីចុះ មួយនាទីពីរនាទីចុះ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តទៀតចុះ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ទាក់ទងនឹងសំណួរមួយដែលលោកមេធាវី កូប៉េ បានសួរមុននេះ អំពីការបះបោរ ក៏ដូចជាការសម្លាប់ទាហានខ្មែរក្រហម។ នៅក្នុងចម្លើយរបស់លោក លោកបានឆ្លើយថា លោកអត់បានដឹងទេ ពីការសម្លាប់ទាហានខ្មែរក្រហមនៅពេលបះបោរ នៅភូមិស្វាយឃ្លាំងរបស់លោកនោះ។ ប៉ុន្តែខ្ញុំឃើញនៅក្នុងឯកសារ E3/7678, ERN ជាភាសាខ្មែរលេខ 00218576, ភាសាបារាំង 00334655, ភាសាអង់គ្លេស 00218582។ ខ្ញុំសូមដកស្រង់៖ "ចំណែកអ្នកភូមិមានកាំភ្លើងពីរដើម មួយដើមម៉ាកអា.កា យកបានពីយោធាខ្មែរក្រហមម្នាក់ដែលមកលេងក្នុងភូមិ។ ឧស្មាន ជាអ្នកបាញ់កាំភ្លើងនេះ។ កាំភ្លើងមួយ

ដើមទៀត ម៉ាកការ៉ាប៊ីន យកបានពីឈ្មោះ ចែត ដែលត្រូវ តាឡិប កាប់ស្លាប់។ ឡិប វ៉ាន់ម៉ាត់ ជាអ្នកកាន់កាំភ្លើងនេះ អ្នកដែលៗមានគ្រាប់ចំនួនត្រឹមតែ១០ប៉ុណ្ណោះ។ ឧស្មាន និយាយប្រាប់ខ្ញុំថា គាត់បានបាញ់ស្លាប់ខ្មែរក្រហមចំនួនប្រាំបីនាក់។ រីឯ ឡិប វ៉ាន់ម៉ាត់ វិញ មិនបាននិយាយប្រាប់ខ្ញុំយ៉ាងណានោះទេ។” សូមបញ្ចប់ការដកស្រង់។ ខ្ញុំចង់សួរលោកថា តើអ្វីដែលខ្ញុំអានអម្បាញ់មិញនេះ ជាសក្ខីកម្មរបស់លោក ដែលលោកចាំបានថា ជាសក្ខីកម្មត្រឹមត្រូវដែរទេ?

[១១:៥៣:២១]

**លោក សុះ ពន់យ៉ាមីន៖**

**ឆ៖** អ្វីដែលខ្ញុំភ្លាប់បាន ខ្ញុំថាវាត្រឹមត្រូវ។ ក៏ប៉ុន្តែខ្ញុំគ្រាន់តែខ្ញុំភ្លាប់មិនបាន ដោយសារគេអ្នកកាន់កាំភ្លើង គេទៅផ្សេង ប៉ុន្តែគេមករាយការណ៍ប្រាប់ថា គេបាញ់ត្រូវប្រាំបីនាក់មែន ដូចៗមានប្រសាសន៍ ខ្ញុំ ខ្ញុំថាត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។ លោកមានឃើញសាកសព ឬក៏អ្វីដែលជាតឹកតាងនៃការបាញ់សម្លាប់នោះបានទេ នៅពេលក្រោយមកទៀតមក ក្រោយពីការបះបោរហ្នឹង?

**ឆ៖** ក្រោយពីការបះបោរ និយាយសំណួរ ខ្ញុំសូមបញ្ជាក់ថា ក្នុងភូមិហ្នឹង ឬក៏?

**ស៖** បាទ ក្នុងភូមិហ្នឹង គឺពេលបន្ទាប់មក ថ្ងៃបន្ទាប់មក។

**ឆ៖** អ៊ីចឹងមិនបានឃើញទេ ដោយមូលហេតុថា ល្ងាចហ្នឹង គេកៀរខ្ញុំចេញយកទៅដាក់មន្ទីរឃុំឃាំងហើយ។ អ៊ីចឹងអ្វីៗខ្ញុំអត់ដឹងទាំងអស់ នៅក្នុងភូមិក្រោយពីខ្ញុំ ដូចថា ខ្ញុំទៅរួចហើយ ខ្ញុំអត់ដឹងទេថា ហេតុផលយ៉ាងម៉េចៗ ខ្ញុំអត់ដឹង។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ លោកដើមបណ្ដឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយឥឡូវនេះ មានហេតុផលបី ទី១ គឺអស់ឌីវីឌី ហើយ ទី២ គឺនៅនីតិវិធីនៃការស្ដាប់សេចក្ដីថ្លែងទុក្ខសោកវេទនារបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងទី៣ គឺដើមបណ្ដឹងរដ្ឋប្បវេណីមានសំណួរមួយចំនួន មានបំណងសួរទៅជនជាប់ចោទ។ ដូច្នេះអង្គជំនុំជម្រះ មិនអាចបន្តនីតិវិធីតទៅទៀតបានទេ។ អង្គជំនុំជម្រះសម្រេចលើកបន្តសវនាការស្ដាប់ចុងក្រោយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅរសៀលនេះ ដើមម៉ោងដំបូងនៃរសៀលនេះ។

ឥឡូវនេះដល់ពេលសម្រាកអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកបន្តធ្វើនៅរសៀលនេះ ចាប់ផ្តើមពីម៉ោងមួយកន្លះ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី -- សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ត្រឡប់មកចូលកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ នៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះនៅវេលាម៉ោង ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៥៦ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:២៩:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការតទៅនេះគឺស្តាប់នូវសេចក្តីរៀបរាប់អំពីទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី។

លោក សុះ ពន់យ៉ាមីន ជាចុងក្រោយនេះ លោកអាចថ្លែងរៀបរាប់ដល់អង្គសវនាការអំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យលោកប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងជំងឺចិត្ត និងជាសមូហភាពពីជនជាប់ចោទ និងអំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកជាអាទិ៍ ខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និងជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ជាព្យសនកម្មផ្ទាល់ខ្លួនដែលបានកើតមានពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ សូមអញ្ជើញបាទ!

[១៣:៣១:៣៦]

**លោក សុះ ពន់យ៉ាមីន៖**

សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការទាំងអស់ជាទីគោរព!

ក្នុងនាមខ្ញុំជាដើមបណ្ដឹងរដ្ឋប្បវេណី ក្រោយពីបានខ្ញុំបានថ្លែងអ្វីៗទាំងអស់កន្លងមក ធ្វើឲ្យអារម្មណ៍ខ្ញុំមានការចាប់អារម្មណ៍ ហើយរំភើបដោយបានតុលាការជាតិ ហើយនិងតុលាការអន្តរជាតិយល់ឃើញពីជនជាតិចាមយើងខ្ញុំមានប្រវត្តិលំបាកវេទនាយ៉ាងធំធេងបំផុត។ អ៊ីចឹងសម្រាប់ខ្ញុំនៅពេលនេះ ខ្ញុំសូមចាប់អារម្មណ៍លើបញ្ហាការឈឺចាប់ ខ្មែរក្រហម របបខ្មែរក្រហមដែលរំលោភធ្វើឲ្យប៉ះពាល់ជនជាតិចាមយើងខ្ញុំ ហើយជារូបខ្ញុំផ្ទាល់ ហើយនិងក្រុមគ្រួសារយើងខ្ញុំទាំងអស់ និយាយរួមទាំងអស់ជាប្រជាជនខ្មែរទូទាំងប្រទេស។ អ៊ីចឹងខ្ញុំមិនសោកស្ដាយតែសម្រាប់តែក្រុមគ្រួសារខ្ញុំតែប៉ុណ្ណោះទេ គឺប្រជាជនខ្មែរទូទាំងប្រទេស និយាយរួមគឺគេមានជីវិតដូចគ្នា ចេះឈឺដូចគ្នា។ អ៊ីចឹងការកាប់សម្លាប់របស់គេធ្វើឲ្យរងទារុណកម្មដោយលំបាកវេទនា ដោយការកាប់សម្លាប់ ដោយត្បូងចប ដោយអូសទម្លាក់ទឹកទន្លេ។ អ៊ីចឹងការសម្លាប់ហ្នឹងដោយវេទនា អ៊ីចឹងធ្វើឲ្យខ្ញុំនឹកឃើញ គួរឲ្យរន្ធត់ក្នុងអារម្មណ៍ខ្ញុំ មិនអាចថ្លែងក្នុងអារម្មណ៍របស់ខ្ញុំបានទាំងអស់នោះទេ។

អ៊ីចឹងធ្វើ -- អ៊ីចឹងពេលនេះ ខ្ញុំសូមសម្ដែងអ្វីៗទាំងអស់ ដែលទុក្ខសោកទាំងឡាយ។ អ៊ីចឹងខ្ញុំនឹងផ្ដោតការឈឺចាប់របស់ខ្ញុំជានិច្ច។ អ៊ីចឹងខ្ញុំសូមថា អង្គការសហប្រជាជាតិខាងតុលាការអង្គការសហប្រជាជាតិ ហើយតុលាការជាតិធ្វើយ៉ាងណាកុំឲ្យរបបនេះវាត្រឡប់មកកាន់កម្ពុជាជាលើកទី២ ទៀត។

ហើយបញ្ហាមួយទៀត បញ្ហាសាសនាៗ អស់លោកមិនមែនតែត្រឹមសាសនាអ៊ីស្លាមទេ សាសនាព្រះពុទ្ធ គឺជាសាសនារបស់រដ្ឋ សាសនារបស់ជាតិខ្មែរយើង។ អ៊ីចឹងកើតតាំងពីយូរឆ្នាំមកហើយ។ អ៊ីចឹងហេតុអីបានគេបំផ្លាញ ផ្សឹកលោកសង្ឃ ហើយវត្តអារាមចោល នេះជាសាសនារបស់ជាតិ មិនមែនត្រឹមតែសាសនាអ៊ីស្លាមទេ។ អ៊ីចឹងអ្វីៗទាំងអស់នេះធ្វើឲ្យអារម្មណ៍ខ្ញុំដក់ជាប់ជានិច្ច ការឈឺចាប់។

ហើយទន្ទឹមនឹងនេះ ក៏ខ្ញុំមានអ្វីគួរឲ្យថ្លែងវែងឆ្ងាយតទៅទៀត ព្រោះអ្វីៗ ខ្ញុំដូចមិនធ្លាប់និយាយរៀបរាប់អស់ ហើយបញ្ហានេះសូមអត់ទោស។ សូមលោកប្រធាន ហើយអង្គសវនាការទាំងអស់ សូមអភ័យទោសឲ្យខ្ញុំផងចុះ។ អ៊ីចឹង ខ្ញុំសូមអរគុណ។

[១៣:៣៥:២៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ពន់យ៉ាមីន ហើយតាមរយៈអ៊ីម៉ែល តាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់ ថាលោក

មានបំណងចង់តាំងសំណួរតាមរយៈប្រធានទៅជនជាប់ចោទ។ តើលោកមានបំណងចង់សួរអីដែរទេ ឬក៏អត់ទេ?

**លោក សុះ ពន់យ៉ាមីន៖**

គោលបំណងខ្ញុំចង់សួរ ប៉ុន្តែខ្ញុំខ្លាចសួរទៅ វាប៉ះពាល់នឹងយ៉ាងម៉េចយ៉ាងម៉ា ខ្ញុំអត់ហ៊ានសួរ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ លោកប្រើសិទ្ធិទេ ព្រោះលោកមានសិទ្ធិតាំងសំណួរ ត្រង់ថាដោះស្រាយយ៉ាងណានោះជាសិទ្ធិរបស់អង្គជំនុំជម្រះ។ ប្រសិនបើលោកសួរ គឺមានឱកាស។ អង្គជំនុំជម្រះផ្តល់ឱកាសឱ្យលោកចុងក្រោយក្នុងការតាំងសំណួរ ប៉ុន្តែគ្រាន់តែប្រើប្រាស់ថាសំណួររបស់លោក គឺសួរទៅជនជាប់ចោទតាមរយៈប្រធានអង្គជំនុំជម្រះប៉ុណ្ណោះ។ លោកមិនអាចសួរផ្ទាល់បានទេ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ដោយសារថាសំណួរទាំងអស់នោះ គឺមេធាវីបានកត់ត្រាចេញពីដើមបណ្តឹងរដ្ឋប្បវេណីហើយ ទុកជូនគាត់នៅលើក្រដាសចំពោះមុខគាត់។ ដូច្នេះ សូមលោកប្រធានអនុញ្ញាតឱ្យគាត់អានក្រដាសនេះ ដែលជួយសម្រួលដល់គាត់នៅក្នុងការលើកសំណួរនេះ សូមលោកប្រធានអនុញ្ញាត។

[១៣:៣៧:២២]

**លោក សុះ ពន់យ៉ាមីន៖**

សំណួរទៅជនជាប់ចោទ តាមរយៈលោកប្រធានអង្គជំនុំជម្រះ។ ១) លោកទាំងពីរជាមេដឹកនាំនៅសម័យនោះ ធ្វើឱ្យប្រជាជនរងទុក្ខវេទនា រងការកាប់សម្លាប់អត់ត្រាប្រណីយ៉ាងដូច្នោះ។ តើគោលបំណងចង់បានអ្វី? សំណួរទី២ តើមូលហេតុអ្វីបានជាបំបាត់ជំនឿសាសនាទាំងអស់ ដូចជាខ្ញុំបាទសាសនាខ្ញុំបាទ ជាជនជាតិចាមត្រូវរងការធ្វើទុក្ខបុកម្នេញគ្រប់ពេលវេលា? សូមអស់សំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមជម្រាបលោក សុះ ពន់យ៉ាមីន ថានៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្តាប់ចម្លើយជនជាប់ចោទទាំងពីរនាក់ឆ្លើយបញ្ជាក់ពីការដែលពួកគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ អង្គជំនុំជម្រះបានកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់ នៅតែរក្សាជំហររបស់ខ្លួនបន្តការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែង

តែរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានព័ត៌មានជាក់លាក់ផ្សេងពីជនជាប់ចោទ ឬពីសហមេធាវីការពារក្ដីជនជាប់ចោទ។ នៅក្នុងសវនាការថ្ងៃនោះ អង្គជំនុំជម្រះបានកំណត់ឲ្យជនជាប់ចោទ និងមេធាវីការពារក្ដីជនជាប់ចោទត្រូវមានភារកិច្ចទទួលខុសត្រូវក្នុងការជូនដំណឹងមកដល់អង្គជំនុំជម្រះឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។ ប្រសិនបើជនជាប់ចោទសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួរដែលអង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធ នៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ។

[១៣:៣៩:២៩]

ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្ដូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប មកជាការយល់ព្រមនៅឡើយទេ។ ដូច្នេះនៅក្នុងនីតិវិធីរបស់តុលាការ មិនមានបទប្បញ្ញត្តិដែលឯណាដែលផ្ដល់សិទ្ធិឲ្យអង្គជំនុំជម្រះហ្នឹងបង្ខំឲ្យជនជាប់ចោទឆ្លើយតបទៅនឹងសំណួររបស់លោកបានទេ។

ហើយអង្គជំនុំជម្រះអរគុណលោក ពន់យ៉ាមីន។ សវនាការស្ដាប់សក្ខីកម្មរបស់លោក និង ថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលលោកបានអះអាងថាលោកបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានដល់ទីបញ្ចប់ហើយ។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតនៅរឿងក្ដីនេះ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់បានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ និងបានសេចក្ដីសុខ សេចក្ដីចម្រើន។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ក្នុងការជូនលោក ពន់យ៉ាមីន វិលត្រឡប់ទៅលំនៅឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយនិងបង្គាប់ឲ្យអញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-832 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ)*

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:៤២:២៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី! តើលោកឈ្មោះអី?

**លោក សេង ឃុយ៖**

**ឆ៖** ខ្ញុំឈ្មោះ សេង ឃុយ។

**ស៖** អរគុណលោក សេង ឃុយ។ តើលោកកើតនៅថ្ងៃខែឆ្នាំណា? លោកចាំដែរទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កុំទាន់អាលទាន់ឆ្លើយតប! ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ បានសំឡេងរបស់លោកចូលទៅប្រព័ន្ធចែកចាយសំឡេងសម្រាប់អង្គជំនុំជម្រះ សម្រាប់ភាគី និងអ្នកបកប្រែភាសា។

**ឆ៖** បាទ ខ្ញុំកើតនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៥៤។

**ស៖** បាទ អរគុណ។ ហើយទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា? ហើយទីលំនៅសព្វថ្ងៃរបស់លោក នៅទីកន្លែងណា លោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេ?

**ឆ៖** ខ្ញុំមានស្រុកកំណើតនៅភូមិអង្គរបានទី២ ឃុំអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម។

**ស៖** សព្វថ្ងៃ?

**ឆ៖** ហើយសព្វថ្ងៃ ខ្ញុំរស់នៅភូមិអង្គរបានទី២ ឃុំអង្គរបាន ស្រុកងកងមាស ខេត្តកំពង់ចាមដដែល។

**ស៖** បាទ អរគុណ។ ហើយចុះឪពុកបង្កើតរបស់លោកឈ្មោះអី? ម្តាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំបាទឈ្មោះ ប៉ោ សេង គាត់នៅរស់។ ម្តាយឈ្មោះ យាន ឡាំងអ៊ី ស្លាប់យូរហើយ។

[១៣:៤៥:១៥]

**ស៖** បាទ អរគុណ។ ហើយភរិយារបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ភរិយាខ្ញុំក្រោយនេះគឺឈ្មោះ លៀង សុខហៀង។ ភរិយាចាស់ខ្ញុំមុនហ្នឹងគាត់ស្លាប់១៣ឆ្នាំជាងហើយ។ ហើយកូនដែលជាកូនរបស់ខ្ញុំភរិយាមុនហ្នឹងមានចំនួនប្រាំពីរនាក់។ ចំណែកភរិយាក្រោយអត់មានកូនទេ។

**ស៖** បាទ អរគុណ។ ហើយលោក សេង ឃុយ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

កាលពីព្រឹកមិញ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺថាលោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន និងបុគ្គលដែលត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះទេ។ តើរបាយការណ៍នេះ ត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ របាយការណ៍នេះ ពិតជាត្រឹមត្រូវ។ ខ្ញុំគ្មានជាប់ពាក់ព័ន្ធជាមួយជនចោទទេ។

**ស៖** ហើយថា លោកបានស្បថរួចហើយនៅមុខអ្នកតាដំបងដែក នៅមុនពេលមកផ្ដល់សក្ខីកម្មបានន័យថា កាលពីព្រឹកនេះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានស្បថរួចរាល់ ត្រឹមត្រូវអស់ហើយ។

[១៣:៤៥:៥៦]

**ស៖** តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ លោក សេង ឃុយ ក្នុងឋានៈលោកជាសាក្សី នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច ក្នុងនាមលោកជាសាក្សីត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះ សួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប ឬក៏ការធ្វើអត្ថាធិប្បាយតបរបស់លោក នាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពី សិទ្ធិរបស់លោកសាក្សីរួចហើយអម្បាញ់មិញនេះ។

ហើយក្នុងនាមជាសាក្សី ត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយ ដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លោក សេង ឃុយ តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ប្រសិនបើមាន តើធ្វើប៉ុន្មានដងធ្វើនៅទីណាកន្លែងណា នៅពេលណា?

[១៣:៤៧:៣០]

**ឆ៖** បាទ ខ្ញុំធ្លាប់ធ្វើកិច្ចសម្ភាសន៍ជាមួយសហចៅក្រមចំនួនពីរលើក គឺនៅក្នុងខែសីហា ឆ្នាំ២០០៨ ម្ដងនៅសាលាឃុំអង្គរបាន។ ហើយលើកទី២ នៅក្នុងខែកក្កដា ឆ្នាំ២០១១ ម្ដងទៀត នៅសាលា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឃុំអង្គរបានដែរ។

**ស៖** បាទ អរគុណ។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុ ដែលលោកបានផ្តល់សក្ខីកម្មចំនួនពីរលើកកាលពីលើកមុនជាមួយអ្នកស៊ើបអង្កេតដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** ខ្ញុំបានចងចាំខ្លះៗដែរ។

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ តើលោកអាចបញ្ជាក់បានដែរទេថាកំណត់ហេតុដែលស្តាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនោះ ពិតជាត្រឹមត្រូវ ឬក៏វាស៊ីចង្វាក់គ្នា ស្របទៅនឹងចម្លើយដែលលោកបានធ្វើកិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលពីរលើកនៅសាលាឃុំអង្គរបាននោះដែរឬទេ?

**ឆ៖** បាទ កិច្ចសម្ភាសន៍នេះ គឺឯកភាព និងត្រឹមត្រូវតាមចម្លើយបំភ្លឺរបស់ខ្ញុំបាទ។

[១៣:៤៩:១២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមបញ្ជាក់ថាសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ ហើយពេលនេះ គឺវគ្គទី១នេះ គឺអាចសួរបានរហូតដល់ម៉ោងបីខ្វះដប់នាទី។ សូមអញ្ជើញបាទ!

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកស្រីចៅក្រម ជម្រាបសួរអស់លោក លោកស្រីទាំងអស់ ទាំងក្នុង ទាំងនៅក្រៅបន្ទប់សវនាការ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** ហើយសូមអរគុណលោកសាក្សី ដែលបានចូលមកឆ្លើយចំពោះមុខតុលាការជាមួយយើងខ្ញុំនៅថ្ងៃនេះ។ ខ្ញុំនឹងសាកសួរ<សំណួរមួយចំនួនទៅ>លោក។ <ខ្ញុំឈ្មោះ អេនឌ្រូ ប៊ិយលី> ខ្ញុំគឺជា

តំណាងសហព្រះរាជអាជ្ញារងអន្តរជាតិ នៃការិយាល័យសហព្រះរាជអាជ្ញា។ បន្ទាប់ពីខ្ញុំទៅ ខ្ញុំនឹងផ្តល់នាទីជូនសហការីជាតិរបស់ខ្ញុំ <គឺលោកមេធាវី សេង លាង ដើម្បី>សាកសួរលោក<បន្ថែម>។ គឺថាលោកបានឆ្លើយទៅនឹងសំណួរលោកប្រធាន<មុននេះ>ថាលោកកើតនៅ<ភូមិ>អង្គរបាន<២> ស្រុកកងមាស <ឃុំអង្គរបាន>។ តើទីកន្លែងនេះ ជាទីកន្លែងដែលលោកបានរស់នៅ ឬយ៉ាងណានៅពេលដែលខ្មែរក្រហមចូលមកកាន់កាប់នៅឃុំអង្គរបាន?

[១៣:៥១:១៦]

**លោក សេង ឃុយ៖**

**ឆ៖** បាទ ភូមិកំណើត និងទីលំនៅដែលខ្ញុំរស់នៅបច្ចុប្បន្ននេះ គឺជាស្រុកកំណើតខ្ញុំ ហើយមួយជីវិតនេះគឺខ្ញុំរស់នៅភូមិអង្គរបានទី២ ឃុំអង្គរបានហ្នឹងតែមួយកន្លែងរហូតបច្ចុប្បន្ន។

**ស៖** សូមអរគុណ។ សូមលោកជម្រាបជូនតុលាការផង ថាតើខ្មែរក្រហមបានចូលគ្រប់គ្រងនៅឃុំអង្គរបាននៅពេលណាដែរ?

**ឆ៖** តាមខ្ញុំដឹងគឺចាប់ពីឆ្នាំ១៩៧៦ រហូតដល់ឆ្នាំ១៩៧៩ហ្នឹង។

**ស៖** ខ្ញុំស្តាប់តាមរយៈការបកប្រែ ឮថាលោកឆ្លើយថាខ្មែរក្រហមបានគ្រប់គ្រងឃុំអង្គរបាននៅដើមឆ្នាំ១៩៧៦។ លោកឆ្លើយថាអ៊ីចឹងមែនទេ ឬក៏ថាខ្មែរក្រហមត្រួតត្រាឃុំអង្គរបានតាំងពីមុនឆ្នាំ១៩៧៦ដែរ?

**ឆ៖** ពីឆ្នាំ១៩៧៥មកគឺ គេជម្លៀសប្រជាជនថ្មីពីទីក្រុងភ្នំពេញ អាហ្នឹងរបបខ្មែរក្រហមគេគ្រប់គ្រងហើយ ពី៧៥មក ៧៦ មករហូត៧៩នេះ។

**ស៖** បាទ សូមអរគុណ។ ហើយមុនពេលខ្មែរក្រហមត្រួតត្រាតំបន់របស់លោក តើនៅពេលនោះ មុនខ្មែរក្រហមនោះ លោកមានតួនាទីធ្វើអ្វីដែរ?

**ឆ៖** បាទមុនរបបខ្មែរក្រហមមកគ្រប់គ្រង ខ្ញុំជាប្រជាពលរដ្ឋមួយ ជាអ្នកធ្វើស្រែចម្ការ ភ្ជួររាស់នៅនឹងភូមិរបស់ខ្ញុំបាទហ្នឹង។

**ស៖** ហើយនៅពេលដែលខ្មែរក្រហមត្រួតត្រាភូមិរបស់លោក តើលោកនៅតែបន្តធ្វើជាកសិករដដែល ឬក៏ការងាររបស់លោកពេលហ្នឹងផ្លាស់ប្តូរហើយ?

[១៣:៥៤:០៣]

**ឆ៖** បាទ នៅពេលខ្មែរក្រហមចូលមកគ្រប់គ្រងនៅភូមិរបស់ខ្ញុំ គឺខ្ញុំហ្នឹងជាទាសករមួយរូប គេ

ឲ្យខាងក្លួររាស់ ស្រែចម្ការហ្នឹងដដែល រហូតពេលទាល់តែដាច់របប ប៉ុល ពត ហ្នឹង។

**ស៖** សូមលោកជម្រាបជូនតុលាការផង លោកមានជនជាតិដើមជាអ្វីដែរ លោកជាខ្មែរ ជាចាម ឬក៏ជាៗជនជាតិភាគតិចណាមួយ?

**ឆ៖** បាទ ខ្ញុំបាទ ជាជនជាតិខ្មែរ គឺសញ្ជាតិខ្មែរ។

**ស៖** នៅក្នុងឆ្នាំ១៩៧៥ នៅពេលខ្មែរក្រហមបានក្ដោបក្ដាប់អំណាចលើកដំបូង<>នៅភូមិរបស់លោក តើមានជនជាតិចាមរស់នៅក្នុង<ភូមិ>អង្គរបាន<២>ដែរទេ?

**ឆ៖** នៅក្នុងឃុំអង្គរបានគឺមានប្រជាជនចាមរស់នៅពីរភូមិ គឺភូមិអង្គរបានទី១ និងអង្គរបានទី៣ នៅពីរភូមិ។ ចំណែកភូមិអង្គរបានទី២ ដែលជាភូមិដែលខ្ញុំរស់នៅ មិនមានប្រជាជនចាមទេ។

**ស៖** ហើយសូមលោកជម្រាបជូនតុលាការផងថា តើភូមិអង្គរបានទី១ វាមានចម្ងាយប៉ុន្មានពីភូមិអង្គរបានទី២ ដែលជាភូមិរបស់លោកនេះ?

**ឆ៖** ចំណែកភូមិទី១នេះគឺជាប់គ្នា អង្គរបានទី១រួច អង្គរបានទី២ បន្ទាប់មកអង្គរបានទី៣។ អ៊ីចឹងភូមិហ្នឹងគឺជាប់ៗគ្នាតែម្ដង មិនឆ្ងាយគ្នាគឺមានព្រំប្រទល់ជាប់គ្នា ភូមិ។

**ស៖** ចុះភូមិអង្គរបានទី៣ តើភូមិអង្គរបានទី៣នេះ ជាប់ព្រំប្រទល់គ្នាជាមួយនឹងភូមិអង្គរបានទី២ដែរទេ?

[១៣:៥៦:៤៦]

**ឆ៖** បាទ ជាប់គ្នា។

**ស៖** តើមានផ្លូវរួមប្រើប្រាស់ដោយភូមិអង្គរបានទី១, ទី២, ទី៣ រួមគ្នាដែរទេ?

**ឆ៖** ភូមិអង្គរបានទាំងបីភូមិនេះ គឺមានផ្លូវថ្នល់រួមគ្នាមួយខ្សែ ប្រើរួមគ្នា ហើយក៏មានផ្លូវបែកៗគ្នា ទៅតាមភូមិនីមួយៗផ្សេងគ្នាទៀត។

**ស៖** មុនពេលខ្មែរក្រហមគ្រប់គ្រងឃុំអង្គរបាន តើលោកមានប្រាស្រ័យទាក់ទងជាមួយនឹងជនជាតិចាមដែលរស់នៅភូមិអង្គរបានទី១ និងភូមិអង្គរបានទី៣ ដែរទេ? ទោះបីជាការទាក់ទងនោះទាក់ទងដោយផ្ទាល់ខ្លួន ឬក៏ជាទំនាក់ទំនងបែបពាណិជ្ជកម្មរបស់លោក បែបអាជីវកម្មរបស់លោកក្ដី តើលោកមានទំនាក់ទំនងណាមួយជាមួយជនជាតិចាមនៅទីនោះទេ?

**ឆ៖** នៅពេលមុនរបបខ្មែរក្រហមចូលមកគ្រប់គ្រង ចំពោះខ្លួនខ្ញុំបាទ និងប្រជាជនចាមដែលមានទីលំនៅជាប់នឹងភូមិខ្ញុំបាទនេះ ខ្ញុំ ការទំនាក់ទំនងជិតស្និទ្ធនោះគឺមិនមានទេ គ្រាន់តែបានធ្វើដំណើរ

ឆ្លងកាត់អីអ៊ីចឹង ពីព្រោះកាលដើមឡើងហ្នឹង គឺបងប្អូនចាមគាត់មានមុខរបរនេសាទផ្សេងទៅ ហើយខ្ញុំភ្លួរាស់ស្រែចម្ការ អ៊ីចឹងវាមិនបានអីទៅទំនាក់ទំនងទៅជិតស្និទ្ធគ្នាទេ។

**ស៖** សូមអរគុណ។ ខ្ញុំសុំសួរលោកអំពីសំណួរទូទៅ ទាក់ទងទៅនឹងជនជាតិចាមរស់នៅភូមិ<ផ្សេងៗ>ជាប់នឹងភូមិរបស់លោកនៅក្នុងអំឡុងពេល<មុន>ខ្មែរក្រហមគ្រប់គ្រងឃុំអង្គរបាន។ លោកដឹងទេថា ជនជាតិចាមនៅពេលនោះ គាត់មានគោរពប្រតិបត្តិសាសនា<អ្វី>ដែរ<>?

[១៣:៥៩:៣២]

**ឆ៖** តាមខ្ញុំដឹង នៅពេលខ្មែរក្រហមចូលមកគ្រប់គ្រង គឺបងប្អូនជនជាតិចាមហ្នឹង មិនមានទៅគោរពប្រតិបត្តិសាសនាទេ គឺខ្លាច មិនហ៊ានទេ។ ពីព្រោះគឺគេចុះទៅគ្រប់គ្រងហើយ ចាមហ្នឹង គេលែងឲ្យទៅជាជនជាតិចាមទៀតហើយ គេឲ្យក្លាយទៅជា មកនៅជាមួយខ្មែរ ទាំងសម្លៀកបំពាក់ ទាំងការហូបចុកអី ជាមកជាខ្មែរឲ្យ លែងឲ្យកាន់សាសនាចាមហើយ តាមខ្ញុំដឹង។

**ស៖** សូមអរគុណ។ ហើយខ្ញុំនឹងសាកសួរអំពីការផ្លាស់ប្តូរ<ទាំងនោះនៅពេលបន្តិចទៀតនោះ> ប៉ុន្តែដំបូងនេះ ខ្ញុំសូមសួរអំពីជនជាតិចាម មុនខ្មែរក្រហមចូលមកដល់។ លោកដឹងទេថា ចាមប្រតិបត្តិសាសនាអ្វីដែរ មុនពេលខ្មែរក្រហមចូលមកដល់?

**ឆ៖** បាទ មុនខ្មែរក្រហមចូលមកគ្រប់គ្រង គឺបងប្អូនជនជាតិចាម គាត់កាន់សាសនាមហាម៉ាត់ អ៊ីស្លាមសាសនាហ្នឹង មហាម៉ាត់ហ្នឹង។

**ស៖** តើនៅក្នុងឃុំអង្គរបានមានវិហារចាមដែលចាមអាចបួងសួងបានទេ?

**ឆ៖** គឺមានមួយកន្លែង វិហារធំ សម្រាប់ថ្វាយបង្គំ។

**ស៖** ហើយថាតើជនជាតិចាម នៅពេលនោះ ស្លៀកសម្លៀកបំពាក់ខុសពីសម្លៀកបំពាក់ខ្មែរ ឬក៏យ៉ាងណាដែរ?

**ឆ៖** បាទ សម្លៀកបំពាក់ គឺស្លៀកតាមប្រពៃណី គឺខុសពីខ្មែរយើង។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ តើជនជាតិចាមប្រុសនិងស្រីនោះ ស្លៀកសម្លៀកបំពាក់ហ្នឹងខុសគ្នារបៀបណាដែរ?

[១៤:០២:១៨]

**ឆ៖** បាទ ខ្ញុំដឹងហ្នឹង គឺបងប្អូនចាមជាបុរសហ្នឹង គឺគាត់ស្លៀក មានស្លៀកសារុង ហើយពាក់អាវវែងធម្មតាៗហ្នឹង។ ហើយចំណែកបងប្អូនចាមជាស្ត្រី គឺគាត់ស្លៀកសំពត់ហ្នឹងជាបំពង់ គឺស្លៀក

វែងៗរហូតដី ទាំងអាវទាំងសំពត់ហ្នឹង ជាប់គ្នាវែង។

**ស៖** តើសក់របស់ស្ត្រីចាម ខុសពីសក់របស់ស្ត្រីខ្មែរ ឬក៏យ៉ាងណា <>ពាក់ព័ន្ធទៅនឹងពេលកាត់សក់ហ្នឹង គេកាត់ឲ្យវាខុសគ្នា ឬក៏យ៉ាងណា?

**ឆ៖** ការកាត់សក់ហ្នឹង វែងដូចគ្នា ប៉ុន្តែគ្រាន់តែបងប្អូនចាម គេទទូរជាប់ហ្នឹង យកៗក្រមាមកក្រណាត់មកទទូរជាប់ ហើយខ្មែរយើងអត់មានទទូរ ទៅណាមកណា។

**ស៖** តើជនជាតិចាមនិយាយភាសាខុសពីភាសាខ្មែរដែរឬទេ?

**ឆ៖** បាទ ជនជាតិចាមនិយាយភាសាចាម ខុសពីខ្មែរយើង។

**ស៖** ហើយតើជនជាតិចាមហូបចំណីអាហារខុសពីជនជាតិខ្មែរ ឬក៏ថាតើចាមមិនហូបចំណីអាហារណាមួយដែលខ្មែរហូបដែរឬទេ?

**ឆ៖** ជនជាតិចាម និងខ្មែរ គឺជនជាតិចាមហូបខុសពីខ្មែរ គឺដាច់ខាតសាច់ជ្រូកហ្នឹង គឺគេមិនហូបទេ។ បងប្អូនចាមមិនហូបដាច់ខាតសាច់ជ្រូក ហើយត្រង់ត្រីសាច់ដទៃ សាច់គោ សាច់អីទៀត ហូបប៉ុន្តែសាច់ជ្រូកមួយមុខ គឺមិនហូបដាច់ខាតតែម្តង សាសនាគេតម។

[១៤:០៤:៥០]

**ស៖** ឥឡូវនេះ ខ្ញុំសូមនិយាយអំពីរយៈពេលដែលខ្មែរក្រហមបានចូលមកគ្រប់គ្រងឃុំអង្គរបាន។ នៅពេលនោះ ក្រោយពេលខ្មែរក្រហមបានមកដល់ តើលោកមានឱកាសពិនិត្យមើលឃើញចាម នៅភូមិអង្គរបាន១ និងភូមិអង្គរបាន៣ នេះត្រូវបានគេប្រព្រឹត្តដោយរបៀបណាដែរទេ?

**ឆ៖** នៅពេលនោះ ជនជាតិចាមទាំងពីរភូមិនោះ គេជម្លៀសចេញទៅអស់ហើយ មិនមាននៅនៅហ្នឹងនៅតិចតួច នៅភូមិខ្មែរជម្លៀសចេញទៅក្រៅ មិនដឹងចេញទៅណាទេ គេមិនឲ្យនៅប្រមូលផ្តុំអីច្រើន ដូចកាលដើមឡើយទេ។

**ស៖** នៅក្នុងអំឡុងរបបខ្មែរក្រហម តើគេមានជម្លៀសជនជាតិចាមឲ្យទៅរស់នៅភូមិរបស់លោកទេ មានន័យថាយកពីភូមិផ្សេងៗទៅឲ្យនៅភូមិអង្គរបានទី២?

**ឆ៖** បាទ នៅក្នុងអំឡុងពីឆ្នាំ ចុងឆ្នាំ៧៦មកហ្នឹង ខ្ញុំឃើញមានបងប្អូនចាមហ្នឹង គេយកមកឲ្យនៅជាមួយបងប្អូនខ្មែរ នៅភូមិរបស់ខ្ញុំនេះ។ មានប្រហែលពី ប្រហែលជា១៥គ្រួសារដែរ។ ប៉ុន្តែមិនមែនបងប្អូនចាមនេះ ទី៣, ទី១ទេ តាមខ្ញុំស្គាល់ គឺចាមផ្សេង។

**ស៖** តើលោកអាចប៉ាន់ប្រមាណបានទេ លោកនិយាយថា ក្រុមគ្រួសារចាម១៥គ្រួសារហ្នឹង បើ

សិនណាគិតពីចំនួននាក់ហ្នឹង តើមានប្រហែលជាប៉ុន្មាននាក់?

**ឆ៖** សូមទោស អំមិញខ្ញុំនិយាយខុស គឺចាមហ្នឹងប្រហែលជាសរុបទៅ១៥នាក់ ១៦នាក់ប៉ុណ្ណឹង មិនមែនគ្រួសារទេបាទ។ បើគិតជាគ្រួសារ ប្រហែលជាប្រាំទៅប្រាំមួយគ្រួសារប៉ុណ្ណឹង។ អំមិញនេះ ជម្រាបថា១៥គ្រួសារមិនមែនទេ គឺប្រហែលជា១៥ ទៅ១៦នាក់ ហើយបើគិតជាគ្រួសារប្រាំប្រាំមួយ គ្រួសារប៉ុណ្ណឹងទេ។

[១៤:០៧:៤១]

**ស៖** ខ្ញុំស្ដាប់ឮថា ចាមទាំងនោះ គឺមិនមែនបញ្ជូនចេញពីភូមិជាប់ភូមិលោកទេ។ បើមិនបញ្ជូន ចេញពីភូមិនៅជាប់ជាមួយនឹងភូមិលោកទេ តើពួកគាត់ទាំងអស់នោះ គេបញ្ជូនមកពីទីណា?

**ឆ៖** បញ្ហានេះ ខ្ញុំអត់ដឹងដែរ។ ស្រាប់តែឃើញគេយកបងប្អូនចាមហ្នឹងយកមកឲ្យរស់នៅធ្វើ ស្រែចម្ការជាមួយប្រជាជននៅភូមិខ្ញុំ។

**ស៖** ជនជាតិចាម ដែលគេបញ្ជូនមកឲ្យរស់នៅក្នុងភូមិរបស់លោក តើពួកគាត់ទាំងអស់នោះ មានទាំងប្រុស ទាំងស្រី ឬក៏មានតែបុរស ឬក៏មានតែស្ត្រី?

**ឆ៖** ដើមដំបូងហ្នឹង គឺមកជាគ្រួសារ មានប្ដីប្រពន្ធ មានកូនអីអ៊ីចឹងបាទ ជាគ្រួសារមក។

**ស៖** ខ្ញុំស្ដាប់ឮថា ដំបូងឡើយ គេមកជាគ្រួសារ ហេតុអ្វីបានជាលោកប្រើពាក្យថា "ដំបូង ឡើយ" <តើពួកគេទាំងនោះ>ក្រោយមក មិនរស់នៅជាគ្រួសារ<ទៀតទេ មែនទេ>?

**ឆ៖** ក្រោយមក គេជម្លៀសប្ដីហ្នឹងទៅឲ្យធ្វើការឆ្ងាយ មិនដឹងជាទៅឯណា នៅតែប្រពន្ធ និង កូនតូចៗ បានជាខ្ញុំនិយាយថាពីដំបូងមក មកទាំងប្ដីប្រពន្ធ។ ដល់នៅបានប្រហែលជាប្រាំប្រាំមួយខែទៅ គេយកប្ដី ដូចថាជម្លៀសទៅឲ្យនៅឆ្ងាយ ឲ្យនៅតែប្រពន្ធ និងកូនក្នុងស្រុកភូមិនេះ។ មិនដឹងជាគេឲ្យទៅ ធ្វើការឯណាទេ មិនដឹងដែរ។

**ស៖** លោកទើបតែបាននិយាយអំពីកូនៗ តើក្មេងៗដែលគេបញ្ជូនមកឲ្យរស់នៅក្នុងភូមិរបស់ លោកជាមួយគ្រួសាររបស់គេហ្នឹង ក្មេងៗហ្នឹងមានអាយុប្រហែលជាប៉ុន្មានដែរ?

[១៤:១០:០០]

**ឆ៖** បាទ មានអាយុ៥ឆ្នាំ, ៦ឆ្នាំ ខ្លះទៅក៏១០ឆ្នាំអ៊ីចឹងទៅ តូចៗ។

**ស៖** ក្រោយគេបញ្ជូនបុរសៗចេញទៅឆ្ងាយពីភូមិ តើមានជនជាតិចាមប៉ុន្មាននាក់រស់នៅភូមិ របស់លោក? <> តើស្ត្រីជាម្ដាយនិងកូនៗ<ដែលជាជនជាតិចាម>នៅ<សល់>ក្នុងភូមិមានប៉ុន្មាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នាក់?

**ឆ៖** មានចំនួនប្រហែលជាពី១០ ទៅ១៥នាក់អីប៉ុណ្ណោះទេ។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ដើម្បីប្រតិចារឹក។ <ខ្ញុំជឿថា ខ្ញុំបានឮ>លោកឆ្លើយថា មុនដំបូងនោះគឺថាមានជនជាតិចាមប្រហែលជា១៥ ទៅ១៦នាក់សរុបទាំងអស់ បញ្ជូនមករស់នៅក្នុងភូមិរបស់លោក។ ហើយក្រោយមកបុរសៗត្រូវគេបញ្ជូនទៅធ្វើការទៅឆ្ងាយ នៅសល់តែស្ត្រីៗជាម្ដាយ និងកូនៗ<ជនជាតិចាមប្រហែល១០ ទៅ១៥នាក់ នៅក្នុងភូមិរបស់លោក>។ ហើយបើយ៉ាងដូច្នេះគឺមានន័យថា មានបុរសជាជនជាតិចាមប្រហែលតែប្រាំនាក់អ៊ីចឹងទេ ឬប្រាំមួយនាក់ទេដែលត្រូវគេបញ្ជូនទៅឆ្ងាយពីភូមិ អ៊ីចឹងមែនទេ?

**ឆ៖** មិនដល់ប៉ុនន៉ុង ពីព្រោះខ្លះហ្នឹងមកហ្នឹងមិនមានប្ដីទេ មានតែកូននិងម្ដាយ។ អ៊ីចឹងបញ្ជូនទៅឆ្ងាយហ្នឹងប្រហែលជាបីទៅបួននាក់អីប៉ុណ្ណឹងទេ។ ហើយអស់ពីហ្នឹងនៅ ពីព្រោះការគាត់មកពីដំបូងហ្នឹង ខ្លះក៏មានប្ដីប្រពន្ធជាមួយ ខ្លះក៏មកតែប្រពន្ធនិងកូនអីតែប៉ុណ្ណឹង។

**ស៖** ហើយនៅពេលជនជាតិចាមមកដល់ភូមិរបស់លោក ធ្វើម៉េចបានជាលោកដឹងថាពួកគាត់ជាជនជាតិចាម?

**ឆ៖** ព្រោះខ្ញុំស្គាល់ចាម និងខ្មែរ គឺខុសគ្នាបាទ។ ខុសទាំងសម្លៀកបំពាក់ ខុសទាំងការនែ៎ គឺស្គាល់ច្បាស់អ៊ីចឹងតែម្ដង ព្រោះខ្ញុំ ជនជាតិចាមហ្នឹង ខ្ញុំហ្នឹងមានស្រុកកំណើតនៅជាប់គ្នាហ្នឹង។ ព្រោះកាលមកដំបូងគឺមាននិយាយចាម និយាយអ៊ីចឹងដែរ។ លួចលាក់នៅពេលស្ងាត់កំបាំងពីគេហ្នឹង បានយើងដឹងថាចាម។

[១៥:១២:៥៩]

**ស៖** ដូច្នេះលោកអាចកំណត់អត្តសញ្ញាណរបស់ពួកគាត់ថាជាចាម ដោយសារលោកបានឮថាគាត់លួចនិយាយភាសាចាមដាក់គ្នា ស្ងាត់ៗ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** លោកក៏បាននិយាយថា ចាមមានសម្លៀកបំពាក់ដោយឡែក។ អ៊ីចឹងបានខ្ញុំចង់សួរថា នៅពេលដែលពួកគាត់មកដល់ភូមិរបស់លោកក្នុងឆ្នាំ១៩៧៦ តើពួកគាត់ស្លៀកសម្លៀកបំពាក់ចាមហ្នឹងដដែលឬពេលនោះ?

**ឆ៖** នៅពេលមករស់នៅភូមិខ្ញុំ គឺលែងប៉ានស្លៀកពាក់ចាមហើយ ស្លៀកពាក់សម្របខ្លួនទៅ

តាមខ្មែរទាំងអស់។ ហើយការនិយាយស្អីអី ក៏លែងហ៊ាននិយាយអីចំហអី គឺនិយាយជាខ្មែរទាំងអស់។

**ស៖** សូមអរគុណ។ តើលោកអាចជម្រាបជូនតុលាការបានទេ នៅពេលដែលគេបញ្ជូនជនជាតិចាមមករស់នៅក្នុងភូមិរបស់លោក នៅក្នុងឃុំ -- នៅក្នុងភូមិអង្គរបានទី២នេះ ប្រជាជនសរុបទាំងអស់មានប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** តាមខ្ញុំដឹងហ្នឹងប្រហែលជា១៥ ទៅ១៦នាក់ប៉ុណ្ណឹងទេ។

[១៤:១៤:៤៨]

**ស៖** សូមទោស ប្រហែលជាសំណួរខ្ញុំវាមិនច្បាស់ហើយមើលទៅ។ ខ្ញុំនិយាយអំពីចំនួនប្រជាជនសរុបនៅក្នុងភូមិអង្គរបានទី២ ទាំងមូលតែម្តង គឺទាំងខ្មែរ ទាំងចាម។ សរុបទាំងអស់មានអ្នកភូមិទាំងអស់ប៉ុន្មាននាក់ គឺនៅពេលដែលគេបញ្ជូនជនជាតិចាមមកឆ្នាំ១៩៧៦ សរុបទាំងខ្មែរ ទាំងចាម មានប៉ុន្មាននាក់ដែរ?

**ឆ៖** ការងារនេះ គឺខ្ញុំប៉ាន់ស្មានទេ ពីព្រោះកាលនោះ ខ្ញុំមិនដឹងចំនួនច្បាស់ ពីព្រោះខ្ញុំមិនមែនជាអ្នកធ្វើការងារ ប៉ុន្តែគ្រាន់តែដឹងថា នៅពេលហូបបាយហ្នឹង ជំនាន់ប៉ុល ពតហ្នឹង គេធ្វើរោងបាយមួយ ហើយមកហូបរួមគ្នាអ៊ីចឹង និងប៉ាន់ស្មានចំនួនផ្ទះ ហើយតាមខ្ញុំធ្វើការងាររាល់ថ្ងៃហ្នឹង និងប៉ាន់ស្មានប្រជាពលរដ្ឋកាលពីជំនាន់នុ៎ង ប្រហែលជាមួយភូមិហ្នឹង ទាំងចាស់ ទាំងក្មេង ទាំងចាមហ្នឹង ប្រហែលជាប្រាំមួយប្រាំពីររយនាក់អីប៉ុណ្ណឹង។

**ស៖** ហើយអំឡុងពេលដែលចាមរស់នៅក្នុងភូមិរបស់លោកនោះ តើលោកមានឱកាសណាមួយកត់សម្គាល់ពួកគាត់ ឬក៏ថាតើមានលោកមានឱកាសណាមួយនិយាយជាមួយពួកគាត់ទេ?

**ឆ៖** មិនដែលបាននិយាយលេងអីទេ ព្រោះជំនាន់ខ្មែរក្រហមគ្រប់គ្រងនោះ គឺព្រលឹមឡើង គឺគេឲ្យទៅភ្ជួររាស់ អត់មានពេលណាជួបគ្នា។ មកជួប ជួបតែហូបបាយនៅរោងបាយជុំគ្នាហ្នឹង យើងក៏អត់បានទៅនិយាយដែរ គឺពេលហូបបាយហ្នឹង ម៉ោងប្រាំពីរ ប្រាំបីយប់ ឡើងពីធ្វើស្រែចម្ការមក។ អ៊ីចឹងមិនបានប្រាស្រ័យទាក់ទងអីគ្នាទេ។

[១៤:១៦:៥៩]

**ស៖** តាមដែលលោកអាចបញ្ជាក់អះអាងបាននោះ តើជនជាតិចាមត្រូវបានគេអនុញ្ញាតឲ្យធ្វើសំយ៉ាំងដែរទេ ប្អូងស្ងួងហ្នឹងដែរទេ នៅពេលដែលគេបញ្ជូនពួកគាត់មកនៅក្នុងភូមិរបស់លោក <គឺភូមិអង្គរបាន២>?

**ឆ៖** មិនមានទេ គឺមិនមានកន្លែងថ្វាយបង្គំ មិនបានទៅថ្វាយបង្គំអី គឺបងប្អូនចាមខ្លាច គឺខ្មែរយើង ធ្វើការម៉េច របៀបរបបម៉េច គឺសម្របខ្លួនតាមខ្មែរយើងទាំងអស់តែម្ដង។

**សៈ** លោកក៏បានឆ្លើយរួចមកហើយ ថាពួកគាត់ក៏មិនត្រូវបានអនុញ្ញាតឲ្យស្លៀកពាក់សម្លៀកបំពាក់បែបបុរាណនោះដែរ ទំនៀមទម្លាប់នោះដែរ ប៉ុន្តែនៅពេលនោះ តើស្ត្រីជាជនជាតិចាមត្រូវបានគេអនុញ្ញាតឲ្យទុកសក់វែងដែរទេ?

**ឆ៖** រឿងសក់ហ្នឹង គឺដូចជាមិនមានការហាមឃាត់ទេ តាមខ្ញុំដឹង។ គឺនៅ ពីព្រោះបងប្អូនចាមហ្នឹងគឺមានខ្លះកាត់ដូចខ្មែរអ៊ីចឹងដែរ មានវែងមានខ្លីត្រឹមកៗអីដូចខ្មែរអ៊ីចឹងដែរ មិនមានវែងអីទេ។

**សៈ** លោកបានឆ្លើយរួចមកហើយថា ជនជាតិចាម គឺថាលួចនិយាយភាសាចាមជាមួយគ្នាស្ងាត់ៗទេ។ ចុះបើសិនណាជាពួកគាត់<មិន>អាចនិយាយ<>ភាសាចាមគ្នាគាត់ហ្នឹងជាចំហបានទេ<តើ>គាត់ត្រូវតែនិយាយ<គ្នាជា>ភាសាខ្មែរ<មែនទេ>?

**ឆ៖** ដាច់ខាតត្រូវតែនិយាយភាសាខ្មែរ។ ការដែលលួចលាក់ហ្នឹង គឺតាមខ្ញុំដឹងហ្នឹង គឺទើបបញ្ជូនគេបញ្ជូនមករស់នៅថ្មីៗហ្នឹង មានលួចលាក់ ប៉ុនដល់នៅបានតែបន្តិចទៅ គឺលែងបានៗទាល់តែសោះតែម្ដង គឺនិយាយតែភាសាខ្មែរ។

**សៈ** តើពួកគាត់និយាយភាសាខ្មែរបានច្បាស់ទេ?

[១៤:១៩:៤០]

**ឆ៖** មិនច្បាស់ទេ ប៉ៃឡាំ។ បាទ មិនច្បាស់ទេ។

**សៈ** លោកបានឆ្លើយថា ពួកគាត់<>ត្រូវ<បានហាមឃាត់មិន>ឲ្យនិយាយភាសាចាម<>ទាំងស្រុងតែម្ដង នៅពេលពួកគាត់មកដល់ភូមិអង្គរបានទី២។ លោកដឹងទេថា ការហាមឃាត់មិនឲ្យនិយាយភាសាចាមទាល់តែសោះហ្នឹង <តើគេដាក់ចេញបញ្ជាមកដោយរបៀបម៉េច>?

**ឆ៖** ការងារនេះ គឺមិនមានអ្នកណាហាមឃាត់ គឺបងប្អូនចាមមិនបាននិយាយខ្លួនឯងតែម្ដងដោយបើនិយាយភាសាចាមទៅ គឺខ្លាចគេយកទៅសម្លាប់ចោលអ៊ីចឹង។ អ៊ីចឹងគឺគាត់សម្របខ្លួន មិនបាននិយាយដោយខ្លួនគាត់តែម្ដង។ ឬមួយក៏គេថាហាមឃាត់ហ្នឹង ក៏ខ្ញុំមិនដឹងដែរ ព្រោះអត់បានដឹងច្បាស់ថា មានគេហៅមកហាមឃាត់ ថាមិនឲ្យនិយាយខ្មែរ ខ្ញុំអត់ដឹងទេរឿងហ្នឹង។

**សៈ** ការហាមឃាត់មិនឲ្យ<គោរពសាសនាអ៊ីស្លាម និងមិនឲ្យ>ស្លៀកសម្លៀកបំពាក់តាមទំនៀមទម្លាប់ចាម លោកដឹងថាតើខ្មែរក្រហមនេះ គេអនុវត្តការហាមឃាត់ហ្នឹងដោយរបៀបណា?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយថាតើហេតុអ្វីបានជាចាមត្រូវតែអនុវត្តតាមការហាមឃាត់នេះ?

**ឆ៖** ការងារទាំងនេះខ្ញុំមិនច្បាស់ដែរ គ្រាន់តែដឹងថាពេលបងប្អូនចាមគេឲ្យមកនៅភូមិខ្ញុំហ្នឹង គឺមិនមានសម្លៀកបំពាក់ចាមទេ គឺសម្លៀកបំពាក់ជារបៀបរបបខ្មែរយើង។

**ស៖** បាទ សូមអរគុណ។ តើលោកធ្លាប់ឃើញការចាប់ខ្លួនជនជាតិចាមណាម្នាក់នៅក្នុងភូមិរបស់លោកទេ?

[១៤:២២:១៥]

**ឆ៖** បាទ បញ្ហានេះខ្ញុំបានឃើញផ្ទាល់នឹងភ្នែក គឺនៅក្នុងឆ្នាំមួយ ប្រហែលជាអំឡុងឆ្នាំ១៩៧៧ ប្រហែលជាម៉ោងប្រាំបីយប់ហ្នឹង បងប្អូនអ្នកស្រុកហ្នឹង ទាំងខ្មែរ ទាំងចាមហ្នឹងឡើងពីធ្វើស្រែចម្ការ ដកស្ទូង ហូបបាយនៅរោងបាយៗរួមគ្នាហ្នឹង។ ហើយនៅយប់នោះ គឺមានសន្តិសុខគេមកចាប់ចាមហ្នឹង។ ចាប់ហ្នឹងគឺមិនមែនម្នាក់ទេ គឺចាប់ចាមដែលរស់នៅក្នុងភូមិទី២ ប៉ុន្មានហ្នឹង គឺគេចាប់ទាំងអស់ ហើយចាប់ហ្នឹងគឺនៅក្នុងរោងបាយកំពុងតែហូបបាយជុំគ្នាជាមួយបងប្អូនខ្មែរហ្នឹង។ ហើយពេលនោះបានជាខ្ញុំបានឃើញ ខ្ញុំកំពុងតែអង្គុយហូបបាយនៅជាមួយក្បែរគ្នាហ្នឹងដែរ។

**ស៖** ខ្ញុំនឹងសួរសំណួរលោកជាលម្អិតអំពីការចាប់ខ្លួននេះ ប៉ុន្តែដំបូងខ្ញុំសួរថា តើនេះគឺជាការចាប់ខ្លួនតែមួយលើកទេឬ ដែលលោកបានឃើញគេចាប់ជនជាតិចាម<នៅក្នុងភូមិរបស់លោក>? ឬក៏លោកបានឃើញការចាប់ខ្លួនហ្នឹងនៅពេលណាផ្សេងទៀតដែរ?

**ឆ៖** ខ្ញុំបានជួបប្រទះមួយលើកហ្នឹងទេ។

**ស៖** លោកទើបតែនិយាយថា ការចាប់ខ្លួនហ្នឹងគឺប្រព្រឹត្តទៅនៅក្នុងឆ្នាំ៧៧ តើលោកអាចបញ្ជាក់ បានទេ ថា<គេចាប់ខ្លួន>ចាមទាំងអស់នៅក្នុងភូមិរបស់លោកនុ៎ង<មែនទេ? តើខ្ញុំយល់ត្រឹមត្រូវទេចំពោះចម្លើយពីមុនរបស់លោកដែលថា>គេចាប់ខ្លួនជនជាតិចាម<ដែលជាស្ត្រី និងកុមារ>ប្រហែលជាសរុបទាំងអស់ហ្នឹង១៥នាក់<នៅពេលនោះ?>

**ឆ៖** តាមខ្ញុំគិតមើលអត់ដឹងទេ។ បងប្អូនចាមហ្នឹងមិនដឹងពីផែនការគេចាប់ខ្លួន ស្រាប់តែអង្គុយៗហូបបាយហ្នឹង សន្តិសុខគេមកចាប់តែម្តង។

[១៤:២៥:១៤]

**ស៖** ចាមដែលត្រូវបានចាប់ខ្លួន<ក្នុងអំឡុងពេល ឬក្រោយពេលហូបបាយល្ងាចហើយ>នោះ មានទាំងស្ត្រី មានទាំងកុមារទេ ដូចដែលលោកបានលើកឡើងពីខាងដើមហ្នឹងទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ មានទាំងស្ត្រី មានទាំងពីកុមារ ក្មេងប្រុស ក្មេងស្រី។

**ស៖** អ៊ីចឹង តើត្រឹមត្រូវទេដែលថាស្ត្រី និងកុមារហ្នឹង សរុបទាំងអស់ហ្នឹង គឺប្រហែលជា១០ទៅ១៥នាក់ ដែលបានចាប់ខ្លួននៅពេលនុ៎ង អ៊ីចឹងមែនទេ?

**ឆ៖** បាទ ប្រហែលអ៊ីចឹង។

**ស៖** អ៊ីចឹងមានន័យថា ជនជាតិចាមទាំងអស់នៅក្នុងភូមិរបស់លោកហ្នឹងត្រូវបានគេចាប់ខ្លួននៅពេលនុ៎ង អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** តើលោកអាចជម្រាបបានទេថា កងសន្តិសុខដែលជាអ្នកធ្វើការចាប់ខ្លួនជនជាតិចាមហ្នឹងជាអ្នកណា?

**ឆ៖** កងសន្តិសុខចាប់បងប្អូនចាមហ្នឹង គឺជាកងសន្តិសុខឃុំ ហៅសន្តិសុខឃុំ។

**ស៖** លោកចាំឈ្មោះកងសន្តិសុខឃុំណាមួយ ដែលមកធ្វើការចាប់ខ្លួនជនជាតិចាមហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំចាំឈ្មោះ គឺគាត់ឈ្មោះ រុន។

[១៤:២៧:២៦]

**ស៖** តើលោកអាចជម្រាបឲ្យបានច្បាស់ទេថា រុន ហ្នឹង<ជានរណា>?

**ឆ៖** រុន ហ្នឹង គឺគាត់មានតួនាទីជាកងសន្តិសុខថ្នាក់ឃុំតែម្តង។ អាហ្នឹងគេហៅ ជំនាន់ហ្នឹងគេហៅសន្តិសុខឃុំ ថ្នាក់ឃុំ។

**ស៖** កងសន្តិសុខហ្នឹង តើលោកដឹង<ទេថាគាត់កាន់>តួនាទី<អ្វី>?

**ឆ៖** តាមខ្ញុំដឹងហ្នឹង ឮគេនិយាយ គឺគាត់ជាប្រធានតែម្តង ប្រធានសន្តិសុខឃុំ ព្រោះគាត់មានកូនចៅគាត់បីបួននាក់មកជាមួយហ្នឹង។

**ស៖** តើលោកធ្លាប់ឮគេនិយាយអំពីឈ្មោះ រុន ដែលជាប្រធានសន្តិសុខ<ឃុំ>ហ្នឹងទេ? <>

**ឆ៖** បាទ ធ្លាប់បានឮថា ឈ្មោះ រុន ហ្នឹងគឺជាប្រធានសន្តិសុខមួយឃុំអង្គរបានហ្នឹង គឺគេដើរធ្វើសកម្មភាពចាប់ចងអី ទូទៅទាំងឃុំអង្គរបានហ្នឹងតែម្តង។

**ស៖** នៅសម័យនោះ លោកខ្លាចឈ្មោះ រុន ហ្នឹងទេ?

**ឆ៖** សម័យនោះ មិនថាតែខ្លួនខ្ញុំទេ សូម្បីតែប្រជាជនដទៃទៀត គ្រាន់តែឃើញឈ្មោះ រុន មកហ្នឹង ភ័យញ័រ។ បើកំពុងតែហូបបាយហ្នឹង ញ័រលែងហូបបាយកើតហើយ មិនបាច់ ចាំបាច់ទៅចាប់ចង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទេបាទ គឺ រុន ហ្នឹងមានអំណាចខ្លះណាស់។

**ស៖** ក្រៅពីគាត់មានអំណាចខ្លាំងហ្នឹង លោកអាចរៀបរាប់បន្ថែមបានទេ ហេតុអីបានជាលោកខ្លាចគាត់?

[១៤:២៩:៥៧]

**ឆ៖** ពីព្រោះតាមដឹង រុន ហ្នឹងឲ្យតែមក គឺចាប់អ្នកស្រុកហ្នឹងតែម្ដង ខ្លាចរឿងគេចាប់យកទៅសម្លាប់ចោលហ្នឹង ព្រោះអត់មានសួរនាំអី បានអ៊ីចឹងនាំគ្នាខ្លាចរអើល។

**ស៖** លោកដឹងថា រុន នេះមកពីទីកន្លែងណាទេ?

**ឆ៖** រុន ហ្នឹងគាត់ជាប្រជាជនមួយនៅភូមិអង្គរបានទី៧ ក្នុងឃុំអង្គរបានហ្នឹងដែរ។ ហើយគាត់កាលដើមឡើយពីមុនរបប គាត់មកធ្វើជាសន្តិសុខគឺគាត់ធ្វើជាយោធា យោធាខ្មែរក្រហម។

**ស៖** លោកធ្លាប់ឮឈ្មោះហៅក្រៅរបស់គាត់ទេ ឬក៏គាត់មានឈ្មោះតែ រុន នេះទេ មានឈ្មោះហៅក្រៅផ្សេងពីហ្នឹងទេ?

**ឆ៖** គឺមានឈ្មោះតែម្នាក់ហ្នឹងទេ ឈ្មោះ រុន តែមួយហ្នឹង។

**ស៖** លោកសាក្សី ខ្ញុំចង់អានសម្រង់មួយនៃកិច្ចសម្ភាសន៍របស់លោក។ នៅពេលនោះគឺលោកបានរៀបរាប់ ហើយខ្ញុំព្យាយាមចង់បានព័ត៌មានបន្ថែមទៀតពីការរៀបរាប់របស់លោក គឺឯកសារលេខ E3/5301 ERN ជាភាសាអង់គ្លេសគឺ 00210483, ជាភាសាខ្មែរគឺ 00635169, ភាសាបារាំង 00622401។ ខ្ញុំសូមដកស្រង់៖ "ខ្ញុំឮគេហៅ រុន ហ្នឹងថាជាឃាតករ ពីព្រោះថាគាត់ចាប់មនុស្សនៅក្នុងឃុំ និងក្នុងភូមិ។ រុន ជាអ្នកទទួលខុសត្រូវខាងសន្តិសុខគ្រប់ភូមិទាំងអស់ក្នុងឃុំនេះ ហេតុនេះហើយបានជាប្រជាជនខ្លាចគាត់ ហើយនិងញ័រខ្លួននៅពេលដែលពួកគេបានឃើញគាត់។ នៅពេលនោះ ពួកយើងមិនហ៊ាននិយាយអំពីគាត់ទេ។ ក្រោយពេលដួលរលំរបបខ្មែរក្រហម ប្រជាជននិយាយថា ឈ្មោះ រុន នេះធ្លាប់ចាប់មនុស្សនៅក្នុងតំបន់ភាគខាងលិច និងភាគខាងកើតទន្លេ។ តំបន់នេះ គឺនៅ<ផ្នែកម្ខាងនៃ>ស្ពានក្នុងឃុំអង្គរបាន។" តើ<ត្រឹមត្រូវទេដែល>លោក<និយាយ>ថា លោកបានឮគេហៅ រុន ហ្នឹងថាជាឃាតក? ហើយលោកយល់យ៉ាងម៉េចដែរ ពាក្យថា "ឃាតក" ហ្នឹងចំពោះលោកហ្នឹង?

[១៤:៣៣:១២]

**ឆ៖** ខ្ញុំបានឮឈ្មោះ រុន នេះ គេហៅថាឃាតកគឺពិតអ៊ីចឹងមែន ពីព្រោះ រុន នេះជាអ្នកសម្លាប់មនុស្សអីអ៊ីចឹង។

**ស៖** តើលោកដឹងថាមានរឿងអ្វីកើតឡើងចំពោះ រុន ទេក្រោយពីខ្មែរក្រហមបានបាត់បង់អំណាចនៅក្នុងឃុំរបស់លោកនោះ?

**ឆ៖** ក្រោយពីការផ្តួលរំលំរបប ប៉ុល ពត នៅឆ្នាំ១៩៧៩ ឈ្មោះ រុន នេះត្រូវបានប្រជាពលរដ្ឋហ្នឹងគេយកទៅកាប់ចិញ្ច្រាំសម្លាប់ចោលនៅមាត់ព្រែកអង្គរបាន ដោយគេខឹងឈ្មោះ រុន ហ្នឹង កាលជំនាន់ រុន ហ្នឹងធ្វើសន្តិសុខនៅជំនាន់ខ្មែរក្រហមហ្នឹង ចាប់បងប្អូនគេយកទៅសម្លាប់ចោល។ អីចឹងដាច់៧៩ ហ្នឹងគឺគេសម្លាប់ រុន ហ្នឹងចោលវិញ អ្នកស្រុកហ្នឹង។

**ស៖** ឥឡូវនេះ ខ្ញុំត្រឡប់មកនិយាយអំពីការចាប់ខ្លួនជនជាតិចាមនៅយប់<នោះ ក្នុង>ឆ្នាំ<១៩៧៨> នៅក្នុងភូមិរបស់លោក។ តើគេមានដែលប្រាប់លោកទេថា ហេតុអីបានជា រុន ហើយនិងកងសន្តិសុខផ្សេងទៀតហ្នឹងមកចាប់ខ្លួនជនជាតិចាមនៅយប់នោះ?

**ឆ៖** គេអត់បានប្រាប់ខ្ញុំទេ ហើយខ្លួនខ្ញុំហ្នឹងក៏មិនដឹង ស្រាប់តែឃើញពេលនុ៎ង គឺគេចុះមកចាប់អីចឹងតែម្តង។

[១៤:៣៥:២៥]

**ស៖** នៅពេលគេចាប់ជនជាតិចាម តើគេមានចងដៃ ចងជើង ឬក៏បិទមុខអីទេ?

**ឆ៖** មានចង ចងដៃទៅក្រោយ ហើយចងហ្នឹង ហើយបើ -- ហ្នឹងបានមានចង។ ហើយបើក្មេងតូចហ្នឹង ប្រហែលជាអត់ចងទេមើលទៅ ក្មេងតូចអាយុបីបួនឆ្នាំអីហ្នឹង។

**ស៖** ក្រោយពីគេចងជនជាតិចាមហើយ <លើកលែងតែក្មេងៗ គឺគេមិនចងទេ តើ>គេធ្វើយ៉ាងម៉េចទៀតចំពោះជនជាតិចាមដែលគេ<ចងទាំងអស់នោះ>?

**ឆ៖** ពេលនោះគឺ ប្រធាន អនុប្រធានភូមិនៅភូមិអង្គរបានទី២ហ្នឹង រុន ហ្នឹងបញ្ជាឲ្យហៅប្រជាពលរដ្ឋហ្នឹង យករទេះគោដឹកបងប្អូនចាមហ្នឹង ទៅវត្តអូរត្រកួន នៅប្រហែលជាម៉ោងប្រាំបួនយប់។

**ស៖** តើគេមានបញ្ជាឲ្យលោកចូលរួមនៅក្នុងសកម្មភាពចាប់ចងហ្នឹងទេ?

**ឆ៖** ការចាប់ចងហ្នឹង គឺអត់ទេ បាទ។

**ស៖** សូមអភ័យទោស ខ្ញុំមិនសំដៅថាលោកចូលរួមចាប់<ខ្លួនមនុស្ស>ដោយផ្ទាល់ទេ ខ្ញុំចង់និយាយអំពីរទេះគោនោះ <>តើមេភូមិហ្នឹងមាន<បញ្ជា>ឲ្យលោកចូលរួមក្នុងការដឹកជនជាតិចាមដែលគេចាប់បានហ្នឹង តាមរទេះគោអីទេ?

**ឆ៖** បាទ ក្នុងនោះ អនុប្រធានភូមិជាមេគ បានចាត់ខ្ញុំ ខ្លួនខ្ញុំម្នាក់ហ្នឹងឲ្យយករទេះគោហ្នឹង ដឹក

ប្រជាជនចាមជាមួយបងប្អូនប្រជាពលរដ្ឋយើងផ្សេងទៀត ចំនួនប្រហែល តាមមើលប្រហែលពីប្រាំទៅប្រាំមួយរទេះគោ បាទ។ ក្នុងនុំង គឺខ្លួនខ្ញុំម្នាក់ហ្នឹង គេចាត់ឲ្យដឹកទៅដែរ ជាអ្នកដឹក ដឹកចាមហ្នឹង។

[១៤:៣៨:២៧]

**ស៖** តើលោកនៅពេលដែលគេឲ្យដឹកហ្នឹង លោកអាចបដិសេធប្រកែកថាមិនចង់ដឹកជនជាតិចាមដែលគេចាប់ហ្នឹង តាមរទេះគោទេ លោកអាចធ្វើអ៊ីចឹងបានទេ ពេលនោះ?

**ឆ៖** មិនហ៊ានប្រកែកទេ បើប្រកែកហ្នឹង ច្បាស់ជាគេយកទៅសម្លាប់ជាមួយចាមហ្នឹងមិនខានទេ ពេលនោះខ្លាច តែគេបញ្ជាមកត្រូវតែខ្លាច ធ្វើតាមគេនុំង។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ។ តើលោកអាចជម្រាបបានទេថា គេប្រើប្រាស់រទេះគោចំនួនប៉ុន្មានគ្រឿង ដើម្បីដឹកជនជាតិចាមទាំងអស់នោះ?

**ឆ៖** តាមខ្ញុំដឹងហ្នឹង ប្រហែលជាប្រាំ ទៅប្រាំមួយរទេះគោ បាទ ហើយក៏ត្រឹមប្រាំរទេះប៉ុណ្ណឹងពីព្រោះយប់ងងឹត ហើយក៏ភ័យខ្លាចមិនបានឈរទៅរាប់មើលរទេះ មើលអីហ្នឹង គ្រាន់តែដឹងបរតាមគ្នាទៅ ប្រហែលជារទេះប្រាំអីប៉ុណ្ណឹងទេ។

**ស៖** តើលោកដឹកចាមតាមរទេះគោហ្នឹងយកទៅកន្លែងណា?

**ឆ៖** បាទ ដឹកចេញពីរោងបាយ កន្លែងភូមិដែលខ្ញុំរស់នៅហ្នឹង ទៅកាន់វត្តអូរត្រកួន។

**ស៖** ម៉េចបានជាលោកដឹងថា លោកត្រូវដឹកទៅវត្តអូរត្រកួន អ្នកណាប្រាប់លោកថាឲ្យដឹកអ្នកទាំងអស់ហ្នឹងទៅវត្តអូរត្រកួនហ្នឹង?

**ឆ៖** គេប្រាប់ គឺនុ៎ះ អនុប្រធានកង អនុប្រធានភូមិនៅហ្នឹងភូមិខ្ញុំហ្នឹង គេប្រាប់ថា ឲ្យបរដឹកទៅវត្តអូរត្រកួន បាទបានយើងដឹង។

[១៤:៤១:១០]

**ស៖** លោកអាចជម្រាបឈ្មោះ<អនុ>ប្រធានភូមិ ឬក៏<អនុ>ប្រធាន<កង>ដែលប្រាប់លោកឲ្យដឹកទៅវត្តអូរត្រកួនហ្នឹងបានទេ?

**ឆ៖** បាទ គាត់អ្នកដែលប្រាប់ទៅហ្នឹង គឺឈ្មោះ អន។ ហើយតាមខ្ញុំដឹង គឺអន ហ្នឹងមានការបញ្ជាពី រុន ហ្នឹង។ អន ហ្នឹងខ្លាច ដែលរឿងហ្នឹងបញ្ជាទៅ ក៏គាត់ធ្វើតាម ពីព្រោះគាត់ជាអនុប្រធានភូមិទេ។ ហើយក៏ជម្រាបជូនទៀតដែលថា អន នេះគាត់ជាមនុស្សស្លូតបូតទេ ហើយប្រជាពលរដ្ឋ គឺគេស្រឡាញ់គាត់ គាត់មិនមែនជាមនុស្សឃោរឃៅទេ។ ប៉ុន្តែដល់ខ្លាច រុន ហ្នឹងគាត់ក៏ធ្វើតាមបញ្ជាគេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើលោកអាចជម្រាបបានទេថា ពីភូមិអង្គរបាន២ ទៅវត្តអូរត្រកួនហ្នឹងមានចម្ងាយប៉ុន្មានគីឡូម៉ែត្រដែរ?

**ឆ៖** កាលដឹកទៅហ្នឹង គឺមិនមែនដឹកទៅវត្តតែម្តងទេ គឺដឹកទៅត្រឹមខ្លោងទ្វារវត្ត ហើយពីភូមិអង្គរបានទី២ ទៅខ្លោងទ្វារវត្តហ្នឹងមានចំនួនប្រហែលជាជាង៣គីឡូ ពីភូមិអង្គរបានទី២ ទៅខ្លោងទ្វារវត្តអូរត្រកួនហ្នឹង ប្រហែលជាជាង៣គីឡូប៉ុណ្ណឹង ប៉ាន់ស្មាន។

[១៤:៤៣:០៣]

**ស៖** ដូច្នេះ នៅពេលដែលធ្វើដំណើរ៣គីឡូហ្នឹង តើលោកប្រើពេលប៉ុន្មានដែរ ហើយនៅពេលដែលលោកទៅដល់ខ្លោងទ្វារវត្តអូរត្រកួនហ្នឹង គឺម៉ោង<ប្រហែល>ប៉ុន្មានដែរ?

**ឆ៖** ទៅដល់ខ្លោងទ្វារវត្តអូរត្រកួន ប្រហែលជាម៉ោងប្រាំបួនជាងបាទ ពីព្រោះផ្លូវរាបហ្នឹងបរលឿន អត់មានបរយឺតអី បាទ។

**ស៖** តើកងសន្តិសុខដែលចាប់ជនជាតិចាមហ្នឹង <ឬកងសន្តិសុខផ្សេងទៀតបាន>មានធ្វើដំណើរក្នុងរទេះគោជាមួយលោកទៅវត្តហ្នឹងទេ?

**ឆ៖** ចំពោះរទេះគោខ្ញុំអត់មានទេ ត្រង់រទេះគោអ្នកដទៃ មិនដឹងដែរ។ ប៉ុន្តែបើតាមខ្ញុំប៉ាន់ស្មានប្រហែលជាមិនទៅទេមើលទៅ តាមខ្ញុំប៉ាន់ស្មានពេលនោះ។

**ស៖** តើជនជាតិចាមដែលលោកដឹកក្នុងរទេះគោហ្នឹង <តើលោក>មាន<ឮពួកគេ>និយាយអ្វីទេ ឬក៏មានស្រែក មានអីទេ ពេលដែលលោកដឹកពីភូមិទៅវត្តអូរត្រកួននោះ?

**ឆ៖** ពេលនោះ រទេះគោខ្ញុំដឹកទៅហ្នឹង បីនាក់ ម្តាយមួយ និងកូនពីរនាក់ ហើយគ្មាននិយាយអីទេ ភ័យនៅស្ងៀមហ្នឹង។ រទេះគោហ្នឹងបរប៉ោល រ៉ូងរ៉ាង១ប្រញាប់ន្ទាលនឹងដល់ មិនមាននិយាយអីទេ។

**ស៖** នៅខ្លោងទ្វារវត្តមានអ្នកណាម្នាក់ចាំយកមនុស្សទាំងអស់ហ្នឹងទេ ពេលដែលលោកដឹកទៅដល់នោះ?

**ឆ៖** បាទ ខ្ញុំជម្រាបជូនថា ពីខ្លោងទ្វារវត្តទៅដល់វត្តអូរត្រកួនហ្នឹងមានចម្ងាយប៉ាន់ស្មានប្រហែលជា៧០០ម៉ែត្រ។ ហើយនៅពេលដែលពួកយើងខ្ញុំដឹកទៅដល់ហ្នឹង មានមនុស្សគេម្នាក់ គេនៅចាំទទួលហ្នឹង។ គឺខាងសន្តិសុខស្រុកវត្តអូរត្រកួនហ្នឹង។ យើងថាសន្តិសុខស្រុកចុះ ព្រោះគេចេញមកទទួលនៅនឹងខ្លោងទ្វារនេះ។

[១៤:៤៦:០៥]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើអ្នកចាំទទួលនោះមាននិយាយអ្វីទេ ពេលដែលលោកដឹកមនុស្សតាមរទេះគោទៅដល់ខ្លោងទ្វារនុ៎ង?

**ឆ៖** អ្នកចាំទទួលហ្នឹងគេគ្រាន់តែប្រាប់ថា អ្នកបររទេះដាក់ចាមចុះទៅ ហើយត្រឡប់ទៅផ្ទះវិញចុះ។ បាទ គេគ្រាន់តែប្រាប់ប៉ុណ្ណឹង។

**ស៖** ហើយនៅ<>ពេលលោកដឹកទៅដល់ខ្លោងទ្វារហ្នឹងជនជាតិចាមទាំងអស់ហ្នឹងនាំគ្នាចុះពីរទេះគោ<របស់លោក ហើយនិងរទេះគោផ្សេងៗទៀត>ដែរទេ?

**ឆ៖** ចុះពីលើរទេះគោ។

**ស៖** លោកមានមើលឃើញក្រោយពីលោកដាក់ជនជាតិចាមទាំងអស់ហ្នឹងចុះ<នៅខ្លោងទ្វារវត្ត>ហើយឃើញពួកចាមហ្នឹងដើរតម្រង់ទៅណាទេ?

**ឆ៖** នៅពេលភ្លាមហ្នឹងក៏យើង បងប្អូនចាមចុះពីលើរទេះទៅ គេនាំបណ្ដើរទៅវត្តអូរត្រកួននោះពីខ្លោងទ្វារទៅចូលទៅវត្តអូរត្រកួន។ ហើយពួកខ្ញុំក៏បររទេះវិលមកផ្ទះមកវិញភ្លាមមក។

**ស៖** ក្រោយពីលោកដាក់ចាមនៅខ្លោងទ្វារហើយឃើញជនជាតិចាមត្រូវគេបណ្ដើរចូលទៅក្នុងវត្ត តើលោកធ្លាប់ឃើញជនជាតិចាមដែលលោកដឹកទៅហ្នឹង ធ្លាប់ឃើញម្ដងទៀតទេ?

[១៤:៤៨:១២]

**ឆ៖** តាំងពីដឹកបងប្អូនចាមទៅវត្តអូរត្រកួនហ្នឹងក្រោយមកអត់ឃើញទាល់តែសោះ បងប្អូនចាមដែលនៅភូមិជាមួយប៉ុន្មាននេះ សូម្បីតែម្នាក់ក៏មិនដែលឃើញផង។

**ស៖** តើលោកមានដែលដឹងរឿងរ៉ាវដែលបានកើតឡើងចំពោះអ្នកដែលគេចាប់ខ្លួនហើយបញ្ជូនទៅវត្តអូរត្រកួននេះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់មួយ និងការជំទាស់មួយ។ ការកត់សម្គាល់ហ្នឹងគឺថា ខ្ញុំៗដូចជា<មិនច្បាស់ថាខ្ញុំយល់ពី>ការតាំងសំណួរ<លម្អិតតូចៗ>នេះ<ទេ> ព្រោះយើងៗនិយាយពីអ្នកដែលដឹកចាមទៅមន្ទីរសន្តិសុខហ្នឹង គឺថាប្រើរយៈពេល<ជិត>មួយម៉ោង។ ឥឡូវនេះ

តំណាងសហព្រះរាជអាជ្ញាបែរជាសួរឲ្យសាក្សីនេះស្មានទៅវិញ។ គាត់<បាននិយាយច្បាស់>ថា<គាត់បាន>ទម្លាក់<ជនជាតិ>ចាម<ទាំងអស់>ហ្នឹង <ហើយ>គាត់មិនដែលឃើញពួក<គេ>ជាថ្មីម្តងទៀតទេ។ ដូច្នេះការសួរបែបនេះ ខ្ញុំយល់ថាជាការសួរឲ្យសាក្សីឆ្លើយស្មានៗ។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

ខ្ញុំសូមឆ្លើយតប<ខ្លីៗ>ទៅវិញ លោកប្រធាន។ <ពិតហើយ> គាត់បានឆ្លើយហើយថា <គាត់>មិនដឹង<ថា>មានអ្វីកើតឡើងចំពោះជនជាតិចាមទាំងនោះទេ។ <បើសង្កេតមើល>សំណួរខ្ញុំ <ឲ្យច្បាស់>ហ្នឹង <គឺប្រាកដជាដឹងថា>ខ្ញុំសួរ<សំណួរទី២ទៅ>គាត់ <គឺសួរ>ថាតើគាត់បានដឹង<អ្វីខ្លះនៅពេលដែលមាន>អ្នកណាម្នាក់ដែល<ត្រូវ>បាន<គេ>ចាប់<ខ្លួន> ហើយបញ្ជូនទៅមន្ទីរសន្តិសុខហ្នឹង។ <ដូច្នេះនេះជាសំណួរខុសគ្នាទាំងស្រុង>។

[១៤:៥០:០០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តី ហើយអង្គជំនុំជម្រះត្រូវការស្តាប់ចម្លើយតបរបស់សាក្សីនេះ ចំពោះសំណួរចុងក្រោយនេះរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ។

សាក្សីឆ្លើយតបនឹងសំណួរចុងក្រោយនេះ!

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** ខ្ញុំសួរសំណួរនេះឡើងវិញ។ តើលោកមានបានដឹងថា មានអ្វីកើតឡើងទៅលើប្រជាជនដែលគេបានចាប់ខ្លួន និងបញ្ជូនទៅវត្តអូរត្រកួននៅក្នុងអំឡុងខ្មែរក្រហមនោះដែរទេ?

**លោក សេង ឃុយ៖**

**ឆ៖** ការចាប់ខ្លួនចាមនេះ គឺខ្ញុំមិនបានដឹងទេ គ្រាន់តែថានៅក្នុងអំឡុងឆ្នាំ១៩៧៧នោះ គឺជាទ្រង់ទ្រាយធំការបោសសម្អាត កាប់សម្លាប់របស់ខ្មែរក្រហមគ្រប់គ្រងនៅក្នុងភូមិ ក៏ដូចជាទូទាំងប្រទេសដែរ។ ខ្ញុំគ្រាន់តែដឹងប៉ុណ្ណឹង បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសចាប់ពីពេលនេះ រហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់

សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងសវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៥១ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរមួយចំនួន មុននឹងប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញាជាតិ។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកសាក្សី បើតាមលោកដឹង តើស្ត្រី និងកុមារជនជាតិចាមដែលបានចាប់ខ្លួន និងបញ្ជូនទៅវត្តអូរត្រកួន តើពួកគាត់មានបានធ្វើអ្វីខុសទេ? ហេតុអ្វីបានជាគេចាប់ខ្លួនពួកគាត់? តើមាន -- លោកដឹងពីមូលហេតុទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់<ចំពោះសំណួរនេះ> លោកប្រធាន។ ការសួរនេះគឺវាហួសពីអ្វីដែលសាក្សីបានដឹងឮហើយ ពីព្រោះថាគាត់មិនបានចូលរួមនៅក្នុងកងកម្លាំងសន្តិសុខដែលចាប់អ្នកទាំងអស់ហ្នឹងទេ។ ហើយគាត់ក៏មិនធ្វើការនៅក្នុងមន្ទីរសន្តិសុខដែរ។ <ឧទាហរណ៍ថា ខ្ញុំបានឃើញគេចាប់មនុស្សនៅពេលព្រឹកនេះ ខ្ញុំក៏មិនដឹងរឿងផ្ទៃក្នុងថា តើហេតុអ្វីបានជាមនុស្សទាំងអស់នេះត្រូវបានចាប់ខ្លួនដែរ> ដូច្នេះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<សំណួរនេះហួសពីការយល់ដឹងរបស់សាក្សី>។ <ខ្ញុំសូមជំទាស់។>

[១៥:០៥:៤១]

**លោក ចូសេហ្វ អេនគ្រូ ប៊ីយលី៖**

ខ្ញុំសូមឆ្លើយតប <លោកប្រធាន។> ខ្ញុំបាន<កម្រិត>សំណួរ<ទៅតាមការយល់ដឹងរបស់គាត់> ហើយ<គាត់មានសិទ្ធិឆ្លើយតបទៅតាមការយល់ដឹងរបស់គាត់>។ <បើសិនគាត់ដឹងព័ត៌មានណាមួយនោះ យើងអាចសាកសួរបន្ថែម ឬ>មេធាវីការពារក្តី<អាចសាកសួរបន្ថែម ថាតើព័ត៌មានទាំងអស់នោះបានមកពីណា។ ប៉ុន្តែគាត់មានសិទ្ធិពេញលេញក្នុងការផ្តល់ភស្តុតាង ឬក៏ព័ត៌មានដែលគាត់មាន ពាក់ព័ន្ធនឹង>មូលហេតុនៃការចាប់ខ្លួនជនជាតិចាមនេះ<>។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវី។ សាក្សីឆ្លើយតបទៅនឹងសំណួររបស់ សួរដោយសហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ។

**លោក សេង ឃុយ៖**

**ឆ៖** ខ្ញុំសូមឲ្យព្រះរាជអាជ្ញាសួរម្តងទៀតឲ្យបានច្បាស់លាស់ បាទ។ សូមសួរម្តងទៀត។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ីយលី៖**

**ស៖** បើតាមលោកដឹង តើមានមូលហេតុអ្វីដែលគេចាប់ខ្លួនជនជាតិចាមនៅក្នុងភូមិរបស់លោកដោយកងសន្តិសុខនោះ?

**ឆ៖** សូមជម្រាបជូនថា ការចាប់ខ្លួនចាម គឺខ្ញុំអត់បានដឹងទេបាទ។ ហើយប្រជាពលរដ្ឋចាមដែលគេចាប់ទៅហ្នឹងគឺជាអ្នកប្រជាជនស្លូតត្រង់មិនមានធ្វើអីខុសទេ បាទ ហើយខិតខំប្រឹងធ្វើការងារហើយបានត្រឹមត្រូវ បាទ។ ខ្ញុំសូមអស់។

[១៥:០៧:២៨]

**ស៖** ក្នុងរបបខ្មែរក្រហម តើលោកធ្លាប់ឃើញគេចាប់ខ្លួនអ្នកផ្សេងទៀតដែលមិនមែនជាជនជាតិចាមនៅក្នុងភូមិរបស់លោកទេ?

**ឆ៖** ខ្ញុំអត់ដែលបានឃើញទេ បាទ។

**ស៖** លោកសាក្សី ខ្ញុំចង់បានការពន្យល់ពីលោកពាក់ព័ន្ធទៅនឹងកំណត់ហេតុរបស់លោកថា ហេតុអីបានជាលោកឆ្លើយបែបហ្នឹង? ខ្ញុំសូមយោងទៅលើឯកសារ E3/5301, ERN ជាភាសា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អង់គ្លេស 00210483, ជាភាសាខ្មែរគឺ 00635169, បារាំងគឺ 00622400។ លោកបានឆ្លើយថា៖ "ខ្ញុំមិនដឹងថាហេតុអ្វីបានជាជនជាតិចាមត្រូវបានគេប្រមូល ហើយយកទៅអូរត្រកួនទេ។ ខ្ញុំដឹងថាក្នុង ១៩៧៧ មានការកាប់សម្លាប់ជាខ្លាំង។ <ខ្ញុំជឿថាពួកនោះមិនចង់ឲ្យជនជាតិចាមរស់នៅក្នុងភូមិនេះ ឬរស់នៅក្នុងប្រទេសកម្ពុជាទេ។>" លោកអាចបញ្ជាក់បានទេថា ហេតុអ្វីបានជាលោកឆ្លើយបែបហ្នឹងនៅក្នុងកំណត់ហេតុនេះ? <តើលោកចង់បានន័យថាម៉េច?>

**ឆ៖** បានជាខ្ញុំឆ្លើយប្រាប់ថា នៅក្នុងឆ្នាំ៧៧នេះ ខ្មែរក្រហមមានទ្រង់ទ្រាយកាប់សម្លាប់ខ្លាំង ព្រោះបានឮប្រជាពលរដ្ឋកន្លែងផ្សេងៗទៀតថា អ៊ូ! កន្លែងគេហ្នឹង ពួកខ្មែរក្រហមហ្នឹងបោសសម្អាតសម្លាប់ច្រើនណាស់។ ហើយមួយទៀត នៅក្នុងភូមិខ្ញុំហ្នឹងមានប្រជាជនថ្មីដែលជម្លៀសពីភ្នំពេញទៅ បួនដប់គ្រួសារដែរ ហើយយូរៗទៅបាត់អស់រលីង អត់ឃើញត្រឡប់មកវិញ។ អ៊ីចឹងនៅក្នុងអំឡុងឆ្នាំ ៧៧ គឺបញ្ជូនឲ្យទៅធ្វើការគឺបាត់អស់។ អ៊ីចឹងបានជាខ្ញុំសន្និដ្ឋានថា ជាផែនការបោសសម្អាតរបស់ខ្មែរក្រហម ហើយនៅក្នុងឆ្នាំ ៧៧ ហ្នឹង បាទ។

[១៥:០៩:៥២]

**ស៖** ហេតុអ្វីបានជាលោកនិយាយថា "ខ្ញុំយល់ថាពួកខ្មែរក្រហមមិនចង់ឲ្យជនជាតិចាមភាគតិចរស់នៅក្នុងភូមិនេះ ឬក្នុងប្រទេសកម្ពុជាទេ"។ ហេតុអ្វីបានជាលោកនិយាយឃ្លានេះនៅក្នុងឯកសារហ្នឹង?

**ឆ៖** ពីព្រោះជំនាន់ ប៉ុល ពត ខ្មែរក្រហមដឹកនាំហ្នឹង គឺគេមិនចង់ឲ្យមានសញ្ជាតិដែលពូជសាសន៍ក្រៅពីពូជសាសន៍ខ្មែរ គឺបើក្រៅពី -- សូម្បីតែខ្មែរក៏គេយកទៅសម្លាប់ដែរ សូម្បីជនជាតិក្រៅពីខ្មែរក៏គេមិនទុកដែរ បានជាខ្ញុំនិយាយថាមិនចង់ឲ្យមានចាម មិនចង់ឲ្យមានអ៊ីចឹងបាទ។

**ស៖** សូមអរគុណ សំណួរចុងក្រោយពាក់ព័ន្ធនឹងអ្វីដែលលោកបានឆ្លើយកាលពីមុន។ លោកបានបញ្ជាក់ថា ពេលដែលខ្មែរក្រហមចូលមកដល់ឃុំអង្គរបាន គេបញ្ជូនជនជាតិចាមហ្នឹងទៅភូមិ១ និងភូមិ៣។ តើលោកអាចបញ្ជាក់បានទេថា តើខ្មែរក្រហមចូលមកបានប៉ុន្មានខែ បានជាគេបញ្ជូនជនជាតិចាមចេញពីភូមិទាំងពីរហ្នឹង?

**ឆ៖** ត្រង់ចំណុចហ្នឹង ខ្ញុំមិនបានកំណត់ថាប៉ុន្មានខែ មានប៉ុន្មានខែទេ គ្រាន់តែបានដឹងថាដើមហេតុដំបូងហ្នឹង កាលពីខ្មែរក្រហមមិនទាន់មកគ្រប់គ្រងហ្នឹង គឺបងប្អូនចាមហ្នឹងរស់នៅភូមិអង្គរបានទី១ និងទី៣។ ហើយអ៊ីចឹងក្នុងអំឡុងពី៧៥ មក៧៩នេះ អត់មានបងប្អូនចាមនៅក្នុងភូមិអង្គរបានទី៣ និងទី១ទៀតទេ។ អ៊ីចឹងប្រហែលជាមិនដឹងគេជម្លៀសចេញទៅហើយ ហើយក៏មិនដឹងចេញជាជម្លៀសពីពេល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ណាដែរ គឺក្នុងអំឡុងពី៧៥ទៅទល់នឹង៧៩ហ្នឹង។ ជម្រាបជូនប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកសាក្សី។

**លោក ចូសេហ្វ អេនគ្រូ ប៊ីយលី៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអនុញ្ញាតប្រគល់វេទិកានេះជូនសហការីរបស់ខ្ញុំ លោកប្រធាន។

[១៥:១២:០៩]

**លោក សេង លាង៖**

ជាបឋមសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការនេះទាំងមូល។

**សួរដោយលោក សេង លាង៖**

**ស៖** ជម្រាបសួរលោកសាក្សី! ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិនៃការិយាល័យសហព្រះរាជអាជ្ញា។ ថ្ងៃនេះ ខ្ញុំមានសំណួរមួយចំនួនចង់ឲ្យលោកជួយបំភ្លឺដល់អង្គសវនា-ការ។ មុននឹងឈានចូលដល់ប្រធានបទដែលខ្ញុំត្រូវសួរ ខ្ញុំសូមសួរសំណួរមួយចំនួនដែលលោកទើបបានឆ្លើយអម្បាញ់មិញនេះ។ មុននេះ លោកសហព្រះរាជអាជ្ញាបានសួរលោកពាក់ព័ន្ធជាមួយនឹងសំណួរមួយដែលថា អានសម្រង់របស់លោក ហើយនៅក្នុងហ្នឹងគឺឯកសារ E3/5303, ERN ជាភាសាខ្មែរ 00635168, ជាភាសាអង់គ្លេស 00210483, និងជាភាសាបារាំង 00622400 – ERN ជាភាសាបារាំង 00622400។ នៅក្នុងហ្នឹងសម្រង់ហ្នឹង លោកនិយាយថា ខ្ញុំយល់ថាពួកខ្មែរក្រហមមិនចង់ឲ្យជនជាតិចាមភាគតិចរស់នៅក្នុងភូមិនេះ ឬនៅក្នុងប្រទេសកម្ពុជាទេ។ ហើយតមកក្រោមទៀត លោកបាននិយាយថា “ប្រជាជនចាមនៅក្នុងភូមិខ្ញុំដែលត្រូវចាប់ខ្លួននោះ មិនមានកំហុសអ្វីទេ។ ពួកគេប្រឹងប្រែងធ្វើការណាស់ មិនថាថ្ងៃ ឬយប់។ ចំពោះខ្ញុំពួកគេត្រូវបានចាប់ខ្លួន ដោយសារតែពួកគេជាជនជាតិចាម។ តើមានមូលដ្ឋានអីដែលនាំឲ្យលោកសន្និដ្ឋានយ៉ាងដូច្នេះ?

**លោក សេង យ៉ុយ៖**

**ឆ៖** បានជាខ្ញុំប៉ាានសន្និដ្ឋានថា គេមិនចង់ឲ្យជនជាតិចាម--

[១៥:១៤:២៨]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបលោកសាក្សី។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ហើយការពិតទៅខ្លឹមសារនៃសំណួរនេះវាហាក់ដូចជាបង្ហាញពីការសន្និដ្ឋានសួរបញ្ជាក់ទៅលើពីការសន្និដ្ឋានបន្ថែមទៀត។ ដូច្នេះ អ្វីដែលសាក្សីបាននិយាយនេះជាការសន្និដ្ឋានផ្ទាល់ខ្លួនទៅហើយ ហើយការសន្និដ្ឋាននេះវាមិនបានផ្តល់ ឬជួយស្វែងរកការពិតអីទេ ពីព្រោះលោកសាក្សីមិនមែនជាអ្នកជំនាញ ជាអ្នកផ្តល់ឯកទេសខាងការសន្និដ្ឋានទេ។ បាទ ដូច្នេះ ខ្ញុំសូមបដិសេធចំពោះធ្វើសន្និដ្ឋានបន្ថែមនេះ។ សូមអរគុណ។

**លោក សេង លាង៖**

លោកប្រធាន ខ្ញុំគិតថា នេះគឺជាសម្តីដែលបានលើកឡើងដោយលោកសាក្សី ហើយដូច្នេះ ខ្ញុំគ្រាន់តែចង់ដឹងថា តើគាត់ផ្អែកលើអីនាំឲ្យគាត់សន្និដ្ឋានអ៊ីចឹង។ ខ្ញុំមិនមែនសួរឲ្យគាត់សន្និដ្ឋានទេ។ ខ្ញុំសួររកមូលដ្ឋានដែលគាត់ -- នាំឲ្យគាត់សន្និដ្ឋាន។

[១៥:១៥:៣៨]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនៅសំណួរប្រភេទនេះទេ។

លោករកសំណួរផ្សេងទៀតសួរ លោកចាំថា ឲ្យច្បាស់ថា សាក្សីមិនត្រូវផ្តល់ចម្លើយជាសេចក្តីសន្និដ្ឋានទេ ហើយការឆ្លើយរបស់គាត់ ជារឿងរបស់គាត់ ប៉ុន្តែអ្នកដំណើរការនីតិវិធីមិនគប្បីទៅធ្វើអ្វីដែលវាឥតប្រយោជន៍ឈានដល់ស្វែងរកការពិតនោះឡើយ។

**លោក សេង លាង៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង លាង៖**

**ស៖** ឥឡូវខ្ញុំចាប់ផ្តើមសួរនូវសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងរចលនាសម្ព័ន្ធគ្រប់គ្រង។ លោកសាក្សី តើលោកដឹងទេថានរណាគេគឺជាលេខាស្រុកកងមាសនៅក្នុងសម័យគ្រប់គ្រងរបស់ខ្មែរក្រហម?

**លោក សេង ឃុយ៖**

**ឆ៖** តាមខ្ញុំដឹងក្នុងសម័យខ្មែរក្រហមនោះ ជំនាន់នុ៎ងគេហៅហ្វាយស្រុកបាទ ចៅហ្វាយស្រុកហ្នឹង គឺឈ្មោះ កាន ដែលគេចាត់តាំងពី -- គេចាត់ពីភូមិភាគនិរតីឲ្យមកកាន់ជាចៅហ្វាយស្រុកឈ្មោះ

កាន។

**ស៖** លោកមានប្រសាសន៍ថា កាន ហ្នឹងត្រូវបានគេចាត់តាំងមកពីនិរតីមកវិញ។ អ៊ីចឹង តើគាត់ក្លាយជាលេខាស្រុកកងមាសហ្នឹង នៅឆ្នាំណាដែរ?

[១៥:១៧:១៣]

**ឆ៖** ត្រង់កំណត់នៅឆ្នាំណាខ្ញុំមិនដឹងទេ។ គ្រាន់តែដឹងថា ឈ្មោះកាន ហ្នឹងធ្លាប់មកប្រជុំប្រជាពលរដ្ឋនៅក្នុងឃុំអង្គរបានហ្នឹង ថាគាត់ជាចៅហ្វាយស្រុក ហើយគេចាត់ពីភូមភាគនិរតីមកបាទ។ សូមជ្រាប។ ប៉ុន្តែគាត់មកប្រជុំនេះ គឺនៅក្នុងឆ្នាំ៧៧ហ្នឹង បាទ។

**ស៖** តើលោកអត់ដឹងច្បាស់ថា គាត់មកពេលណាទេអ៊ីចឹង?

**ឆ៖** បាទ សំណួរនេះមិនដឹងច្បាស់ទេ ព្រោះខ្ញុំជាប្រជាពលរដ្ឋនៅតាមភូមិដ្ឋានបាទ។

**ស៖** តើលោកដឹងថា នរណាគេ គឺជាសន្តិសុខនៅវត្តអូរត្រកួនដែរឬទេ?

**ឆ៖** ខ្ញុំដឹង គឺសន្តិសុខនៅវត្តអូរត្រកួនហ្នឹង គឺឈ្មោះ ហាន។

**ស៖** ហាន ហ្នឹងមកពីណាដែរលោក?

**ឆ៖** បាទ បានដឹងហ្នឹងដោយសារតាមរយៈចៅហ្វាយស្រុក កាន ហ្នឹងគាត់ទៅប្រជុំហ្នឹង គាត់ហៅ ហាន ហ្នឹងទៅជាមួយ ហើយគាត់ប្រកាសប្រាប់ប្រជាជនហ្នឹងថា ហាន ហ្នឹងមកពីនិរតីជាមួយគាត់ បានខ្ញុំដឹងហ្នឹង។

**ស៖** អ៊ីចឹងបានន័យថា តាមអ្វីដែលលោកដឹងហ្នឹង គឺ ហាន -- កាន បានប្រាប់ថា ហាន មកជាមួយ គាត់អ៊ីចឹង? តែពេលណាពិតប្រាកដលោកអត់ដឹងទេ ឬយ៉ាងម៉េច?

[១៥:១៩:១៦]

**ឆ៖** តាមកំណត់នៅឆ្នាំដែលគេមកធ្វើការ គឺខ្ញុំអត់បានដឹងទេ បាទ។

**ស៖** អ៊ីចឹងតើលោកអាចប្រាប់បានទេ នៅពេលដែល កាន ហើយនិង ហាន មកដល់ហ្នឹង តើការឃាត់ខ្លួនជនជាតិចាម ១៥នាក់ ដែលលោកបានលើកឡើងហ្នឹង គេធ្វើនៅពេលណាដែរ?

**ឆ៖** ការចាប់ជនជាតិចាម ១៥នាក់ហ្នឹង គឺគេធ្វើនៅក្នុងជំនាន់ ហាន និង កាន ហ្នឹងគ្រប់គ្រងហើយ។

**ស៖** តើលោកមានដឹងពីបញ្ហាមួយចំនួនដូចជាការផ្លាស់ប្តូរកម្មាភិបាលនៅបូព៌ាដោយកម្មាភិបាលមកពីនិរតីដែរឬទេ?

**ឆ៖** ត្រង់សំណួរនេះ ខ្ញុំអត់បានដឹងទេទាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្ដីលោកនួន ជា – លោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមែនជាការជំទាស់ទេលោកប្រធាន ប៉ុន្តែតាមរយៈការបកប្រែ ខ្ញុំឮសួរសួរ និយាយអំពីការជំនួសកម្មាភិបាលភូមិភាគបូព៌ា គឺនៅតំបន់៤១នៃភូមិកណ្ដាល ឮសួរសួរពាក្យថា "មកជំនួសកម្មាភិបាលភូមិភាគបូព៌ា"។

[១៥:២១:១៥]

**លោក សេង លាង៖**

សូមទោសលោកប្រធាន ខ្ញុំប្រហែលច្រឡំទេ គឺភូមិភាគកណ្ដាល។ ខ្ញុំនិយាយច្រឡំ សុំទោស។

**សួរដោយលោក សេង លាង៖**

**ស៖** អ៊ីចឹង តើលោកមានដឹងទេអំពីទំនាក់ទំនងរវាង កាន ហើយនិង ហាន ហ្នឹង តើគេធ្វើការគេទំនាក់ទំនងគ្នាយ៉ាងម៉េចដែរ? លោកមានដឹងទេ?

**លោក សេង ឃុយ៖**

**ឆ៖** ការងារនេះខ្ញុំគ្រាន់តែដឹងថា ឈ្មោះកាន ហ្នឹង គឺគាត់ជាចៅហ្វាយស្រុក ហើយឈ្មោះ ហាន ហ្នឹងគេឱ្យទទួលខុសត្រូវជាប្រធានសន្តិសុខស្រុក ប្រចាំការនៅក្នុងវត្តអូរត្រកួនហ្នឹងតែម្ដង បាទ គ្រាន់តែដឹងប៉ុណ្ណឹង។

**ស៖** តើលោកស្គាល់វត្តអូរត្រកួនហ្នឹងតាំងពីពេលណាដែរ? លោកអាចប្រាប់បានទេ?

**ឆ៖** ខ្ញុំស្គាល់ច្បាស់ពីព្រោះវត្តអូរត្រកួនហ្នឹងនៅមិនឆ្ងាយពីភូមិខ្ញុំប៉ុន្មាន ហើយខ្ញុំតាំងពីតូចមកធ្លាប់ ក្រុមគ្រួសារទៅធ្វើបុណ្យទាននៅចំណុះវត្តអូរត្រកួនហ្នឹងតែម្ដងបាទ។

**ស៖** មុនពេលដែលគេប្រើលោកឱ្យដឹកប្រជាជនចាម ១៥នាក់ហ្នឹងទៅហ្នឹង តើលោកដឹងថាទីហ្នឹងគឺជាមន្ទីរសន្តិសុខដែរឬទេ?

**ឆ៖** ខ្ញុំដឹងនៅពេលគេចាត់ឱ្យទៅហ្នឹង ថាទៅវត្តអូរត្រកួនហ្នឹង គឺជាកន្លែងសន្តិសុខ បាទខ្ញុំដឹង។

**ស៖** លោកដឹងមុនពេលគេចាត់ឱ្យទៅ ឬនៅពេលដែលលោកទៅដល់ហើយ?

**ឆ៖** តាមដឹង កន្លែងវត្តអូរត្រកួនហ្នឹង គឺគេដាក់កន្លែងសន្តិសុខហ្នឹងតាំងពីសម័យ ប៉ុល ពតចូល

ទៅគ្រប់គ្រង គឺគេដាក់កន្លែងហ្នឹងជាកន្លែងសន្តិសុខតែម្តង។ អ៊ីចឹង តាំងពីចូលទៅគឺគេកំណត់កន្លែងវត្ត អូរត្រកួនហ្នឹង បាទ។ មិនមែនទើបតែដឹងថា ពេលគេដឹកចាមទៅបានដឹង គឺដឹងតាំងពីមុនដែរ។

[១៥:២៣:៥៥]

**លោក សេង លាង៖**

អរគុណលោកប្រធាន ដោយសារពេលវេលា ខ្ញុំប្រគល់វេទិកានេះ ជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសួរសំណួរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ចំពោះសាក្សីរូបនេះ មេធាវីនាំមុខសូមអនុញ្ញាតផ្ទេរសិទ្ធិជូនលោកមេធាវី ហុង គឹមសួន ដើម្បីសួរលោកសាក្សីរូបនេះ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោកមេធាវី ហុង គឹមសួន!

**លោក ហុង គឹមសួន៖**

បាទ សូមអរគុណ។ បាទ សូមគោរពលោកប្រធាន និងលោកស្រី លោកចៅក្រម ព្រមទាំងអង្គសវនាការជាទីគោរព។

[១៥:២៤:៥៨]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** ជម្រាបសួរលោកសាក្សី! ខ្ញុំបាទឈ្មោះ ហុង គឹមសួន ជាមេធាវីមកពីអង្គការគោរពអ្នកច្បាប់ការពារសិទ្ធិកម្ពុជា និងជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំធ្វើការសាកសួរលោកនូវសំណួរខ្លះៗទាក់ទងជាមួយនឹងការឆ្លើយរបស់លោកក្នុងថ្ងៃនេះ។ លោកទើបតែនឹងបញ្ចប់ការឆ្លើយសំណួររបស់លោកសហព្រះរាជអាជ្ញាអម្បាញ់មិញច្រើនរួចមកហើយ អ៊ីចឹងខ្ញុំសួរចោះៗទេ ទាក់ទងជាមួយនឹងលោកបានជម្រាបជូនអង្គសវនាការអំពីទំនាក់ទំនងទៅលើជនជាតិខ្មែរអ៊ិស្លាម ឬជនជាតិចាម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នេះ។ ខ្ញុំសួរលោកបន្តិច ទាក់ទងជាមួយនឹងការរស់នៅដូចលោកបានជម្រាបជូនអង្គសវនាការហើយថា លោករស់នៅ នៅក្នុងភូមិអង្គរបាន ឬក៏ឃុំអង្គរបាននេះ សឹងតែមួយជីវិតលោកទៅហើយ។ ហើយលោកបានជម្រាបអំពីភូមិចាមនៅជាប់នឹងភូមិរបស់លោក អង្គរបានទី១ និងអង្គរបានទី៣។ អ៊ីចឹងកន្លែងនេះ ខ្ញុំចង់សួរបន្តិចថាតើ ពាក្យថាៗ "អង្គរបានទី១ អង្គរបានទី៣" ហ្នឹង ភូមិរបស់លោក អង្គរបានទី២ មែនទេ? ចាំមានភ្លេងសិនលោក?

**លោក សេង ឃុយ៖**

**ឆ៖** សូមជម្រាបជូនថា នៅក្នុងឃុំអង្គរបាននេះ គឺមានប្រាំបួនភូមិ គឺភូមិអង្គរបានទី១, ទី២ ទី៣ រហូតទី៩ តែម្តង។ ហើយភូមិអង្គរបានទី២នេះ គឺជាភូមិ ជាស្រុកកំណើត និងជាទីកន្លែងដែលខ្ញុំរស់នៅរហូតមកទល់សព្វថ្ងៃនេះ បាទ។

**ស៖** បាទ សូមអរគុណ។ តើភូមិខ្មែរមានប៉ុន្មានភូមិ និងភូមិចាមមានប៉ុន្មានភូមិ នៅក្នុងឃុំអង្គរបាន បាទ?

[១៥:២៦:៣១]

**ឆ៖** នៅក្នុងឃុំអង្គរបាន មានចំនួនប្រាំបួនភូមិ ប៉ុន្តែនៅក្នុងហ្នឹង នៅភូមិអង្គរបានទី១ហ្នឹង មិនមែនសុទ្ធតែ ទី១ និងទី៣ហ្នឹង មិនមែនសុទ្ធតែបងប្អូនចាមសុទ្ធទេ គឺភូមិអង្គរបានទី១ មានចំនួនឧទាហរណ៍បច្ចុប្បន្ននេះ ខ្ញុំជម្រាបជូនថាបច្ចុប្បន្ននេះ គឺពាក់កណ្តាលម្នាក់ ហើយអង្គរបានទី៣នេះ ក៏មានបងប្អូនចាមពាក់កណ្តាល ខ្មែរពាក់កណ្តាល បាទ គឺរស់នៅចូលលាយគ្នា មិនមែនដាច់តែឡែកដោយឡែកទេ បាទ។

**ស៖** បាទ សូមអរគុណ។ នេះ ខ្ញុំសួរពីជំនាន់មុនសម័យខ្មែរក្រហមបន្តិច ទាក់ទងជាមួយនឹងភូមិនេះ មានផ្លាស់ប្តូរពីមុនជំនាន់១៩៧៥ មកសម័យក្រោយមួយពាន់ប្រាំបួនរយ-- ក្រោយ០៦ មករា ១៩៧៩ នេះ ឈ្មោះ ភូមិ និងឃុំហ្នឹង មានផ្លាស់ប្តូរគ្នាដែរទេ?

**ឆ៖** បាទ នៅភូមិអង្គរបានទី១ មុនខ្មែរក្រហម គេហៅភូមិអន្ទង់ស ប៉ុនដល់មកក្រោយហ្នឹង គេដាក់ ជំនាន់ខ្មែរក្រហមហ្នឹង កងទី១ ជាប់រហូតមក។ កងទី១ គឺភូមិទី១រហូតមកហ្នឹង បាទ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំសូមចូលទៅក្នុងសំណួរអំពីទំនាក់ទំនងនៃប្រជាពលរដ្ឋជាជនជាតិចាម។ លោកបានជម្រាបជូនអង្គសវនាការ អំពីថាលោកមិនមានការជិតស្និទ្ធអីជាមួយនឹងបងប្អូនជនជាតិចាមទេ ប៉ុន្តែបានជម្រាបជូនអំពីការរស់នៅហ្នឹង មានផ្លូវមួយជាផ្លូវរួម នៅក្នុងភូមិ ក្នុងឃុំនោះ។

អ៊ីចឹងខ្ញុំមិនសួរអំពីភាពជិតស្និទ្ធទេ ខ្ញុំគ្រាន់តែសួរការប៉ាន់ស្មាន ប្រហាក់ប្រហែលដែលលោកដឹង មុនពេលសម័យខ្មែរក្រហមចូលកាន់កាប់គ្រប់គ្រងប្រទេស ឬទឹកដីរបស់លោកហ្នឹង តើលោកអាចដឹងខ្លះៗទេ ថាប្រហាក់ប្រហែលជាប៉ុន្មានដែរ ប្រជាពលរដ្ឋចាមនៅក្នុងឃុំអង្គរបាន?

**ឆ៖** តាមខ្ញុំប៉ាន់ស្មាន មិនច្បាស់ដែរ ពីព្រោះជំនាន់ហ្នឹង ខ្ញុំអត់បានយកចិត្តទុកដាក់ និងសួរនាំ ហើយក៏ចង់ដឹងថា តើចាមពីរភូមិហ្នឹង នៅក្នុងឃុំអង្គរបានមានចំនួនប៉ុន្មាន ដល់អ៊ីចឹងខ្ញុំមិនអាចជម្រាបជូនដោយមិនច្បាស់លាស់បានទេ បាទ សូមអរគុណ។

[១៥:២៩:០៥]

**ស៖** អ៊ីចឹងសំណួរខ្ញុំសួរអ៊ីចេះវិញ បាទ លោកខ្ញុំមិនសួរឲ្យប៉ាន់ឲ្យចំៗទេ សួរថា ព្រោះអីភូមិជាប់គ្នា ភាគច្រើន យើងអាចដឹងៗថា អ៎ូ! អ្នកនេះ នៅភូមិនេះ នៅភូមិនោះដែរ តែមិនដឹងថាចំនួនប៉ុន្មាននាក់ទេ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់សួរថា វាមានច្រើន មានតិច អ៊ីចឹងតែប៉ុណ្ណឹងទេ បាទ។ តើលោកអាចបញ្ជាក់បានបន្តិចទេ?

**ឆ៖** បាទ សូមអធ្យាស្រ័យត្រង់សំណួរត្រង់នេះ ចាកបន្តិច ប៉ុន្តែខ្ញុំគ្រាន់តែប្រៀបធៀបថា បើគិតចំនួនប៉ាន់ស្មានប្រជាជនចាមរាល់ថ្ងៃនេះ ដែលខ្ញុំគ្រប់គ្រង ពីព្រោះរាល់ថ្ងៃនេះខ្ញុំជាមេឃុំ។ អ៊ីចឹងប៉ាន់ស្មានប្រជាជនពីដើមហ្នឹង ប្រហែលជាមិនខុស មិនត្រូវប៉ុន្មានទេ ពីព្រោះប្រជាជនពីដើម ចាមពីដើមហ្នឹង ផ្ទះគាត់នៅត្រង់កន្លែងណា ដល់មកឥឡូវ គាត់នៅពេញទាំងអស់វិញ អ៊ីចឹងមានចំនួនប្រហែលជាតាម ប៉ាន់ស្មានមានចំនួនប្រហែលជាបួនរយគ្រួសារជាង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំសូមសួរអ៊ីចេះវិញ លោកថាបើចំនួនប្រជាពលរដ្ឋ លោកមិនអាចប៉ាន់ស្មានបានមែន ប៉ុន្តែភូមិឃុំពីមុនធ្លាប់មានរស់នៅប្រហែលប៉ុន្មាន ឥឡូវហ្នឹងប្រហាក់ហែលវិញ អ៊ីចឹងចន្លោះពីឆ្នាំ១៩៧៩ -- សូមទោស ក្រោយថ្ងៃ០៦ មករា ១៩៧៩ ឬចាប់ពីថ្ងៃ០៧ មករា ឡើងមកក្នុងឆ្នាំទី១ គឺឆ្នាំ១៩៧៩ដដែល។ តើភូមិរបស់លោក (ខ្ញុំសួរភូមិទេណ៎ះ!) ឬក៏ភូមិជាប់នោះ មានប្រជាពលរដ្ឋចាមប្រហែលជាប៉ុន្មានគ្រួសារដែរ?

**ឆ៖** នៅពេលប្តូររលំរបបប៉ុល ពត ឆ្នាំ៧៩មកហ្នឹង គឺអត់មានទេ នៅក្នុងភូមិអង្គរបានទី១ និងទី៣ ហ្នឹង គឺអត់ទាន់មានទេបាទ គឺអស់រលីងហ្នុង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងអ្វីដែលលោកអះអាងអំមិញ មានន័យថា ចេះតែនាំគ្នាមកនៅក្រោយៗមកទៀតទេ អ៊ីចឹងមែនទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** សូមសួរម្ដងទៀត។

**ស៖** សួរម្ដងទៀតបើលោកមិនចាំ។ ខ្ញុំចង់សួរថា ក្រោយពេលដែលអ្នកមកនៅថ្មីក្រោយៗឡើងមកទៀតនេះ គឺជាអ្នកមកថ្មីទេ ឬមិនមែនទេ? ហើយអ្នកចាស់នោះ តើមាននៅសល់ទេ?

**ឆ៖** តាមខ្ញុំពិនិត្យមើល ប្រជាពលរដ្ឋចាមដែលមករស់នៅសព្វថ្ងៃក្នុងភូមិអង្គរបានហ្នឹង គឺប្រហែលជាចូលមករស់នៅហ្នឹង នៅឆ្នាំ៨២, ៨៣ ចេះតែបន្តបន្ទាប់ហូរហែរមក។ តាមខ្ញុំសួរនាំហ្នឹង ខ្លះមកពីបាត់ដំបងទៅ សៀមរាបទៅ ពោធិ៍សាត់អ៊ីចឹងទៅ បាទ។

[១៥:៣២:១៥]

**ស៖** បាទសូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមចូលទៅក្នុងរឿងការប្រព្រឹត្តទៅលើជនជាតិចាម។ ខ្ញុំសួរបន្តអំពីសំណួររបស់លោកព្រះរាជអាជ្ញា ត្រង់កន្លែងដែលលោកថា កំពុងតែហូបបាយ ពេលព្រលប់មួយ នៅឆ្នាំ១៩៧៧ ឃើញកងសន្តិសុខបានទៅចាប់ចាម នៅពេលកំពុងហូបបាយនៅរោងបាយ។ អ៊ីចឹងខ្ញុំមិនទាន់និយាយដល់ពេលចាប់ទេ ខ្ញុំចង់សួរអំពីថា តើគេក្នុងសម័យខ្មែរក្រហមហ្នឹង គេបំបែកប្រជាពលរដ្ឋចាម និងប្រជាពលរដ្ឋខ្មែរឲ្យហូបផ្សេងគ្នា ឬក៏ហូបយ៉ាងម៉េច?

**ឆ៖** បាទ ក្នុងជំនាន់ខ្មែរក្រហមហ្នឹង ការហូបចុកនៅក្នុងរោងបាយហ្នឹង គឺហូបរួមគ្នាតែមួយបាទមិនមានបែងចែកទេបាទ។

**ស៖** តើលោកអាចជម្រាបជូនបានទេ ពេលហូបហ្នឹង តើមានម្ហូបដោយឡែក ចាមផ្សេង ខ្មែរផ្សេង ឬក៏ដូចគ្នាបាទ?

**ឆ៖** ម្ហូបនៅពេលហូបបាយរវាងជនជាតិខ្មែរ និងជនជាតិចាមហ្នឹង គឺម្ហូបដូចគ្នា តែមួយមុខយើងថាមួយមុខចុះ មិនមានបែងចែកម្ហូបចាមដោយខ្លួន ខ្មែរដោយខ្លួនទេបាទ។

**ស៖** បាទ សូមអរគុណ។ សំណួរមួយទៀតទាក់ទងជាមួយនឹងម្ហូបអាហារដដែល លោកបានជម្រាបជូនអង្គសវនាការទាក់ទងដែលលោកដឹងថា ជនជាតិចាម ប្រពៃណីរបស់គាត់មិនហូបសាច់ជ្រូកដាច់ខាត។ ចុះនៅក្នុងពេលរស់នៅជាមួយគ្នា នៅក្នុងភូមិរបស់លោក ឬក៏នៅពេលទៅហូបបាយរួមគ្នាហ្នឹង តើជនជាតិចាមមានការបង្ខំឲ្យហូបសាច់ជ្រូកដែរឬទេ?

**ឆ៖** នៅត្រង់ចំណុចហូបសាច់ជ្រូកនេះ គឺខ្ញុំមិនបានឮប្រធានកងថា កំណត់ថាត្រូវតែហូបទេ ប៉ុន្តែកន្លងមក បើម្ហូបនៅរោងបាយហ្នឹងមានអីហូប គឺត្រូវតែហូបជាមួយគ្នាទាំងអស់ហ្នុង ទាំងចាមទាំងខ្មែរហ្នឹង អង្គុយនៅតុហ្នឹង។ បាទ សូមជម្រាបជូនអ៊ីចឹង។

**ស៖** តើលោកមានដែលសម្គាល់ឃើញទេ បើសិនជាមានចាមណាមួយដែលគាត់មិនព្រមហូប តើមានរឿងអ្វីកើតឡើងដល់លើខ្លួនគាត់ដែរទេ ឬមានទារុណកម្មជាដើម អានេះសួរឲ្យចំ ស្រួលឆ្លើយ?

[១៥:៣៤:៥២]

**ប្រធានអង្គជំនុំ៖**

ប្រភេទឧបមាវិធីហ្នឹងយើងមិនឲ្យសាក្សីឆ្លើយទេបាទ អត់មានបើសិននេះទេ អត់ទាន់ឃើញសួរបង្កើតមានអង្គហេតុហ្នឹងអត់ផង។

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបាទសូមប្តូរសំណួរទៅវិញ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** តើមានការហូបសាច់ជ្រូកនៅក្នុងរោងបាយរួមហ្នឹងជាមួយនឹងជនជាតិចាម ហើយជនជាតិចាមហូបសាច់ជ្រូក តម្រូវឲ្យហូបសាច់ជ្រូកអីចឹងដែរឬទេ?

**លោក សេង ឃុយ៖**

**ឆ៖** គ្រាន់តែជម្រាបថា ការហូបម្ហូបអាហារនេះ គឺខ្ញុំមិនបានចុះស្ថិតស្ថេរទេ ពីព្រោះខ្ញុំជាប្រជាពលរដ្ឋព្រលឹមឡើងចុះទៅភ្ជួររាស់ ហើយវាអត់បានសួរហូបអីនៅជាមួយចាមអីនៅជុំទេ។ កំណត់ព្រឹកឡើងទៅបាត់ ហើយដល់យប់អីបានមក ជួនអីក៏បានជួបគ្នា ទៅជួនក៏មិនបានជួបគ្នាទៅ។ ប៉ុន្តែគ្រាន់តែជម្រាបថា បើរោងបាយនេះគេស្លសាច់ជ្រូក ត្រូវតែហូបម្ហូបហ្នឹងទាំងអស់គ្នា ត្រង់ចាមនុ៎ងគាត់ហូបឬមិនហូប ខ្ញុំមិនបាននៅមើលឃើញផ្ទាល់ទេទាន។ បាទ នេះជាការពិត។

[១៥:៣៦:១០]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមចូលសួរទៅក្នុងសំណួរមួយទៀតទាក់ទងអំពីការចាប់មនុស្សដែលជាជនជាតិចាមនៅពេលដែលលោកបានជម្រាបជូនអង្គសវនាការអំពីពេលហូបបាយនៅពេលនោះដែរក្នុងឆ្នាំ១៩៧៧។ មុនពេលការចាប់ខ្លួននេះ តើមានការប្រជុំប្រាប់ ព្រោះកងលោកកងដឹក តាមក្នុងឯកសារអំពីអ្នកដឹក ហើយក៏ជម្រាបជូនអង្គសវនាការអំមិញ។ តើមានការប្រាប់ជាសម្ងាត់មុនឬទេចំពោះក្រុមដឹកជញ្ជូនរទេះរបស់លោក?

**ឆ៖** សូមជម្រាបជូនអីចេះថា ត្រង់សំណួរថាខ្ញុំជាក្រុមរទេះដឹកហ្នឹង គឺមិនមែនទេ។ ខ្ញុំជាប្រជាពលរដ្ឋទៅភ្ជួររាស់ ប៉ុន្តែនៅពេលគេចាប់នោះ គឺគេចាត់ឲ្យខ្ញុំហ្នឹងទៅយករទេះគោហ្នឹងទៅចូលរួមដឹក។

ហើយការចាប់ ការអីនោះ គឺមិនមានផែនការអីដឹងមុនទេ ស្រាប់តែអង្គុយ កំពុងតែអង្គុយហូបបាយហ្នឹង ស្រាប់តែគេមក កងសន្តិសុខគេមកបួនប្រាំនាក់ ព្រឹបៗចាប់ចងអីតែម្តងបាទ។

**ស៖** បាទ សូមអរគុណ។ សូមសួរលោកទាក់ទងជាមួយនឹងការចាប់។ អំមិញលោកបានជម្រាបជូនអំពីថា ភាគច្រើនគឺស្ត្រីនិងកុមារ។ តើនៅពេលដែលខាងសន្តិសុខចាប់ស្ត្រី និងកុមារនោះអ្នកដែលមកចាប់ហ្នឹងគេមានឲ្យអ្នកណាដើរចង្អុល ឬគេមកដល់គេដឹង ឬគេស្គាល់ខ្លួនគេ ឬគេចាប់ព្រឹបៗតែម្តង?

**ឆ៖** នៅក្នុងចំណុចហ្នឹង គឺខ្ញុំមិនបានដឹងច្បាស់លាស់ដែរ។ ប៉ុន្តែខ្ញុំគ្រាន់តែនៅកំពុងអង្គុយហូបបាយហ្នឹងមកដល់គឺគេចាប់ព្រឹបៗ ពីព្រោះឈ្មោះ រុន ហ្នឹងគាត់ស្រុកកំណើតអីនៅជាប់ ហើយគាត់ស្គាល់ចាមស្គាល់អីច្បាស់លាស់។ អ៊ីចឹងគាត់និងបក្ខពួកកូនចៅរបស់គាត់ហ្នឹង សន្តិសុខហ្នឹងគាត់ប្រហែលជាចាប់ខ្លួនគាត់តែម្តងក៏មិនដឹង ពីព្រោះខ្ញុំអត់បានទៅឃើញគេចាត់ឲ្យអ្នកណាទៅចង្អុលទៅអីគ្រាន់តែឃើញគេមកភ័យរៀងខ្លួនបាទ។

[១៥:៣៨:៤៣]

**ស៖** បាទ សូមអរគុណបាទ។ នៅពេលដែលការចាប់ខ្លួនហ្នឹងមានការប្រមាថកាតទានទៅលើអ្នកដែលត្រូវចាប់ខ្លួនហ្នឹងដែរទេ? លោកមានឮសួរគេនិយាយប្រមាថមើលងាយអីដែរទេ?

**ឆ៖** បាទ នៅពេលចាប់ភ្លាមៗហ្នឹងមានលេចឮដែរ ប្រធានកងសន្តិសុខឃុំហ្នឹងមានជេរអ៊ីចឹងដែរ។ ជេរថាអាចាមអាអ៊ីចឹង ក្បត់ជាមួយអង្គការ អ៊ីចឹងត្រូវតែបោសសម្អាតអី។ បាទ មានឮពាក្យអីហ្នឹងខ្លះដែរបាទ។

**ស៖** បាទ តើនៅពេលដែលចាប់ហ្នឹងគេចង ឬក៏គេចងមុខ ចងដៃយ៉ាងម៉េចដែរ មានធ្វើអ៊ីចឹងដែរទេ?

**លោក គង់ សំអុន៖**

លោកប្រធាន សូមជំទាស់ ព្រោះវាជាសំណួរច្រំដែល។ បាទ សូមអរគុណ។

**លោក ហុង គីមសួន៖**

ខ្ញុំបាទសូមជម្រាបជូនបន្តិចផងដែរទាក់ទងនឹងការចងនេះ។ ខ្ញុំបាទចង់ដឹង ព្រោះមិនទាន់មានសំណួរចងភ្នែកអីទេ បានខ្ញុំបាទសួរ។

**ប្រធានអង្គជំនុំ៖**

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

បាទ បដិសេធនូវសេចក្ដីជំទាស់។ អញ្ជើញសាក្សីឆ្លើយតប!

**លោក សេង ឃុយ៖**

**ឆ៖** សូមជម្រាបជូនថា ការចងនេះ គឺចងតែស្លាបសេកទៅក្រោយទេ ដោយខ្សែនីឡុង ហើយមិនមានឃ្នុំមុខទេ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** បាទ សូមអរគុណ។ អំមិញខ្ញុំសួរអំពីប្រមាថកាតទាន ប៉ុន្តែឥឡូវនេះខ្ញុំសួរថាតើមានវ៉ៃដំច្រំធាក់អីហ្នឹងមុននឹងបញ្ជូនឡើងរទេះដែរទេ?

**លោក សេង ឃុយ៖**

**ឆ៖** បាទ នៅពេលចាប់ចងរួចហ្នឹង គឺមិនមានវ៉ៃដំច្រំធាក់ ប៉ុន្តែរុញឡើងរទេះ ព្រោះជាប់ចំណងហើយ ពួកសន្តិសុខហ្នឹង។ ក្មេងតូចៗអីក៏លើកបោះទៅ ហើយមនុស្សចាស់នេះគឺចាប់រុញឡើង មិនមានវ៉ៃដំអីទេបាទ។

**ស៖** តើមុនពេលចេញដំណើរក្រុមៗរទេះនេះ ខ្ញុំចង់និយាយថា ដោយសារលោកមានប្រសាសន៍អំពីថា រទេះប្អូនប្រាំដែលដឹកប្រជាពលរដ្ឋចាមយកទៅមន្ទីរសន្តិសុខ។ អ៊ីចឹងខ្ញុំប្រើពាក្យថា "ក្រុម"ដោយសាររទេះច្រើន។ អ៊ីចឹងតើមុនពេលចេញដំណើរក្រុមរទេះហ្នឹង មានការហាមឃាត់មិនឱ្យប្រជាជនចាមដែលបោះដាក់រទេះ ឬក៏ចងដាក់នៅលើរទេះហ្នឹងយំយែក ឬក៏ហាមមិនឱ្យស្រែក ហាមមិនឱ្យនិយាយគ្នាមាននិយាយពាក្យហ្នឹងទេ ឬមានហាមប្រាមអ៊ីចឹងទេ?

[១៥:៤១:៥១]

**ឆ៖** សូមជម្រាបជូនថា នៅក្នុងសំណួរនេះ ខ្ញុំមិនបានឮប្រធានកង ឬក៏សន្តិសុខអីហាមឃាត់ទេ ប៉ុន្តែនៅពេលដឹកទៅ គឺមិនប៉ានយំស្រែកអីទេ គឺស្ងាត់។

**ស៖** សូមអរគុណ។ ចុះនៅពេលដែលទៅដល់មុខខ្លោងទ្វារវត្ត នៅពេលដែលដាក់ចុះហ្នឹង តើគេធ្វើយ៉ាងម៉េច គាត់ចុះយ៉ាងម៉េចពីលើរទេះទៅដី?

**ឆ៖** បាទ នៅត្រង់ចំណុចចុះនេះគឺមនុស្សចាស់អី គាត់ចុះខ្លួនគាត់អ៊ីចឹងទៅ រួចមនុស្សតូចៗអីក្មេងតូចអីយើងជួយលើកដាក់ចុះទៅហ្នឹង ពីព្រោះដៃជាប់ចំណងអី។

**ស៖** យើងហ្នឹងជាយើងជាអ្នកបរទេះ--

**ឆ៖** យើងហ្នឹងអ្នកបររទេះហ្នឹង។ បើមិនជួយលើកទៅវាចុះអត់រួចក្មេងតូចហ្នឹងបាទ។

**សៈ** បាទ សូមអរគុណ។ អ៊ីចឹងនៅពេលដែលចុះពីលើរទេះមុននឹងបញ្ចូលទៅក្នុងវត្ត តើអ្នកដែលមកទទួលហ្នឹង គេជាអ្នកណាលោកដឹងទេ ចង់និយាយថាជាស៊ីវិល ឬជាយោធារបស់ខ្មែរក្រហម?

**ឆៈ** អ្នកដែលមកទទួលហ្នឹង គឺយើងខ្ញុំមិនបានស្គាល់ទេ ហើយក៏មិនបានឃើញមុខមាត់យ៉ាងម៉េច ពីព្រោះមេឃងងឹត ហើយម៉ោង ងងឹតខ្លាំង គ្រាន់តែឃើញខ្មៅស្ទង់ៗ ប៉ុន្តែគេគ្រាន់តែប្រាប់ថា ដាក់រួចរទេះត្រឡប់ផ្ទះវិញចុះ។ បាទ ឮសំឡេងប៉ុណ្ណឹង។

**សៈ** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំសួរទាក់ទងជាមួយនឹងប្រុសៗដែលជាប្ដី ឬក៏ជាសមាជិកគ្រួសារដែលលោកបានជម្រាបជូនអង្គសវនាការអំពីថា បញ្ជូនខ្លួនគាត់ចេញ ឬក៏ទៅកងចល័តឆ្ងាយ។ តើក្នុងប្អូនប្រាប់នាក់ដែលលោកបានជម្រាបជូនលោកប្រធានអម្បាញ់មិញហ្នឹង ដែលឃើញពួកគេត្រឡប់មកភូមិវិញដែរទេ?

**ឆៈ** ចំពោះប្ដីហ្នឹង គឺអត់ដែលឃើញទេបាទ តាំងពីថ្ងៃចាប់ប្រពន្ធទៅមកទល់រាល់ថ្ងៃហ្នឹងក៏មិនដែលឃើញដែរបាទ។

[១៥:៤៤:១៣]

**សៈ** បាទ សូមអរគុណ។ ក្នុងឯកសាររបស់លោក ឬក៏លោកបានជម្រាបជូនលោកប្រធានអម្បាញ់មិញទាក់ទងជាមួយនឹងការបោសសម្អាតទ្រង់ទ្រាយធំនៅក្នុងឆ្នាំ៧៧។ អ៊ីចឹងកន្លែងនេះ លោកជម្រាបជូនអង្គសវនាការអម្បាញ់មិញនេះ ខ្ញុំចង់ដឹងថាតើលោកធ្លាប់ឃើញមានសាកសពដែលស្លាប់នៅតាមវាល តាមព្រៃ ជិតៗភូមិលោកដែរទេ?

**ឆៈ** នៅក្នុងចំណុចនេះ សាកសពហ្នឹងបើនិយាយពីអ្នកដែលស្លាប់ហ្នឹងនៅក្នុងរដូវវស្សា ខែទឹកទន្លេឡើងខ្លាំងមកមានបណ្ដែតទឹកហ្នឹងហូរ បណ្ដែតទឹកទន្លេហ្នឹងជាបន្តបន្ទាប់ បាទច្រើន បាទយើងបានឃើញ ហើយយើងគ្រាន់តែបានឮដំណឹងតៗថា នៅកន្លែងគេ សន្តិសុខ នៅស្រុកគេផ្សេងៗអីមានការកាប់សម្លាប់ អាហ្នឹងគ្រាន់តែបានឮតគ្នាអ៊ីចឹង បាទ។

**សៈ** បាទ សូមអរគុណ។ អម្បាញ់មិញ លោកជម្រាបជូនសវនាការអំពីថា លោកបានដឹងថាពួកចាមហ្នឹងគាត់អត់មានកំហុសទេ ដែលចាប់យកទៅសម្លាប់នេះ។ ចុះប្រជាពលរដ្ឋផ្សេងទៀត ចុះបើខ្មែរវិញ មានយកទៅសម្លាប់ដែរឬទេ?

**ឆៈ** ជម្រាបជូនថា ក្នុងនោះដែរ ក៏មានប្រជាជនថ្មីដែលជម្លៀសពីភ្នំពេញហ្នឹង ប្រហែលជាប្អូនដប់គ្រួសារដែរ ដែលមកនៅនឹងភូមិខ្ញុំហ្នឹង។ ហើយយូរៗទៅចេះតែបាត់ម្ដងបន្តិចៗជាបន្តបន្ទាប់យូរៗ

អស់។ បាទ អ៊ីចឹងខ្ញុំសន្និដ្ឋានថា អ្ហ៎! មុខតែគេយកទៅសម្លាប់ចោលអស់ហើយ។

[១៥:៤៦:២០]

**ស៖** តើលោកបានដឹងទេថា ពួកគាត់ហ្នឹងមានកំហុសដែរទេ?

**ឆ៖** ចំណែកប្រជាជនថ្មីហ្នឹង ខ្ញុំគ្រាន់តែដឹងថា គាត់គ្មានធ្វើអីខុសទេ គាត់ខិតខំប្រឹងខំធ្វើស្រែធ្វើចម្ការជាមួយបងប្អូនខ្មែរជាប្រជាជនចាស់ហ្នឹងរាល់ថ្ងៃហ្នឹងបាន។

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញឈ្មោះ រុន ជាមេសន្តិសុខនៅក្នុងឃុំអង្គរបាន ហើយឈ្មោះ ហាន ជាប្រធាននៅមន្ទីរសន្តិសុខអូរត្រកួន។ ចុះលោកស្គាល់ឈ្មោះ -- លោកដឹងឈ្មោះ ឬក៏ស្គាល់ឈ្មោះ គណៈស្រុក និងគណៈតំបន់ដែលលោករស់នៅហ្នឹងឈ្មោះអីដែរទេ?

**ឆ៖** ចំពោះលោកចៅហ្វាយស្រុក ខ្ញុំបានជម្រាបជូនហើយថា ឈ្មោះ កាន។ ប៉ុន្តែចំពោះគណៈតំបន់នោះ ខ្ញុំគ្រាន់តែបានឮគេនិយាយទេថា ហៅ មិត្តតាំង មិត្តស្រេង ជាគណៈតំបន់ ប៉ុន្តែខ្ញុំអត់ដែលបានឃើញស្គាល់គាត់ទេ គ្រាន់តែឮនិយាយតៗគ្នាថាមិត្តតាំង មិត្តស្រេងហ្នឹង ជាគណៈប្រធានតំបន់បាទ។

**ស៖** បាទ សូមអរគុណ។ លោកបានជម្រាបជូនអង្គសវនាការអំពីពេលវេលាអ្នកដែលគ្រប់គ្រងតំបន់នោះមុន ហើយដល់ឆ្នាំ៧៧ មានពួកខាងនិរតីមក។ អ៊ីចឹងតើឈ្មោះ តាំង និងឈ្មោះ ស្រេង ហ្នឹងជាគណៈតំបន់មុនពេលខាងនិរតីមក ឬក៏មានចាត់តាំងឈ្មោះហ្នឹងរហូតមក?

**ឆ៖** ខ្ញុំបានឮគេហៅ និយាយមិត្តតាំង មិត្តស្រេង ហ្នឹង គឺនៅក្នុងជំនាន់ដំណាលចៅហ្វាយស្រុកឈ្មោះ កាន ហ្នឹងធ្វើការងារដែរបាទ។

**ស៖** មុនពេលខាងនិរតីមក ឬក្រោយពេលខាងនិយាយមក?

**ឆ៖** នៅពេល កាន ហ្នឹងទៅប្រជុំក៏មាននិយាយរឿងមិត្តតាំង មិត្តស្រេង ដែរបាទ។ បានន័យថាប្រហែលជាមុនគេមក ហើយក៏គេនៅធ្វើការជាប់នៅហ្នឹង។ នេះតាម--

**ស៖** តំបន់ដែលលោករស់នៅហ្នឹង លោកស្គាល់ទេ គេដាក់ឈ្មោះតំបន់អី ឬក៏ជាលេខប៉ុន្មានដែរទេ?

**ឆ៖** ភូមិដែលខ្ញុំរស់នៅ គឺខ្ញុំអត់បានស្គាល់ទេ ហើយគេក៏អត់បាន--

**ស៖** សូមម្តងទៀត ខ្ញុំសួរលោកអំពីឈ្មោះតំបន់ គេដាក់ឈ្មោះ ឬគេដាក់លេខបាទ?

**ឆ៖** បាទ ចំពោះភូមិដែលខ្ញុំនៅហ្នឹង ខ្ញុំអត់បានដឹង អត់បានស្គាល់ថា ជាឈ្មោះតំបន់លេខប៉ុន្មាន ឬក៏គេហៅតំបន់ស្អីដែរបាទ។

[១៥:៤៩:៤៩]

**ស៖** បាទ សូមអរគុណ។ ដោយសារលោករស់នៅនឹងឃុំអង្គរបានជាប់លាប់រហូត ខ្ញុំចង់សួរលោកថា ក្រោយថ្ងៃរំដោះ ០៦ មករា តើលោកដែលចូលទៅក្នុងវត្តអូរត្រកួនភ្លាមៗដែរទេ កន្លែងមន្ទីរសន្តិសុខហ្នឹង?

**ឆ៖** ក្រោយដាច់ឆ្នាំ៧៩ មក ខ្ញុំអត់ដែលបានចូលទេ ភ្លាមៗហ្នឹងបាទ។

**ស៖** តើលោកមានធ្លាប់បានចូលរួមប្រជុំអំពីរឿងដំណឹងអំពីអ្នកដែលស្លាប់នៅក្នុងមន្ទីរសន្តិសុខវត្តអូរត្រកួនហ្នឹងដែរទេ?

**ឆ៖** ខ្ញុំបានធ្លាប់ចូលរួមប្រជុំក្រោយផ្តួលរំលំរបបប៉ុល ពត មកគឺខាងមន្ត្រី អ្នកធ្វើការងារយើងហ្នឹងដូចជាលោកអភិបាលស្រុកអីប្រជុំតាមរយៈបុណ្យទានហ្នឹង គ្រាន់តែនិយាយថា ប៉ុល ពត យកអ្នកស្រុកមកសម្លាប់នៅក្នុងវត្តអូរត្រកួនហ្នឹងប្រហែល – ពាក្យថា"ប្រហែល" ទេ គឺប្រហែល៣០.០០០នាក់ ប៉ុន្តែ៣០.០០០នេះ មិនមែនជាតួលេខច្បាស់លាស់ទេ គ្រាន់តែប៉ាន់ស្មានដែរទេ ហើយដឹងឮហ្នឹងតាមរយៈអ្នកធ្វើការងារហ្នឹងគេប្រជុំប្រាប់ បាទ។

**ស៖** លោកមានឃើញរណ្តៅសព ឬក៏លលាដ៍ក្បាលសាកសព ឬក៏ឆ្អឹងសាកសពនៅបន្សល់ទុកនៅវត្តអូរត្រកួនហ្នឹងដែរទេ?

**ឆ៖** បាទ នៅក្នុងវត្តអូរត្រកួននេះ គឺខ្ញុំបានឃើញ ពីព្រោះកន្លែងហ្នឹងឥឡូវគេធ្វើជាស្តូកមួយរើសក្បាល លលាដ៍ក្បាលសាកសពហ្នឹងក្បាលខ្មោចហ្នឹងមកតម្កល់ទុក ហើយធ្វើបុណ្យរំឭកវិញ្ញាណក្ខន្ធហ្នឹងរៀងរាល់ឆ្នាំហ្នឹងបាទ មានច្រើន។

**ស៖** បាទ អរគុណៗបាទ។ ចុះនៅជុំវិញវត្តអូរត្រកួនហ្នឹងមានកន្លែងដែលលោកដឹងថាកន្លែងគេសម្លាប់មនុស្សក្នុងសម័យខ្មែរក្រហមលើសពីវត្តអូរត្រកួនហ្នឹងទៀតដែរទេ?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំអត់បានដឹងដែរបាទ។

[១៥:៥២:២២]

**លោក ហុង គឹមសួន៖**

បាទ ខ្ញុំបាទសូមអរគុណ។ ខ្ញុំបាទអស់សំណួរហើយលោកប្រធាន។ សូមអរគុណបាទ។

អរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយសវនាការនៅរសៀលនេះដូចជាជឿនលឿនជាងពីព្រឹក ហើយនៅសល់ពេលវេលាតិចតួចទេ។ ដូច្នេះហើយសវនាការនៅថ្ងៃនេះ ដល់ពេលសម្រាកហើយ។

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ គ្រាន់តែជម្រាបជូនលោកប្រធានថា ក្រុមយើងខ្ញុំគ្មានសំណួរទេ។ ខ្ញុំមិនដឹងថាក្រុម ខៀវ សំផន គាត់មានសំណួរ<ឬទេ។ បើសិនជាគាត់មានសំណួរដែលប្រើពេលតែ>១០នាទី ឬ<១៥នាទី យើងអាច>បញ្ចប់ថ្ងៃនេះតែម្តង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗណាស់ដែលបានផ្តល់ព័ត៌មានដូច្នេះ។

បាទ សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន! ហើយត្រូវការចំណាយពេលវេលាប្រហែលប៉ុន្មានទៅដំបូង ដើម្បីអង្គជំនុំជម្រះប៉ាន់ប្រមាណមើលថា តើគួរបន្តនៅរសៀលនេះ ឬក៏លើកទៅបន្តធ្វើនៅថ្ងៃស្អែក?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសោកស្តាយណាស់ដែលខ្ញុំធ្វើឲ្យមេធាវី កូប៉េ ខកចិត្ត ប៉ុន្តែខ្ញុំ ខ្ញុំត្រូវការពេលវេលាប្រហែលជាជាងដប់នាទី លើសជាងដប់នាទីនៅសល់ហ្នឹងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញ! បង្ហើយតែម្តងទៅដើម្បីឲ្យគាត់មានលទ្ធភាពអាចវិលត្រឡប់ទៅផ្ទះវិញផង។ ព្រោះនៅសល់ច្រើនដែរប្រហែលជាអាច ១៥នាទីអី អាចទៅរួចណ៎ះ!

បាទ សូមអញ្ជើញបាទ!

ឥឡូវត្រូវការពេលប៉ុន្មាន? ឥឡូវម៉ោងទើបតែប្រាំ -- ខ្វះប្រាំពីរនាទីទៀត ម៉ោងបួនណ៎ះ!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំគិតថាមានបញ្ហាការបកប្រែ។ ខ្ញុំនិយាយអំមិញថា ខ្ញុំត្រូវការពេលវេលាជាងដប់នាទី។ អ៊ីចឹងឥឡូវនេះ <ខ្ញុំមិនអាចចាប់>ចោទ<សួរ ហើយបញ្ចប់>សំណួរទៅសាក្សីរូបនេះ<ក្នុងថ្ងៃនេះបាន>ទេលោកប្រធាន<។ ដូច្នេះខ្ញុំគិតថា> បើសិនជាលោកប្រធានចង់ឲ្យសម្រាកឥឡូវនេះក៏ធ្វើបាន។ ខ្ញុំមិន<ដឹងពិតប្រាកដថាខ្ញុំត្រូវការ>ពេល<ប៉ុន្មាន>ទេ<។> គឺថា<>អាចថា<៤៥>នាទី ក៏ថាបាន ឬក៏

លើសពីហ្នឹងក៏ថាបាន <វាអាស្រ័យទៅលើការឆ្លើយរបស់សាក្សី។ ប៉ុន្តែពិតប្រាកដណាស់ វាអាចបន្តរហូតដល់ម៉ោងបួនល្ងាច។> ប្រហែល<ជាលើសហ្នឹង>ច្រើនទៀត លោកប្រធាន។

[១៥:៥៥:២០]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញសហ -- លោកៗ យុយ យ៉ាងម៉េចទៅ?

**លោក សេង យុយ៖**

បាទ ខ្ញុំសូមគោរពលោកប្រធានអង្គជំនុំជម្រះថា ខ្ញុំសូមអរគុណណាស់ ខ្ញុំសូមលោកប្រធានមេត្តាបញ្ចប់នូវការសាកសួរ និងផ្តល់ជាព័ត៌មានដល់ខ្ញុំ ព្រោះខ្ញុំនៅមូលដ្ឋាន ខ្ញុំធ្វើការងារជាមេឃុំ ហើយមកបីថ្ងៃថ្ងៃនេះហើយ ហើយផ្ទះហ្នឹងបិទទ្វារចោល ហើយសូមជួយបញ្ចប់ល្ងាចហ្នឹងផងទាន ព្រោះដល់ថ្ងៃស្អែកទៀត បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយយើងលៃលកអំមិញថា វាលទ្ធភាពទៅរួច ប៉ុន្តែប្រហែលការប៉ាន់ស្មានទៅទៅមិនរួចទេ ព្រោះអំមិញថា១០នាទីហ្នឹង វាៗទំនងហើយភាសាខ្មែរ ប៉ុន្តែដល់ពេលយើងបញ្ជាក់ឡើងនេះ គឺមិនប្រាកដថារយៈពេលប៉ុន្មានទេ ប៉ុន្តែទំនងថ្ងៃស្អែកនេះ មិនវែងប៉ុន្មានទេ យ៉ាងច្រើន មួយវគ្គនេះបានន័យថាមួយម៉ោងប៉ុណ្ណោះណ៎ា។ ដូច្នេះយើងមិនអាចធ្វើការបញ្ចប់បានតាមៗពេលវេលានៅរសៀលនេះបានទេ ព្រោះពេលវេលាខ្លីពេក។

បាទ ហើយសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ទី១០ ខែកញ្ញា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី សេង យុយ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណ លោក សេង យុយ ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សី នៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នក

ជំនាញជូនលោក សេង ឃុយ ត្រឡប់ទៅកាន់ទីន្លែងដែលគាត់ស្នាក់នៅវិញចុះ និងឲ្យអញ្ជើញគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកវិញនៅវេលាម៉ោងប្រាំបួនព្រឹក ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

បាទ សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង១៥:៥៨នាទី)*